សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Science Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការបញ្ជូនរឿងទៅស៊ើបសួរ

ស្រាវជ្រាវពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **យៀង សុមុន្នី**

សាស្ត្រាចារ្យណែនាំ
លោក **ហោ សោភ័ណ្ឌ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Science Economiques**

**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# ការបញ្ជូនរឿងទៅស៊ើបសួរ

ស្រាវជ្រាវពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **យឿង សុមុន្នី**

សាស្ត្រាចារ្យណែនាំ
លោក **ហោ សោភ័ណ្ឌ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# **សេចក្តីថ្លែងអំណរគុណ**

**៙៚**

ខ្ញុំបាទឈ្មោះ **យៀង សុមុន្នី** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រឆ្នាំទី ៤ ជំនាន់ទី ១៩ នៃ ***សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច*** ។

**សូមអនុញ្ញាតគោរព ដឹងគុណ និងថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅបំផុតជូន**

-**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃ ព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ដែលបានខិតខំគ្រប់កាលៈទេសៈក្នុងការបង្រួបបង្រួមជាតិ ឯកភាពជាតិ ឲ្យទទួលបាននូវ សុខសន្តិភាព និង ការអភិវឌ្ឍន៍ប្រទេសជាតិ លូតលាស់រីកចម្រើនគ្រប់វិស័យ ប្រកបដោយនិរន្តរភាព ដោយមានការទទួលខុសត្រូវខ្ពស់ចំពោះបច្ចុប្បន្ន និង អនាគត់ នៃជាតិមាតុភូមិកម្ពុជានៃយើង ។ ជាក់ស្តែង សមិទ្ធិផលដែលបានជាផ្លែ ជាផ្កាដ៏មានតម្លៃដែលមិនអាចកាត់ថ្លៃបាននេះហើយ ទើបអនុញ្ញាតឲ្យរូបខ្ញុំបាទ ទទួលបានការសិក្សាក្រេបជញ្ជក់នូវពុទ្ធិផ្សេងៗ ទាក់ទងនឹងវិស័យច្បាប់ក្រោមដំបូលសុខសន្តិភាព ។

-**សហភាពសហព័ន្ធយុវជនកម្ពុជា** ក្រោមការដឹកនាំរបស់ **ឯកឧត្តម ហ៊ុន ម៉ានី** ដែលបានបង្កើតស្ថាប័ននេះឡើង ព្រមទាំងបានផ្តល់នូវអាហារូបករណ៍ ជាច្រើនដល់សិស្សនិស្សិត និង យុវជនកម្ពុជា គ្រប់ស្រទាប់វណ្ណៈ ដោយឥតប្រកាន់ និន្នាការនយោបាយ ជាតិ សាសនា ឬពណ៌សម្បុរ ទៅតាមសមត្ថភាព និងគោលបំណងរៀងៗខ្លួន ដោយឲ្យបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រ និង បរិញ្ញាបត្រជនខ្ពស់ គ្រប់ជំនាញ គ្រប់កម្រិត តាមតម្រូវការរបស់ខ្លួន ។ ជាក់ស្តែងណាស់ស្ថាប័ននេះក៏បាន ផ្តល់នូវ**អាហារូបករណ៍**ដល់រូបខ្ញុំបាទ ឲ្យបានសិក្សាថ្នាក់វិញ្ញាបត្រនីតិសាស្ត្រនៃ ***សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច*** រយៈពេល (៤ឆ្នាំ) មួយចប់កម្មវិធីសិក្សារហូតទទួលបានជោគជ័យ យ៉ាងត្រចះត្រចង់គោជាទីមោទនៈ និង បានផ្តល់នូវការបណ្តុះបណ្តាលការងារសង្គមជាច្រើនផ្សេងៗទៀត នៃសកម្មភាពការងារកន្លងមក ។

-**ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង** ព្រមទាំងលោក លោកស្រីសាស្ត្រាចារ្យ ទាំងអស់ក្នុងក្របខ័ណ្ឌ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអស់កម្លាំងកាយ កម្លាំងចិត្ត ចូលរួមលើកស្ទួយដល់ការបណ្តុះបណ្តាលធនធានមនុស្ស ឲ្យទទួលបាននូវមូលធនបញ្ញាយ៉ាងច្បាស់លាស់ ជាពិសេសបានបង្ហាត់បង្រៀនដល់រូបខ្ញុំបាទ តាំងពីឆ្នាំសិក្សាថ្នាក់មូលដ្ឋានរហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ ព្រមទាំងទទួលបាននូវចំណេះដឹងផ្នែកច្បាប់ដើម្បី យកទៅចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ ឲ្យមានភាពរីកចម្រើនបន្ថែមទៀតទៅថ្ងៃអនាគត់ ។

-ជាពិសេស ដោយក្ដីគោរពយ៉ាងធំធេង និងដោយស្មោះអស់ពីដួងចិត្តបំផុត ជូនចំពោះលោកសាស្ត្រាចារ្យ **ហោ សោភ័ណ្ឌា** ជាសាស្ត្រាចារ្យទទួលបន្ទុក ដឹកនាំសារណា ដែលលោកបានខិតខំអស់ពី កម្លាំងកាយ កម្លាំងចិត្ត ប្រាជ្ញាស្មារតី និង ពេលវេលាដ៏មានតម្លៃ ព្រមទាំង ដោយភាពមមាញឹក ដោយផ្ដល់ជាគំនិតផ្ដួចផ្ដើមដ៏ច្រើនសន្ធឹកសន្ធាប់ ក្នុងការជម្រុញណែនាំ លើកទឹកចិត្ត និងបានត្រួតពិនិត្យកែលម្អ ជាច្រើនលើក ច្រើនសារ ដល់រូបខ្ញុំបាទ លើការស្រាវជ្រាវ ចងក្រង សរសេរនូវអត្ថបទសារណានេះឡើង រហូតបានបញ្ចប់ជាស្ថាពរ និងប្រកបដោយលទ្ធផលជាវិជ្ជមាន ។

-**លោកឪពុក អ្នកម្ដាយ** និង **លោកយាយ** ដែលលោក បានផ្ដល់នូវកំណើតដល់រូបខ្ញុំបាទ ព្រមទាំងខិតខំតស៊ូលំបាកគ្រប់យ៉ាងប្តូរផ្ដាច់ ក្នុងការចិញ្ចឹមបីបាច់ថែរក្សា ការពារអប់រំទូន្មាន ប្រៀនប្រដៅរូបកូនប្រកបដោយទឹកចិត្ត ព្រហ្មវិហារធម៌គ្មានទីបំផុត និងជារៀងរហូតមក ។ ទឹកដោះម្ដាយថ្លៃទើបកូនមានថ្ងៃនេះ ដោយសារលោកអ្នកទាំងទ្វេ បានខិតខំមិនខ្លាចនឿយហត់ ទាំងយប់ទាំងថ្ងៃ ទាំងឈឺ ទាំងជា ពុះពារគ្រប់ការលំបាកដើម្បីកូនបាន ទទួលការសិក្សាតាំងតែពីថ្នាក់បឋមសិក្សារហូតមកដល់បញ្ចប់ថ្នាក់មហាវិទ្យាល័យនៃបរិញ្ញាបត្រនីតិសាស្ត្រ ប្រកបទៅដោយភាពជោគជ័យ ។ គុណូបការៈគុណដ៏មានតម្លៃថ្លៃថ្លាដែលមិនអាចកាត់ថ្លៃបានក្នុងជាតិនេះ ហើយកូនសូមអនុញ្ញាតបួងសួង ដល់វត្ថុស័ក្តសិទ្ធិដែលថែរក្សានៃព្រះរាជាណាចក្រកម្ពុជា សូមជួយតាមថែរក្សាបីបាច់ដល់ **លោកយាយ** និង **អ្នកម្ដាយ** អោយមានសុភាពល្អ ព្រមទាំងអាយុយឺនយូ ដើម្បីជាម្លប់ត្រជាក់ដល់កូនចៅតរៀងទៅ ។ ម្យ៉ាងវិញទៀត ដោយអំណាចនៃគុណបុណ្យព្រះរតនៈត្រៃ មានព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាប្រធាន និងកុសលផលបុណ្យទាំងឡាយ សូមជួយអោយវិញ្ញាណក្ខន្ធរបស់ **លោកឪពុក** បានសោយសុខទៅក្នុងសុគតិភព ពោលគឺព្រះនិព្វាន។

ជាកិច្ចបញ្ចប់នេះ ខ្ញុំបាទសូមអនុញ្ញាតលើកដៃប្រណមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក និងទេវត្តាដែលមានបារមីទាំងឡាយ សូមជួយតាមបីបាច់ថែរក្សា **សម្ដេច ឯកឧត្តម លោកជំទាវ លោក លោកស្រីសាស្ត្រាចារ្យ និង លោក លោកស្រី** ដូចបានរៀបរាប់ខាងលើទាំងអស់ សូមជួបប្រទះតែភាពសុខដុមរមនា កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ អាយុយឺនយូរ សុភមង្គល និងភាពចម្រុងចំរើនជានិច្ចនិរន្តរ៍ តរៀងទៅ ជាពិសេស សូមបានជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ប្រទេសកម្ពុជា ក៏ដូចជាបណ្តាប្រទេសផ្សេងៗទៀត នៅលើពិភពលោកយើងនេះ តែងតែចង់បាននូវការអភិវឌ្ឍន៍ប្រទេសរបស់ខ្លួនមួយដោយពិតប្រាកដ ប៉ុន្តែដើម្បីបានការអភិវឌ្ឍន៍ជាចាំបាច់ណាស់ ត្រូវការនូវសន្តិភាពនៃប្រទេសរបស់ខ្លួនជាមុនសិន។ សន្តិភាពកើតឡើងហើយចាំបាច់ត្រូវតែមានច្បាប់សម្រាប់គាំពារសង្គមនោះផង ជាក់ស្តែងណាស់រាល់ទំនាក់ទំនងនីមួយៗ មិនមែនសុទ្ធតែត្រូវគ្នាទាំងអស់នោះទេ ដោយសារតែទំនាស់មួយចំនួនដោះស្រាយមិនត្រូវគ្នានោះហើយ ទើបបណ្តាប្រទេសនីមួយៗ បានបង្កើតស្ថាប័នមួយហៅថាតុលាការ។ ដោយឡែកនៅក្នុងបរិបទនៃប្រទេសកម្ពុជាយើងនេះ ទំនាស់មានច្រើនប្រភេទទៅតាមរឿងក្តី ចំពោះសំណុំរឿងព្រហ្មទណ្ឌវិញ គឺត្រូវបានដោះស្រាយដោយតុលាការ តាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន។

ដោយសារតែក្រមនីតិវិធីព្រហ្មទណ្ឌ គឺជាច្បាប់គោលសំខាន់ក្នុងការដោះស្រាយរឿងក្តី ហើយដើម្បីឲ្យទទួលបាននូវភាពយុត្តិធម៌ សមស្របទៅ និងទង្វើររបស់ជនដែលបានប្រព្រឹត្តនោះ រឿងក្តីព្រហ្មទណ្ឌ ចាំបាច់ត្រូវតែធ្វើការស៊ើបសួរឲ្យមានភាពច្បាស់លាស់ មុននិងធ្វើការជំនុំជម្រះទៅលើជនណាម្នាក់ថាមានទោស ឬ គ្មានទោសនៃអំពើដែលបានកើតឡើង។ ដោយសារតែមូលហេតុនេះ ហើយបានជាជំរុញ ឲ្យយើងខ្ញុំដែលជានិស្សិតនីតិសាស្ត្រឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច មានចំណាប់អារម្មណ៍លើកិច្ចនីតិវិធីមួយនេះ ដូចជាការបញ្ជូនរឿងជាដើម គឺជាចំនុចមួយដែលខ្ញុំបាទមានចំណាប់អារម្មណ៍ជាងគេ។ ហេតុដូច្នេះហើយ ខ្ញុំបានសម្រេចចិត្តថា និង ខិតខំឲ្យអស់ពីកម្លាំងកាយ កម្លាំងចិត្តក្នុងការស្រាវជ្រាវ និង ធ្វើការសិក្សាទៅលើប្រធានបទ **ការបញ្ជូនរឿងទៅស៊ើបសួរ** ដើម្បីបង្ហាញឲ្យឃើញកាន់តែមានភាពច្បាស់លាស់ នូវនីតិវិធីនៃការបញ្ជូនរឿងក្តីព្រហ្មទណ្ឌមួយ ទៅកាន់ស្ថាប័នមួយទៀតដែលគេហៅថា ចៅក្រមស៊ើបសួរ ក្នុងការស៊ើបសួរស្វែងរកទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ហើយស្វែងរកអង្គហេតុពិត ព្រមទាំងធ្វើការជំនុំជម្រះដោយមិនមានភាពអយុត្តិធម៌។

ទោះបីជាមានការខិតខំប្រឹងប្រែង និងធ្វើដោយមានភាពហ្មត់ចត់យ៉ាងណាក៏ដោយ ក៏នៅតែមានការខ្វះចន្លោះ ដែលមិនបានមើល នៅតែមានជាយថាហេតុ មិនអាចជៀសផុតបាន។ ដូចនេះហើយ យើងខ្ញុំដែលជានិស្សិតសូមទទួលយកនូវរាល់មតិរិះគន់គ្រប់មជ្ឈដ្ឋាន ក្នុងន័យស្ថាបនាដើម្បីឲ្យសមិទ្ធិផលដ៏តូចមួយនេះ ឲ្យកាន់តែមានភាពប្រសើរឡើង និង សូមអនុញ្ញាតគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការរិះគន់ទាំងឡាយ និងការចំណាយពេលវេលាដ៏មានតម្លៃក្នុងការអាននូវស្នាដៃនៃការស្រាវជ្រាវមួយនេះ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១

## ការចោទប្រកាន់ដោយអយ្យការ

**ផ្នែកទី១៖ លក្ខខណ្ឌនៃការចោទប្រកាន់** ........ ៥

១. ការពិនិត្យលើលក្ខខណ្ឌ ........ ៥

១.១ បទល្មើសជាបទលហុ ........ ៥

១.២ បទល្មើសជាបទមជ្ឈិម ........ ៦

១.៣ បទល្មើសជាបទឧក្រិដ្ឋ ........ ៧

២. សិទ្ធិក្នុងការចោទប្រកាន់របស់ព្រះរាជអាជ្ញា ........ ៨

**ផ្នែកទី២៖ ការសម្រេចចោទប្រកាន់** ........ ៩

១. ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ........ ៩

១.១ នីតិវិធីនៃការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ........ ១០

១.២ អានុភាពនៃការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ........ ១១

២. ការបង្ហាញខ្លួនភ្លាម ........ ១១

២.១ ការបង្ហាញខ្លួនដើម្បីស៊ើបសួរ ........ ១២

២.២ ការបង្ហាញខ្លួនទៅជនុំជម្រះ ........ ១៣

៣. ការបើកការស៊ើបសួរ ........ ១៤

៣.១ លក្ខខណ្ឌនៃការបើកការស៊ើបសួរ ........ ១៥

៣.២ អានុភាពនៃការបើកការស៊ើបសួរ ........ ១៥

## ជំពូកទី២

## ការស៊ើបសួរ

**ផ្នែកទី១៖ ការចាត់តាំង ការបែងចែក និង ការដកហូតសំណុំរឿង** ........ ១៧

១. ការចាត់តាំង និង ការបែងចែកសំណុំរឿង ........ ១៧

២. ការដកហូតសំណុំរឿង ........ ១៨

**ផ្នែកទី២៖ លក្ខខណ្ឌនៃការស៊ើបសួរ** ........ ១៩

១. ការស៊ើបសួរដោយដីការបស់ព្រះរាជអាជ្ញា ........ ១៩
២. ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ........ ១៩
**ផ្នែកទី៣៖ ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ** ........ ២២
១. កិច្ចស៊ើបសួរទាក់ទង និង បុគ្គល ........ ២២
១.១ ជនត្រូវចោទ ........ ២២
១.២ ដើមបណ្តឹងរដ្ឋប្បវេណី ........ ២៣
១.៣ សាក្សី ........ ២៤
២. កិច្ចស៊ើបសួរទាក់ទង និង ភស្តុតាង ........ ២៦
២.១ ការប្រមូលភស្តុតាង ........ ២៧
២.២ ការវាយតម្លៃវត្ថុតាង ........ ២៨
៣. ការស្តាប់ទូរស័ព្ទ ........ ៣០
**ផ្នែកទី៤៖ វិធានការនិរន្តរាយ** ........ ៣១
១. ដីកា ........ ៣២
១.១ ដីកាបង្គាប់ឲ្យចូលខ្លួន ........ ៣២
១.២ ដីកាបង្គាប់ឲ្យនាំខ្លួន ........ ៣៣
១.៣ ដីកាបង្គាប់ឲ្យចាប់ខ្លួន ........ ៣៣
១.៤ ដីកាបង្គាប់ឲ្យឃុំខ្លួន ........ ៣៥
២. ការឃុំខ្លួនបណ្តោះអាសន្ន ........ ៣៥
២.១ មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន ........ ៣៦
២.២ លក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន ........ ៣៦
២.៣ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ........ ៣៧
២.៤ អានុភាពនៃការឃុំខ្លួនបណ្តោះអាសន្ន ........ ៣៨
៣. ការត្រួតពិនិត្យតាមផ្លូវតុលាការ ........ ៣៨
៣.១ ការជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ........ ៣៨
៣.២ នីតិវិធីនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ........ ៣៩
៣.៣ អានុភាពនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ........ ៤១

**ផ្នែកទី៥៖ ការបិទការស៊ើបសួរ** ........ ៤១
១. ដំណាក់កាលបឋម ........ ៤១
១.១ ការជូនព័ត៌មាន ........ ៤១
១.២ ការបញ្ជូនសំណុំរឿងឲ្យព្រះរាជអាជ្ញា ........ ៤២
១.៣ ដីកាស្ថាពររបស់ព្រះរាជអាជ្ញា ........ ៤២
២. នីតិវិធីចុងក្រោយនៃការស៊ើបសួរ ........ ៤២
២.១ ការលើកលែងបទចោទប្រកាន់ ........ ៤២
២.២ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ........ ៤៤
**សេចក្ដីសន្និដ្ឋាន** ........ ៤៥
**អនុសាសន៍** ........ ៤៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១.បុព្វហេតុ

បន្ទាប់ពីប្រទេសកម្ពុជាបានរួចផុតពីរបបនៃសង្គ្រាមជាច្រើនឆ្នាំកន្លងមក ព្រះរាជាណាចក្រកម្ពុជាក៏បានបង្កើតរដ្ឋធម្មនុញ្ញនៅឆ្នាំ១៩៩៣ ដោយធ្វើការបែងចែកអំណាចដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និង អំណាចតុលាការ។[1] ដែលអំណាចតុលាការ ត្រូវបានប្រគល់ឲ្យតុលាការកំពូល និង សាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់។ នៅក្នុងការដោះស្រាយរឿងក្តី នៃប្រព័ន្ធតុលាការ ចាំបាច់តម្រូវឲ្យមាននូវច្បាប់នីតិវិធីមួយជាក់លាក់ តួយ៉ាងដូចជាក្រមនីតិវិធីព្រហ្មទណ្ឌថ្មីមួយ ត្រូវបានរដ្ឋសភាអនុម័តលើសម្លេង ៨៣ លើ ៨៣ នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧ ហើយត្រូវបានព្រឹទ្ធសភាអនុម័ត ដោយសម្លេង ៥១ លើ ៥១។ អ្វីដែលវិសេសវិសាលជាងនេះទៅទៀត **ព្រះមហាក្សត្រ** ទ្រង់បានឡាយព្រះហត្ថលេខាប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌនេះ ជាផ្លូវការនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។ ក្រមនីតិវិធីព្រហ្មទណ្ឌនេះ ជាយន្តការក្នុងការដោះស្រាយនូវរឿងក្តីព្រហ្មទណ្ឌ ដើម្បីធានាឲ្យមានភាពយុត្តិធម៌ក្នុងប្រព័ន្ធតុលាការ ពោលគឺធ្វើយ៉ាងណាកំណត់ឲ្យបានច្បាស់ និងប្រកបដោយតក្កៈភាពនូវ **អត្ថិភា** ឬ **នត្ថិភាព** នៃបទល្មើសណាមួយ ហើយជាពិសេសមានគោលបំណងចម្បងធ្វើឲ្យមានការគោរពសិទ្ធិ និងការពារផលប្រយោជន៍ ជូនដល់គ្រប់ភាគីនៅក្នុងរឿងក្តីព្រហ្មទណ្ឌ។

តាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌថ្មីនេះ បានបង្កើតឲ្យមានស្ថាប័នជាច្រើន ដែលក្នុងនោះមានស្ថាប័នពីរសំខាន់ៗ គឺ **ស្ថាប័នអយ្យការ** និង **ស្ថាប័ននៃចៅក្រមស៊ើបសួរ** ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការស្វែងរកនូវភាពយុត្តិធម៌ នៅក្នុងដំណាក់កាលនៃរឿងក្តីព្រហ្មទណ្ឌ។ ហើយនៅក្នុងក្របខ័ណ្ឌនៃដំណើរការរឿងក្តីព្រហ្មទណ្ឌ ប្រទេសកម្ពុជាបានប្រកាន់យក**ប្រព័ន្ធអាំងគីស៊ីទ័រ** ចំណែកឯនៅក្នុងដំណើរការរឿងក្តីរដ្ឋប្បវេណីវិញប្រទេសកម្ពុជាយើង បានជ្រើសរើសយក***ប្រព័ន្ធអគុយសាទ័រ*** ដើម្បីធ្វើការអនុវត្តនូវដំណើរការនៃរឿងក្តី។[2] ក្នុង***ប្រព័ន្ធអគុយសាទ័រ*** នៅពេលមានជម្លោះម្តងៗ គឺគូភាគីនៃបណ្តឹងជាអ្នកទទួលបន្ទុកភស្តុតាង តួរអង្គរដ្ឋគ្រាន់តែដើរតួរជាអ្នកវិនិច្ឆ័យតែប៉ុណ្ណោះ។ ចំណែកឯ ***ប្រព័ន្ធអាំងគីស៊ីទ័រ*** វិញគឺតួរអង្គរដ្ឋ (**អយ្យការ**) ដើរតួនាទីយ៉ាងសំខាន់ក្នុងការស្វែងរកភស្តុតាង ហើយរកតែភស្តុតាងដាក់បន្ទុកតែប៉ុណ្ណោះ ដូចនេះហើយទើបគេបង្កើតឲ្យមានតួរអង្គមួយឯករាជ្យ

---

1 មាត្រា៥១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

2 ដកស្រង់ចេញពីសៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌរបស់លោកសាស្ត្រាចារ្យ KOEUY Vinh-Koeurm បោះពុម្ពនៅឆ្នាំ ២០១៤-២០១៥ ត្រង់ទំព័រទី២។

ដែលទទួលបន្ទុកស្វែងរកភស្តុតាងទាំងដាក់បន្ទុក និងដោះបន្ទុកដែលត្រូវបានគេហៅថា *ចៅក្រមស៊ើបសួរ* ។ ដូច្នេះនៅក្នុងដំណាក់កាលនៃ **ការបញ្ជូនរឿងទៅស៊ើបសួរ** ពិតជាមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការដោះស្រាយនៃរឿងក្តីព្រហ្មទណ្ឌ ពីព្រោះដើម្បីឲ្យចៅក្រមស៊ើបសួរ ទទួលយកសំណុំរឿងទៅស៊ើបសួរ ស្វែងរកការពិតជូនដល់ភាគីទទួលយកបាន នូវភាពយុត្តិធម៌ទៅតាមទង្វើរនៃអំពើដែលខ្លួនបានប្រព្រឹត្ត។

**២.ចំណោទបញ្ហា**

ទន្ទឹមនឹងការលើកឡើងខាងលើ ក៏មានចម្ងល់ និងបញ្ហាមួយចំនួនត្រូវបានចោទឡើង ពាក់ព័ន្ធនឹង ការបញ្ជូនរឿងទៅស៊ើបសួរ ថា **តើការបញ្ជូនរឿងទៅស៊ើបសួរត្រូវមាននូវលក្ខខណ្ឌអ្វីខ្លះ? ហើយ តើស្ថាប័នណាជាអ្នកមានសមត្ថកិច្ចក្នុងការបញ្ជូនរឿង? តើស្ថាប័នណាជាអ្នកទទួលសំណុំរឿងក្តីយកទៅធ្វើការស៊ើបសួរបន្ត? ហើយមាននីតិវិធីដូចម្តេច?**

**៣.គោលបំណងនៃការស្រាវជ្រាវ**

ការស្រាវជ្រាវ និងសិក្សាលើប្រធានបទ **ការបញ្ជូនរឿងទៅស៊ើបសួរ** មានគោលបំណងមួយចំនួនដូចជា៖

- ទុកជាស្នាដៃនៃការសិក្សាបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ
- ទុកជាអត្ថបទសម្រាប់អ្នកអាន និង អ្នកស្រាវជ្រាវជំនាន់ក្រោយៗបន្តទៀត
- ចូលរួមផ្សព្វផ្សាយ គោរព និងលើកកម្ពស់ផ្នែកវិស័យច្បាប់
- បានជាចំណេះដឹងនៃនីតិវិធីព្រហ្មទណ្ឌតាមរយៈការបញ្ជូនរឿងក្តីព្រហ្មទណ្ឌ
- អ្វីដែលខ្ញុំទទួលបានដោយមិនអាចខ្វះបាននោះគឺដឹងពីសមត្ថភាពពិតប្រាកដរបស់ខ្លួនឯង៕

**៤.ដែនកំណត់នៃការស្រាវជ្រាវ**

អត្ថបទដែលខ្ញុំបាទបានយកចិត្តទុកដាក់ស្រាវជ្រាវនេះ គឺស្រាវជ្រាវត្រឹមតែ **ការបញ្ជូនរឿង** ដោយស្ថាប័នអយ្យការអមសាលាដំបូង *(ការចោទប្រកាន់)* ទៅកាន់ **ចៅក្រមស៊ើបសួរ** *(ការស៊ើបសួរ)* នៃសាលាដំបូងតែប៉ុណ្ណោះ។ ដោយនៅត្រង់ចំណុច ការចោទប្រកាន់ដោយអយ្យការ និងបានបញ្ចប់ទៅវិញ ត្រឹមការបិទការស៊ើបសួរ របស់ចៅក្រមស៊ើបសួរ។

**៥.វិធីសាស្ត្រនៃការស្រាវជ្រាវ**

ដើម្បីសម្រេចនូវគោលបំណង នៃការស្រាវជ្រាវអត្ថបទខាងលើនេះ ខ្ញុំបាទបានសិក្សាទៅលើឯកសារដែលពាក់ព័ន្ធ និង ទ្រឹស្តីក៏ដូចជាមេរៀនដែលបានរៀនកន្លងមក ហើយក៏បានបញ្ចូលនូវអត្ថន័យនៃសៀវភៅមេរៀនរបស់ លោក លោកស្រីសាស្ត្រាចារ្យ ផ្សេងៗដែលមានការទាក់ទងគ្នាទៅ

និងប្រធានបទខាងលើ។ ព្រមទាំងបានទទួលនូវការណែនាំ ផ្តល់ដំបូន្មានល្អៗពី លោកសាស្ត្រាចារ្យដឹកនាំស្រាវជ្រាវ សារណាមួយនេះ។ ហើយនៅក្នុងលិខិតបទដ្ឋានគតិយុត្ត មួយចំនួនមានដូចជា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ រួមទាំងច្បាប់ប្រកាស និង លិខិតគតិយុត្តផ្សេងៗ ទៀតដែលមានជាធរមាននៅពេលបច្ចុប្បន្ន ខ្ញុំក៏បានញ្ចូលនៅក្នុងអត្ថបទនេះផងដែរ។

## ៦.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដូចនេះជាដំណោះ ស្រាយទៅលើបញ្ហាគតិយុត្តខាងលើ ហើយដើម្បីជាការសិក្សាទៅលើប្រធានបទនៃ **ការញ្ជូនរឿងទៅស៊ើបសួរ** ខ្ញុំបាទបានស្រាវជ្រាវទៅលើចំនុចសំខាន់ៗ ចំនួន ២ (ពីរ) ជំពូកគឺ៖ **ជំពូកទី១ ការចោទប្រកាន់ដោយអយ្យការ** និង **ជំពូកទី២ ការស៊ើបសួរ** ព្រមទាំងមានការបកស្រាយនូវខ្លឹមសារសំខាន់ៗ ដូចខាងក្រោមនេះ៖

# ជំពូកទី១
# ការចោទប្រកាន់ដោយអយ្យការ

បន្ទាប់ពីព្រះរាជអាជ្ញា បានទទួលនូវពាក្យបណ្តឹងទាមទារពីជនរងគ្រោះ ឬ អ្នកតំណាងរបស់ជនរងគ្រោះ ឬទទួលបានរបាយការណ៍ពីមន្រ្តីនគរបាលយុត្តិធម៌ ប្តឹងចោទប្រកាន់ទៅលើជនណាម្នាក់ទាក់ទង នឹងបទល្មើសព្រហ្មទណ្ឌ ព្រះរាជអាជ្ញាមិនធ្វើការចោទប្រកាន់បានភ្លាមនោះទេ។ មុននឹងសម្រេចធ្វើការចោទប្រកាន់ ព្រះរាជអាជ្ញាបើកការស៊ើបអង្កេតបឋម ឬ បង្គាប់ឲ្យធ្វើការស្រាវជ្រាវបន្ថែម។[3]ម្យ៉ាងវិញទៀត ព្រះរាជអាជ្ញាមុននឹងសម្រេចក្នុងការចោទប្រកាន់ ត្រូវតែធ្វើការពិនិត្យយ៉ាងល្អិតល្អន់ទៅលើកត្តាមួយចំនួនដូចជា៖

- តើការប្រព្រឹត្តអំពើរបស់ជននោះមានធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌដែរឬទេ ?
- តើជនសង្ស័យមានអភ័យឯកសិទ្ធិដែរឬទេ ?
- តើអំពើរបស់ជននោះអាចចាត់ទុកជាបទល្មើសព្រហ្មទណ្ឌដែរឬទេ ?
- តើបណ្តឹងអាជ្ញាមានការផុតរលត់ហើយឬនៅ ?
- ជនជាប់សង្ស័យដែលត្រូវបានចោទប្រកាន់ ត្រូវចោទប្រកាន់ក្នុងនាមជាអ្វីដើម្បី ឲ្យសមស្របទៅ នឹងអំពើដែលបានប្រព្រឹត្តដែរឬទេ?
- ត្រូវត្រួតពិនិត្យ ទៅលើពាក្យបណ្តឹង ថាត្រូវនិងសមត្ថកិច្ចរបស់ខ្លួនដែរ ឬទេ ?
- ត្រូវត្រួតពិនិត្យថា តើអំពើនោះចាំបាច់ត្រូវតែមានពាក្យបណ្តឹងពីជនរងគ្រោះដែរឬទេ ?

ក្រោយពីបានធ្វើការស៊ើបអង្កេតយ៉ាងត្រឹមត្រូវ ទៅលើសំណុំរឿងព្រហ្មទណ្ឌរួចមក ព្រះរាជអាជ្ញាមានតួនាទីយ៉ាងសំខាន់ ក្នុងដំណាក់កាលនៃការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌ។ ព្រោះព្រះរាជអាជ្ញាជាម្ចាស់នៃបណ្តឹងអាជ្ញា[4] ហើយបណ្តឹងអាជ្ញាអនុវត្តទៅលើបុគ្គលគ្រប់រូបទាំង រូបវន្តបុគ្គល និង នីតិបុគ្គល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធានឬ ស្ថានភាពឯទៀតឡើយ។[5]

ព្រះរាជអាជ្ញាអនុវត្តបណ្តឹងអាជ្ញា ក្នុងគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឲ្យឃើញពិរុទ្ធភាពនៃជនល្មើ និងផ្តន្ទាទោសជននោះតាមច្បាប់កំណត់ ឲ្យសមស្របទៅនិងអំពើរបស់ខ្លួនដែលបានព្រឹត្ត ដែលបង្ករឲ្យមានព្យាសនៈកម្មទៅលើជនរងគ្រោះ និង ផលប្រយោជន៍សាធារ

[3] មាត្រា៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[4] មាត្រា១៣១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
[5] មាត្រា៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ណៈនៃសង្គមជាតិ។ ការចោទប្រកាន់របស់ព្រះរាជអាជ្ញា គឺជានីតិវិធីមួយដែលព្រះរាជអាជ្ញាមានអានុភាព និង សមត្ថកិច្ចពេញលេញទៅលើយុត្តាធិការស៊ើបសួរ និងជំនុំជម្រះនៃរឿងក្តីព្រហ្មទណ្ឌ។ ព្រះរាជអាជ្ញាមុននិងធ្វើការចោទប្រកាន់ ចាំបាច់ត្រូវតែធ្វើការត្រួតពិនិត្យលើ **(ផ្នែកទី១) លក្ខខណ្ឌនៃការចោទប្រកាន់** បន្ទាប់មកទៀតបានព្រះរាជអាជ្ញាធ្វើ **(ផ្នែកទី២) ការសម្រេចចោទប្រកាន់** ដើម្បីឲ្យកាន់តែមានភាពច្បាស់លាស់នៅក្នុងនីតិវិធីនេះ។

## ផ្នែកទី១៖ លក្ខខណ្ឌនៃការចោទប្រកាន់

ដើម្បីឲ្យរឿងក្តីព្រហ្មទណ្ឌ ទទួលបាននូវភាពច្បាស់លាស់ក្នុងការចោទប្រកាន់ ទៅតាមនីតិវិធីព្រហ្មទណ្ឌនោះព្រះរាជអាជ្ញាត្រូវធ្វើ (១) ការពិនិត្យលើលក្ខខណ្ឌ និង (២) សិទ្ធិក្នុងការសម្រេចរបស់ព្រះរាជអាជ្ញា។

### ១. ការពិនិត្យលើលក្ខខណ្ឌ

នៅក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា ចាំបាច់ត្រូវតែធ្វើការត្រួតពិនិត្យទៅលើប្រភេទនៃបទល្មើសព្រហ្មទណ្ឌជាមុនសិន មុននិង ធ្វើការចោទប្រកាន់។ ដែលក្នុងនោះរួមមានបទល្មើសបីប្រភេទគឺ (១.)បទល្មើសជាបទលហុ ព្រមទាំង(២.)បទល្មើសជាបទមជ្ឈិម និង(៣.)បទល្មើសជាបទឧក្រិដ្ឋ។

#### ១.១.បទល្មើសជាបទលហុ

បទល្មើសជាបទលហុ នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារ មានរយៈពេលក្រោមឬ ស្មើនឹង ៦ថ្ងៃដោយទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។ ម្យ៉ាងវិញទៀតបទល្មើសគឺជាបទលហុ កាលបើបទល្មើសនោះត្រូវផ្តន្ទាទោសត្រឹមតែជាការពិន័យជាប្រាក់តែប៉ុណ្ណោះ។[6] នៅក្នុងនីតិវិធីព្រហ្មទណ្ឌ ដោយសារតែការកម្រិតទោសមានលក្ខខណៈស្រាលនោះ ព្រះរាជអាជ្ញាបន្ទាប់ពីខ្លួនបានទទួលពាក្យបណ្តឹងហើយបានធ្វើការស៊ើបអង្កេត និងស្រាវជ្រាវមានភាពច្បាស់លាស់រួចរាល់ ព្រះរាជអាជ្ញាអាចបញ្ជូនរឿងនេះទៅធ្វើការជំនុំជម្រះផ្ទាល់ នៅមុខសាលាដំបូងនៃសាលាជម្រះក្តីដែលតុលាការធ្វើការកោះហៅ ។[7]

ហើយបទល្មើសជាបទលហុដែលមានក្នុងច្បាប់សារធាតុព្រហ្មទណ្ឌ ឬក្រមព្រហ្មទណ្ឌមានដូចជា៖

- បទធ្វើឲ្យខូចខាតប័ណ្ណប្រកាសនិងសេចក្តីជូនដំណឹងជាផ្លូវការ (មាត្រា ៤២០)
- បទធ្វើឲ្យខូចខាតស្រាល (មាត្រា ៤១៨)

[6] កថាខណ្ឌទី២ មាត្រា៤៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

[7] កថាខ័ណ្ឌទី១ មាត្រា៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

- បទហៅអ្នកដំទៃនៅទីសាធារណៈ (មាត្រា ២៩៨)
- បទស្រវឹងជាក់ស្តែង (មាត្រា ២៩៧)

ហើយក៏នូវមានបទល្មើសមួយចំនួនទៀត ក៏ជាបទល្មើសលហុផងដែរ។

ថ្វីត្បិតតែករណីនេះ ជាបទល្មើសលហុកក៏ដោយ ក៏ជនជាប់ចោទអាចមានសិទ្ធិក្នុងការពឹងពាក់មេធាវីឲ្យធ្វើការពារក្តីរបស់ខ្លួន ឬអមខ្លួនបានផងដែរនៅពេលតុលាការបានធ្វើការកោះហៅតាមដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។[8]

### ១.២.បទល្មើសជាបទមជ្ឈិម

នៅក្នុងករណីបទល្មើសជាបទមជ្ឈិម ដោយយោងទៅលើក្រមនីតិវិធីព្រហ្មទណ្ឌ បន្ទាប់ពីព្រះរាជអាជ្ញាបានទទួលនូវពាក្យបណ្ដឹងពីជនរងគ្រោះ ឬ ពីមន្ត្រីនគរបាលយុត្តិធម៌ ហើយធ្វើការពិនិត្យស្រាវជ្រាវ និង ស៊ើបអង្កេតចប់សព្វគ្រប់ហើយនោះ ព្រះរាជអាជ្ញាអាចធ្វើតាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាម[9] (បទល្មើសជាបទមជ្ឈិមជាក់ស្តែង) ឬធ្វើតាមនីតិវិធីនៃការបញ្ជូនរឿងទៅស៊ើបសួរ[10] (ករណីបទល្មើសជាបទមជ្ឈិមដែលមានលក្ខខណៈស្មុកស្មាញ ឬ សំណុំរឿងមិនទាន់គ្រប់គ្រាន់ក្នុងការបញ្ជូនទៅជំនុំជម្រះ)។ ដោយមូលហេតុបទមជ្ឈិម ជាប្រភេទបទល្មើសដែលមានការដាក់ទោសឲ្យជាប់ពន្ធនាគារ មានរយៈពេលលើសពី ៦ថ្ងៃ និងក្រោមឬស្មើនឹង ៥ឆ្នាំនិងអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។

ម្យ៉ាងវិញទៀត នៅក្នុងករណីបទល្មើសមជ្ឈិមដែលមានលក្ខណៈស្មុកស្មាញ មិនមានភស្តុតាងគ្រប់គ្រាន់ ឬជនដែលទទួលរងនូវការចោទប្រកាន់ស្ថិតក្នុងស្ថានភាពជាអញ្ញាតជន ដែលគេអាចកំណត់ម្យ៉ាងទៀតថា សំណុំរឿងមិនទាន់មូល ហើយព្រះរាជអាជ្ញាយល់ឃើញថាត្រូវបើកការស៊ើបសួរជាការគួរ និង ដើម្បីបញ្ចៀសនៃកំហុសក្នុងការចោទប្រកាន់ (ដោយសារតែកំណត់ធាតុផ្សំបទល្មើសមិនច្បាស់លាស់) ខ្លួនអាចសម្រេចក្នុងការចោទប្រកាន់ដោយបញ្ជូនសំណុំរឿងនោះមកធ្វើការស៊ើបសួរតាមរយៈ **ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ**។ ហើយចំពោះបទមជ្ឈិមដែលមាន ក្នុងក្រមព្រហ្មទណ្ឌ មានបទល្មើសមួយចំនួនដូចជា៖

- បទល្មើសឆបោក (មាត្រា ៣៧៧ នៃក្រមព្រហ្មទណ្ឌ)
- បទល្មើសរំលោភលើទំនុកចិត្ត (មាត្រា ៣៩១ នៃក្រមព្រហ្មទណ្ឌ)

---

[8] កថាខ័ណ្ឌទី៤ មាត្រា៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[9] មាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[10] មាត្រា៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

- បទល្មើសទទួលផលចោរកម្ម (មាត្រា ៣៩៩ នៃក្រមព្រហ្មទណ្ឌ)
- បទល្មើសគំរាមកំហែងហែកកេរ្តិ៍ (មាត្រា៣៧២ នៃក្រមព្រហ្មទណ្ឌ)...។

ដោយឡែកនូវក្នុងករណី ដែលមានភាពមិនច្បាស់លាស់ អំពីអាយុរបស់អនីតិជនដែលជាប់សង្ស័យនោះ ព្រះរាជអាជ្ញាគម្បីធ្វើការស៊ើបអង្កេតបន្ថែម ដើម្បីស្វែងរកការពិតនូវអាយុពិតប្រាកដរបស់អនីតិជនដែលជាប់សង្ស័យនោះ។ ហើយនៅក្នុងករណីដែលព្រះរាជអាជ្ញារកមិនឃើញ នូវអាយុពិតប្រាកដរបស់អនីតិជន ព្រះរាជអាជ្ញាអាចធ្វើជាដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ទៅឲ្យចៅក្រមស៊ើបសួរ ដើម្បីស៊ើបសួរពីបញ្ហាអាយុរបស់អនីតិជននោះ។

ពីព្រោះថាស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ ព្រះរាជអាជ្ញាត្រូវតែធ្វើការបញ្ជូនរឿងឲ្យស៊ើបសួរ អំពីអាយុពិតប្រាកដរបស់អនីតិជនជាមុនសិន មុននិងសម្រេចនៅក្នុងការចោទប្រកាន់ ដើម្បីជៀសវាងធ្វើការចោទប្រកាន់ ដោយរំលោភទាក់ទងទៅនិង ស្ថានភាពរបស់អនីតិជន ដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌ ដោយអនីតិជនក្រោមអាយុ ១៤ ឆ្នាំមិនអាចទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។[11] មួយវិញទៀត ប្រសិនបើជនរងគ្រោះមិនសុខចិត្ត និងការតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញាពីបទមជ្ឈិមនោះ ហើយដែលខ្លួនយល់ឃើញថា ការតម្កល់រឿងនោះមិនត្រឹមត្រូវនិង ធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ខ្លួន គាត់អាចដាក់ពាក្យបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ ចៅក្រមស៊ើបសួរបានផងដែរ។

### ១.៣.បទល្មើសជាបទឧក្រិដ្ឋ

នៅក្នុងករណីបទល្មើសជាបទឧក្រិដ្ឋនោះ ព្រះរាជអាជ្ញាត្រូវតែបញ្ជូនរឿងទៅធ្វើការស៊ើបសួរដោយខានពុំបានឡើយ។[12] ការបើកការស៊ើបសួរត្រូវបានធ្វើឡើងតាមរយៈ **ការចេញជាដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរ** នៅស្ថាប័នចៅក្រមស៊ើបសួរ។[13] ព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់ដោយមិនបានឆ្លងកាត់នូវនីតិវិធីនៃការស៊ើបសួរ ទៅចំពោះមុខចៅក្រមជំនុំជម្រះបានឡើយ។ ដោយហេតុបទល្មើសឧក្រិដ្ឋគឺ ជាបទល្មើសដែលមានលក្ខណៈនៃការផ្តន្ទាទោស មានភាពធ្ងន់ធ្ងរ ទើបច្បាប់ធ្វើការទាមទារឲ្យមានការកំណត់ ឲ្យបានច្បាស់លាស់អំពីពិរុទ្ធភាពដែលត្រូវចោទប្រកាន់ និងដើម្បីជៀសវាងនូវ ការជំនុំជម្រះធ្វើឡើងដោយមានការភាន់ច្រឡំដែលធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅដល់ជនជាប់ចោទ។ រាល់គ្រប់បទល្មើសទាំងឡាយដែលជាប្រភេទ នៃបទឧក្រិដ្ឋ គឺ

[11] មាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

[12] មាត្រា៤៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[13] មាត្រា៤៤ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ជាបទល្មើសទាំងឡាយណាដែលមានអប្បរិមានៃទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ៣០ឆ្នាំ និង អាតិបរមានៃទោសដាក់ពន្ធនាគារអស់មួយជីវិត។[14]

បទឧក្រិដ្ឋនេះទៀតសោត ត្រូវធ្វើការស៊ើបសួរជាមុន ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ ធ្វើការស៊ើបសួរទាំងភស្តុតាងដោះបន្ទុក និងភស្តុតាងដាក់បន្ទុក ដើម្បីធ្វើការត្រួតពិនិត្យដោយជាក់លាក់ និងស្វែងឲ្យដឹងពីការពិត ព្រមទាំងបង្ហាញឲ្យមានភាពច្បាស់លាស់ពីការជំនុំជម្រះ របស់ប្រព័ន្ធយុត្តាធិការតុលាការប្រកបដោយភាពយុត្តិធម៌។ ជារួមព្រះរាជអាជ្ញាមានកាតព្វកិច្ចធ្វើដីកា (ចេញដីកា) នេះដោយស្នើ (ប្តឹង) ឲ្យធ្វើការស៊ើបសួរក្នុងករណីមានបទល្មើសដូចខាងក្រោម៖

- បទឃាតកម្ម (មាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ)
- បទឃាតកម្មគិតទុកជាមុន (មាត្រា២០០ នៃក្រមព្រហ្មទណ្ឌ)
- បទទារុណកម្មនិង អំពើឃោរឃៅ (មាត្រា២០១ នៃក្រមព្រហ្មទណ្ឌ)
- បទរំលោភសេពសន្ថវៈ (មាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ) និង មានបទឧក្រិដ្ឋមួយចំនួនទៀត ដែលតម្រូវឲ្យសមត្ថកិច្ច ព្រះរាជអាជ្ញាធ្វើការចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ នៅចៅក្រមស៊ើបសួរ។

បន្ទាប់ពីព្រះរាជអាជ្ញា បានធ្វើការត្រួតពិនិត្យលើប្រភេទនៃបទល្មើសព្រហ្មទណ្ឌរួចមកព្រះរាជអាជ្ញានូវមានសិទ្ធិមួយទៀតជាពិសេសនោះគឺយើងអាចនិយាយបានថាជា (២) សិទ្ធិក្នុងការចោទប្រកាន់របស់ព្រះរាជអាជ្ញា។

## ២.សិទ្ធិក្នុងការចោទប្រកាន់របស់ព្រះរាជអាជ្ញា

ជាគោលការណ៍ ព្រះរាជអាជ្ញាមានសិទ្ធិពេញលេញក្នុង ការចោទប្រកាន់ ឬមិនចោទប្រកាន់លើបទល្មើសព្រហ្មទណ្ឌ។ ប៉ុន្តែ ដោយហេតុថា ព្រះរាជអាជ្ញាស្ថិតនៅក្នុងអង្គដែលមានឋានានុក្រម ដូច្នេះព្រះរាជអាជ្ញាត្រូវធ្វើតាមបង្គាប់របស់ថ្នាក់លើ តាមឋានានុក្រមរបស់ខ្លួន ដែលបង្គាប់ឲ្យធ្វើការចោទប្រកាន់ទៅលើអំពើអ្វីមួយ ទោះបីព្រះរាជអាជ្ញាខ្លួនឯងយល់ថាមិនត្រូវចោទប្រកាន់ក៏ដោយ។ គួរបញ្ជាក់ផងដែរថា មានតែការចោទប្រកាន់តែប៉ុណ្ណោះ ដែលព្រះរាជអាជ្ញាអនុវត្តតាម ប៉ុន្តែប្រសិនបើមានអធិបញ្ញាមិនឲ្យចោទប្រកាន់ ព្រះរាជអាជ្ញាមិនអនុវត្តតាមនោះទេ។

នៅក្នុងករណីដែល ព្រះរាជអាជ្ញាយល់ឃើញថាអំពើដែលត្រូវចោទប្រកាន់នោះ មានធាតុផ្សំមិនគ្រប់គ្រាន់ ឬមានការផុតអាជ្ញាយុកាល ព្រះរាជអាជ្ញាធ្វើនីតិវិធីព្រហ្មទណ្ឌមួយទៀតនោះគឺ ការតម្កល់រឿងទុកឥតចាត់ការ តាមមាត្រា ៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយត្រូវតែមានសំអាងហេតុ

[14] មាត្រា៤៦ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

និង សំអាងច្បាប់។ ការតម្កល់រឿងទុកឥតចាត់ការនោះ មិនមានអានុភាពអាជ្ញាអស់ជំនុំនោះទេ ពោល គឺប្រសិនបើនៅថ្ងៃក្រោយព្រះរាជអាជ្ញាយល់ឃើញថា មានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ នោះ ព្រះរាជអាជ្ញាអាចសើរើធ្វើការចោទប្រកាន់បានលើកលែងតែ សំណុំរឿងនោះផុតអាជ្ញាយុកាលនៃបទល្មើស[15] តែប៉ុណ្ណោះទើបមិនអាចធ្វើការចោទប្រកាន់បាន។

បន្ទាប់ពីព្រះរាជអាជ្ញាយល់ឃើញថា បទល្មើសនោះជាប្រភេទបទឧក្រិដ្ឋ ឬជាបទមជ្ឈិម ដែលមានលក្ខណៈស្មុកស្មាញនោះព្រះរាជអាជ្ញា និង សម្រេចចោទប្រកាន់ដើម្បីស្វែងរកភាពយុត្តិធម៌ជូនជនរងគ្រោះ និង ធ្វើនីតិវិធីរបស់ខ្លួនយ៉ាងណាដើម្បីកុំអោយជនដែលបានប្រព្រឹត្តបទល្មើសដែលច្បាប់ព្រហ្មទណ្ឌបានកំណត់ រួចផុតពីទោសកំហុសដែល ខ្លួនបានធ្វើ ។

## ផ្នែកទី២៖ ការសម្រេចចោទប្រកាន់

នៅពេលដែលព្រះរាជអាជ្ញាមានភស្តុតាងធ្ងន់ល្មមអាចជឿបានថា ជនសង្ស័យអាចនិងប្រព្រឹត្តអំពើនោះមែន ព្រះរាជអាជ្ញានិងធ្វើការចោទប្រកាន់។ ការចោទប្រកាន់ធ្វើឡើងតាមរយៈការជ្រើសរើសនៃនីតិវិធី (១) **ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់** នៅក្នុងករណីបទល្មើសមួយចំនួនទៀតអាចធ្វើតាមនីតិវិធី (២) **ការបង្គាប់ឲ្យបង្ហាញខ្លួនភ្លាម** ប៉ុន្តែប្រសិនបើសំណុំរឿងនោះជាបទល្មើសឧក្រិដ្ឋ ឬបទល្មើសមជ្ឈិមដែលមានលក្ខណៈស្មុកស្មាញ នោះព្រះរាជអាជ្ញាអាច (៣) **បើកការស៊ើបសួរ**។

### ១. ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

នៅក្នុងដំណាក់កាលនេះ កាលបើព្រះរាជអាជ្ញាយល់ឃើញថា សំណុំរឿននៃនីតិវិធីអាចបញ្ជូនទៅតុលាការ ជំនុំជម្រះដោយមិនចាំបាច់មានការស្រាវជ្រាវផ្សេងទៀតទេ។ ស្ថានភាពនៃសំណុំរឿងនីតិវិធីនេះត្រូវបានសន្មត់ជា ដំបូងថា គេបានសង្ស័យទៅលើបុគ្គលម្នាក់ ឬច្រើនអ្នកដែលបានកំណត់អត្តសញ្ញាណ ហើយត្រូវបានចោទប្រកាន់ពីបទល្មើសមួយ ឬច្រើន ដែលបទល្មើសទាំងនោះ ជាប្រភេទបទល្មើសមជ្ឈិម ឬបទលហុ។ ចំពោះបទល្មើសជាបទមជ្ឈិម ដែលព្រះរាជអាជ្ញាយល់ឃើញថា មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដើម្បីឲ្យតុលាការធ្វើការវិនិច្ឆ័យសេចក្ដីលើរឿងនេះបាន ព្រះរាជអាជ្ញា និង ប្រើនីតិវិធីនៃការចោទប្រកាន់នេះ។ ចំណែកឯបទល្មើស ជាបទលហុវិញ ព្រះរាជអាជ្ញាត្រូវតែជ្រើសរើសយកនីតិវិធីនៃការចោទប្រកាន់នេះដែរ (មាត្រា៤៩នៃក្រមនីតិវិធីព្រហ្ម

[15] **អាជ្ញាយុកាលនៃបទល្មើស** គឺជារយៈពេលសម្រាប់បណ្ដឹងអាជ្ញា ពោលគឺផុតរយៈពេលនេះព្រះរាជអាជ្ញាមិនអាចធ្វើបណ្ដឹងអាជ្ញាបានទេ (មាត្រា៧ និង មាត្រា១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧)។

ទណ្ឌឆ្នាំ២០០៧) ហើយក៏មិនមានបទប្បញ្ញត្តិផ្សេង ដែលអនុញ្ញាតឲ្យតំណាងអយ្យការបើកការស៊ើបសួរ ឬប្រើនីតិវិធីនៃការបង្ហាញខ្លួនភ្លាមចំពោះបទលហុនោះទេ។

**១.១.នីតិវិធីនៃការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់**

ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់នេះគឺធ្វើឡើងតាមរយៈ **ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់** ទៅយុត្តាធិការជំនុំជម្រះ និងបង្គាប់ឲ្យជនជាប់ចោទចូលបង្ហាញខ្លួននៅសាលាដំបូង។ តាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់នេះ ដោយត្រូវចុះនូវអត្តសញ្ញាណរបស់ជនជាប់ចោទ សេចក្តីសង្ខេបអង្គហេតុ និងអត្ថបទច្បាប់ដែលបានកំណត់ និងបង្ក្រាបបទល្មើស និងឈ្មោះនៃបទល្មើសដែលត្រូវបានចោទប្រកាន់ផងដែរ។ ព្រមទាំងមានការចង្អុលបង្ហាញ ប្រាប់មន្ទីតុលាការដែលទទួលបណ្តឹង ទីកន្លែងកាលបរិច្ឆេទ និងម៉ោងពេលនៃសវនាការ ហើយជាចុងក្រោយនៃដីកានេះ ត្រូវបញ្ជាក់ឲ្យបានច្បាស់ថាជនជាប់ចោទអាចសុំជំនួយពីមេធាវីឲ្យអមខ្លួនបាន។[16] លក្ខខណៈទម្រង់នៃដីកាដែលមានចុះកាលបរិច្ឆេទ ទីកន្លែងកំណើតរបស់ជនជាប់ចោទ ត្រូវតែមានការចុះកាលបរិច្ឆេទ និង ចុះហត្ថលេខារបស់ព្រះរាជអាជ្ញា។

ដូចដែលមានចែងនៅក្នុងមាត្រា៤៦ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់) នៃក្រមនេះ ស្រាប់ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់គឺជាបញ្ជា ដល់ជនជាប់ចោទឲ្យចូលបង្ហាញខ្លួន នៅតុលាការជាន់ដំបូងដែលសម្រេចអំពីរឿងក្តីព្រហ្មទណ្ឌ។[17] យោងតាមមាត្រា៤៥៧ ៖ រយៈពេលដែលត្រូវគោរព រវាងការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដល់ជនជាប់ចោទ និង ថ្ងៃដែលត្រូវកំណត់ឲ្យចូលបង្ហាញខ្លួន នៅមុខតុលាការត្រូវកំណត់ដូចតទៅ៖

- ១៥ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការតុលាការជាន់ដំបូង។
- ២០ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ។
- ២ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជា។
- ៣ខែ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងដទៃផ្សេងទៀត។

ហេតុដូចនេះ ជាទូទៅប្រសិនបើមិនមានការគោរពនូវលក្ខខណ្ឌ ទាក់ទងនិងរយៈពេលដូចបានកំណត់ខាងលើនោះទេ បើតុលាការយល់ឃើញថា ការមិនគោរពនូវវិធាននៃរយៈពេលនេះ បានធ្វើឲ្យប៉ះពាល់ផលប្រយោជន៍ដល់បុគ្គលដែលជាប់ចោទ តុលាការអាច និងប្រកាសអំពីមោឃៈភាពទាក់ទងទៅ នឹង ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ (មាត្រា ៤៩២ នៃកថាខណ្ឌទី១)។ ជាការប៉ះ

[16] មាត្រា ៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[17] មាត្រា ៤៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ប៉ូវឡើងវិញ តុលាការអាចបង្គាប់ឲ្យចេញដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ជាថ្មីម្ដងទៀត (មាត្រា៤៩១ កថាខណ្ឌទី២)។ ការបញ្ជូនដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ទៅដល់ជនជាប់ចោទ អាចធ្វើឡើងដោយ ព្រះរាជអាជ្ញា ឬអាជ្ញាសាលា ឬមេឃុំ/ចៅសង្កាត់ប្រសិនបើជនជាប់ចោទ បដិសេធមិនព្រមទទួលដីកា និង ជាចុងក្រោយការប្រគល់ដីកា អាចធ្វើដោយ ក្រឡាបញ្ជី តាមផ្លូវរដ្ឋបាល ដោយប្រធានពន្ធនាគារឬ អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ហើយវិធីនៃការប្រគល់ ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ដល់ជនជាប់ចោទ ដោយមានមាត្រា ៥៥៨ និងបន្តបន្ទាប់ពោលគឺ គន្ថីទី៧ មាតិការទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ទោះបីជានីតិវិធីនៃការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ជាយន្តការដ៏ឆាប់រហ័ស ដែលមិនទាមទារឲ្យមានការអូសបន្លាយរយៈពេលវែងនៃនីតិវិធីក៏ដោយ ក៏មិនមែនមានន័យថា នៅក្នុងកិច្ចដំណើរការក្នុងពេលសវនាកា មិនមានការចូលរួមពីភាគីពាក់ព័ន្ធនោះទេ។ ដូច្នេះទន្ទឹម និងការចេញដីកាកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ទៅលើជនជាប់ចោទ ព្រះរាជអាជ្ញាក៏ត្រូវកោះហៅភាគីដែលជាប់ពាក់ព័ន្ធដូចជា ជនរងគ្រោះ សាក្សី អ្នកបកប្រែ និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី តាមព័ត៌មានដែលផ្ដល់ឲ្យដោយជនជាប់ចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណី។[18]

### ១.២.អានុភាពនៃការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

ដីកាកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ដែលចេញដោយព្រះរាជអាជ្ញា មានអានុភាពជាបណ្ដឹងនៃការចោទប្រកាន់ ទៅចំពោះមុខយុត្តាធិការជំនុំជម្រះផ្ទាល់តែម្ដង ដោយមានកម្មវត្ថុពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឲ្យឃើញពិរុទ្ធភាពនៃជនជាប់ចោទ និងស្នើសុំឲ្យចៅក្រមជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ជាធរមាន។ ហើយក្នុងក្របខ័ណ្ឌនៃការអនុវត្តដីកានេះ មិនមានអានុភាពបញ្ជាដល់ កម្លាំងសាធារណៈទាំងអស់ឲ្យធ្វើការនាំខ្លួន ឬចាប់ខ្លួនបុគ្គលនោះនាំយកមកបង្ហាញខ្លួននៅចំពោះមុខយុត្តាធិការជំនុំជម្រះនោះទេ។ វិធាននៃការចោទប្រកាន់ខាងលើនេះបានធានាការពារដល់សិទ្ធិសេរីភាពរបស់ជនជាប់ចោទ។ ហេតុនេះ បុគ្គលជាប់ចោទអាចចូលទៅបង្ហាញខ្លួន នៅចំពោះមុខតុលាការដោយសេរី និង ឯករាជ្យភាព។[19]

## ២. ការបង្ហាញខ្លួនភ្លាម

ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ជានីតិវិធីមួយក្នុងចំណោមនីតិវិធីទាំងបី នៃការចោទប្រកាន់ខាងបទល្មើសព្រហ្មទណ្ឌរបស់ព្រះរាជអាជ្ញា ដែលអាចនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាម នៅចំពោះមុខតុលាការជាន់ដំបូង។ នីតិវិធីនេះបញ្ញត្តិឡើងដើម្បីជម្រុញដល់ដំណើរការរឿងក្ដី

[18] មាត្រា ២៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[19] មាត្រា ៣០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ឲ្យមានភាពឆាប់រហ័សជៀសវាងការកកស្ទះ ប៉ុន្តែទោះជាយ៉ាងណាការអនុវត្តការបង្ហាញខ្លួនភ្លាម ត្រូវតែគោរពនូវលក្ខខណ្ឌ នៃនីតិវិធីដែលត្រូវអនុវត្តក៏ដូចជាការបង្កើតឲ្យមានអានុភាពផងដែរ។ លក្ខខណ្ឌនៃ នីតិវិធីការបង្ហាញខ្លួនភ្លាមនេះ ត្រូវបានបញ្ញត្តិនៅក្រមនីតិវិធីព្រហ្មទណ្ឌ ដែលធ្វើឡើង ចំពោះ បទល្មើសជាប្រភេទបទមជ្ឈិមជាក់ស្តែង ហើយមានការផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១ឆ្នាំ និងយ៉ាងច្រើន ៥ឆ្នាំ ព្រមទាំងជនជាប់ចោទនោះជានីតិជន ហើយរឿងក្តីនោះមានលក្ខណៈ គ្រប់គ្រាន់ល្មមជំនុំជម្រះបាន។[20]

បទល្មើសជាបទមជ្ឈិមជាក់ស្តែង៖ បើពិនិត្យមើលមាត្រា៨៧ ដដែល ត្រង់ចំណុចទី១ នេះ ច្បាប់បានប្រើពាក្យថា បទល្មើសជាបទល្មើសជាក់ស្តែង ហើយបានចង្អុលបង្ហាញទៅមាត្រា៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) និងមាត្រា៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) ប៉ុន្តែនីតិវិធីនៃការបង្ហាញខ្លួនភ្លាមអនុវត្តបានតែចំពោះបទល្មើសដែលជាបទមជ្ឈិមជាក់ស្តែងតែប៉ុណ្ណោះ ព្រោះនឹងមានបង្ហាញនៅចំណុចទី២ បន្ទាប់ដែលបានកំណត់ពីការផ្តន្ទាទោសដាក់ពន្ធនាគារ។

ជនជាប់ចោទជានីតិជន៖ មានន័យថាកាលដែលជនជាប់ចោទត្រូវបានដល់នីតិភាព ដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ។ ការកំណត់បែបនេះដើម្បីជៀសវាងមាន ការប៉ះពាល់សិទ្ធិរបស់អនីតិជន ដោយហេតុថានីតិវិធីនេះមានការជំនុំជម្រះលឿន ហើយបើពុំបានកំណត់ជនជាប់ចោទជានីតិជនទេ នាំឲ្យមានផលប៉ះពាល់ទៅដល់សិទ្ធិរបស់អនីតិជននោះជាមិនខានឡើយ។ ចំណែកឯរឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន៖ ព្រះរាជអាជ្ញាត្រូវតែមានភស្តុតាង ឬមូលហេតុធ្ងន់ល្មមក្នុងការដាក់បន្ទុកដើម្បីធ្វើការចោទប្រកាន់ ព្រោះបើគ្មានភស្តុតាង ឬហេតុផលដ៏រឹងមាំក្នុងការដាក់បន្ទុកជនល្មើស នាំឲ្យតុលាការសម្រេចឲ្យរួចខ្លួន ជាហេតុធ្វើអោយព្រះរាជអាជ្ញាពុំអាចធ្វើការចោទប្រកាន់ជាថ្មីបានដោយសាគោលការណ៍អាជ្ញាអស់ជំនុំ។ ហើយការបង្ហាញខ្លួនភ្លាម ត្រូវបានធ្វើឡើងជាពីរដំណាក់កាលគឺ (២.១) ការបង្ហាញខ្លួនដើម្បីស៊ើបសួរ និង (២.២) ការបង្ហាញខ្លួនទៅជំនុំជម្រះ ដែលមានបរិយាយដូចខាងក្រោមនេះ៖

### ២.១.ការបង្ហាញខ្លួនដើម្បីស៊ើបសួរ

នៅពេលបញ្ចប់ការឃាត់ខ្លួន បុគ្គលដែលឃាត់ខ្លួនត្រូវបញ្ជូនដោយមានកម្លាំងការពារ ដើម្បីឲ្យចូលបង្ហាញខ្លួននៅចំពោះមុខព្រះរាជអាជ្ញា។ បន្ទាប់ពីទទួលបានកំណត់ហេតុ និងខ្លួនបុគ្គលដែល

[20] មាត្រា ៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

គេឃាត់ខ្លួនពីមន្ត្រីនគរបាលយុត្តិធ ឬជនរងគ្រោះ កាលបើសម្រេចប្រើនីតិវិធីឲ្យបង្ហាញខ្លួនភ្លាម ព្រះរាជអាជ្ញាត្រូវតែៈ

- ពិនិត្យ ឬសាកសួរអំពីអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនឲ្យខ្លួន
- ឲ្យដំណឹងដល់ជននោះអំពីរឿងរ៉ាវដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសព្រមទាំងអត្ថបទច្បាប់កំណត់ និងបង្ក្រាបបទល្មើស
- ទទួលស្តាប់ចម្លើយរបស់សាមីជន ប្រសិនបើជននោះចង់និយាយ
- ធ្វើកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម។

ដោយប្រាប់ទៅជននោះថា ក្រោមវិធានបង្គាប់បែបនេះ ជននេះនិងត្រូវជំនុំជម្រះតែម្តងដោយសាលាដំបូង ហើយមានសិទ្ធិទទួលជំនួយ ពីមេធាវីតាមការជ្រើសរើសដោយខ្លួនឯង ឬ តាមការចាត់តាំងឡើងដោយ អនុឡោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បន្ទាប់ពីទទួលបានការជ្រើសរើស ឬចាត់តាំងរួចហើយ មេធាវីត្រូវបានទទួលដំណឹងភ្លាម ហើយមានសិទ្ធិអាចពិនិត្យសំណុំរឿង និងទាក់ទងជាមួយជនជាប់ចោទបាន។[21]

ការឲ្យដំណឹងអំពីការបង្គារ ដែលធ្វើឡើងដោយកំណត់ហេតុ ស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម គឺជាដីកាកោះប្រគល់ឲ្យជនត្រូវចោទ ហើយដែលក្នុងខណៈនោះជនត្រូវចោទ បានទទួលឈ្មោះជា**ជនជាប់ចោទ។** ទម្រង់ទាំងនេះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ បើពុំនោះទេនីតិវិធីត្រូវទុកជាមោឃៈ។[22] ជនជាប់ចោទត្រូវបង្ខាំងទុកដោយកម្លាំងការពារ រហូតដល់ពេលសាមីខ្លួនចូលបង្ហាញខ្លួន នៅចំពោះមុខតុលាការដែលត្រូវបើកសវនាការនៅក្នុងថ្ងៃនោះតែម្តង។

### ២.២.ការបង្ហាញខ្លួនទៅជំនុំជម្រះ

នៅសាលាដំបូងដែលទទួលបណ្តឹងតាមកំណត់ហេតុ ត្រូវធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជនជាប់ចោទដំបូងគេបង្អស់ និងធ្វើរបាយការណ៍សង្ខេបរឿងរ៉ាវដែលបានចោទប្រកាន់ និងជាពិសេសត្រូវប្រាប់ដល់ជននេះ អំពីរយៈពេលដែលមានដើម្បីការពារខ្លួន។ ការទាមទារបែបនេះបង្ហាញឲ្យឃើញច្បាស់ថាជនជាប់ចោទពុំមានរយៈពេល ដើម្បីរៀបចំការពារខ្លួន ចាប់តាំងពីពេលទទួលដំណឹងអំពីការបង្គារ។ ប្រសិនបើជនជាប់ចោទ ត្រូវការរយៈពេលដើម្បីរៀបចំការពារខ្លួន ឬបើតុលាការយល់ឃើញថា រឿងក្តីនោះមិនទាន់អាចជំនុំជម្រះភ្លាមៗបានទេ នោះសំណុំរឿងត្រូវលើកសវនាការទៅជំនុំជម្រះនៅពេលក្រោយ។ សវនាការនេះ មិនអាចបើកក្នុងពេលចិរៈវេលាមិនឲ្យ

[21] មាត្រា៤៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[22] មាត្រា៤៨ កថាខណ្ឌទី៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

លើសពី ពីរសប្តាហ៍បានឡើយ។ ក្នុងរយៈពេលដែលរងចាំការបង្ហាញខ្លួន តុលាការត្រូវសម្រេចគួរឃុំខ្លួនជនជាប់ចោទដោយសាលក្រម ដែលមានបញ្ជាក់ពីសម្អាងហេតុ និងយោងអំពីមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន អនុឡោមតាមមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ រហូតដល់ពេលសវនាការ។ បន្ទាប់មក តុលាការត្រូវចេញដីកាសម្រេចឲ្យឃុំខ្លួនដោយយោងតាមអំណាចសាលក្រម។

កាលបើរយៈពេលពីរសប្តាហ៍ គិតពីថ្ងៃចូលទៅបង្ហាញខ្លួននៅតុលាការកន្លងផុតទៅ សាលក្រមលើអង្គសេចក្តីនៅមិនទាន់បានប្រកាស នោះការឃុំខ្លួនបណ្តោះអាសន្នត្រូវតែបញ្ឈប់ដោយពេញច្បាប់។ ការអនុវត្តនីតិវិធីនៃការបង្ហាញខ្លួនភ្លាម របស់ព្រះរាជអាជ្ញា មិនមានអានុភាពឲ្យសាលាដំបូងត្រូវតែប្រតិបត្តិនោះទេ ផ្ទុយទៅវិញតុលាការមានសេរីភាពវាយតម្លៃ លើស្ថានភាពនៃសំណុំរឿងនីតិវិធី និងអាចសន្និដ្ឋានជាយថាហេតុ កាលបើលក្ខខណ្ឌនៃមាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានបំពេញទេ ឬក៏រឿងក្តីនេះមានភាពស្មុគស្មាញ តម្រូវជាចាំបាច់ឲ្យធ្វើការស្រាវជ្រាវឲ្យបានជ្រាលជ្រៅបន្ថែម តុលាការត្រូវបញ្ជូនរឿងនោះទៅព្រះរាជអាជ្ញាដើម្បីបើកការស៊ើបសួរ។ ជនជាប់ចោទត្រូវតែបង្ហាញខ្លួននៅថ្ងៃនោះតែម្តង នៅចំពោះមុខចៅក្រមស៊ើបសួរ បើពុំដូច្នេះទេជនជាប់ចោទត្រូវតែដោះលែង ឲ្យមានសេរីភាព ដោយឯកឯង។

ចំណែកឯភាគី ដែលត្រូវបានកោះហៅក្នុងករណី ចូលបង្ហាញខ្លួនភ្លាមត្រូវបានបញ្ញត្តិដោយមាត្រា ២៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលក្នុងនោះការកោះហៅ ត្រូវធ្វើឡើងដោយព្រះរាជអាជ្ញាឲ្យចូលរួមសវនាការនូវ៖ ជនរងគ្រោះ សាក្សី អ្នកបកប្រែ (បើចាំបាច់) អ្នកទទួលខុសត្រូវរដ្ឋប្បវេណីតាមព័ត៌មានដែលផ្តល់ឲ្យដោយជនជាប់ចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។ វិធីនៃការកោះហៅក្នុងករណីចូលបង្ហាញខ្លួនភ្លាម ត្រូវអនុវត្តដូចដែលបានចែងក្នុងគន្ថីទី៧ មាតិកាទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ប៉ុន្តែក្នុងករណីបន្ទាន់ ព្រះរាជអាជ្ញាអាចកោះហៅជនរងគ្រោះ សាក្សី អ្នកបកប្រែ និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី តាមគ្រប់មធ្យោបាយ ទោះបីដោយផ្ទាល់មាត់ក៏ដោយ។ ប្រសិនបើក្នុងករណីបទល្មើសជាបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលមានលក្ខណៈស្មុគស្មាញ ឬសំណុំរឿងមិនទាន់មូលគ្រប់គ្រាន់នោះព្រះរាជអាជ្ញា និង (៣) បើកការស៊ើបសួរ បន្ថែមទៀតផង។

### ៣. ការបើកការស៊ើបសួរ

ការវាយតម្លៃស្ថានភាពនៃសំណុំរឿង មុននឹងព្រះរាជអាជ្ញាសម្រេច អនុវត្តនីតិវិធីអាចធ្វើឲ្យព្រះរាជអាជ្ញា យល់ពីភាពចាំបាច់ក្នុងការស្រាវជ្រាវបន្ថែម ដើម្បីទទួលបានភស្តុតាងដែលអនុញ្ញាតឲ្យអនុវត្តបណ្តឹងអាជ្ញាដោយភាពត្រឹមត្រូវតាមផ្លូវច្បាប់ជាធរមាន។ ក្នុងទស្សនៈវិស័យនេះ ព្រះរាជអាជ្ញាមានផ្លូវពីរ គឺបន្តការស៊ើបអង្កេត និងធ្វើបណ្តឹងទៅចៅក្រមស៊ើបសួរ ទៅលើបទល្មើសព្រហ្ម

ទណ្ឌដែលខ្លួនទទួលបានពីគ្រប់ភាគីណាមួយ ។ ការប្តឹងទៅយុត្តាធិការស៊ើបសួរ ត្រូវធ្វើឡើងតាមរយៈ **ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។**

### ៣.១. លក្ខខណ្ឌនៃការបើកការស៊ើបសួរ

យោងតាមបទប្បញ្ញត្តិមាត្រា ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ញត្តិថា៉ **ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ។ ការស៊ើបសួរត្រូវបានបើក តាមដីកាបញ្ជូនរឿងឲ្យស៊ើបសួរដែលត្រូវប្តឹង ទៅចៅក្រមស៊ើបសួរ។ ការស៊ើបសួរត្រូវបានប្រឆាំងលើ បុគ្គលម្នាក់ ឬច្រើននាក់ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន** ៉។ ការបើកការស៊ើបសួរមានលក្ខណៈដាច់ខាត ក្នុងករណីដែលបទល្មើស នឹងអាចធ្វើការចោទប្រកាន់នោះ មានបទល្មើសមួយជាចម្បង ជាបទឧក្រិដ្ឋ ប៉ុន្តែចំពោះការបើកការស៊ើបសួរដែលមានលក្ខណៈមិនដាច់ខាតនោះទេ ចំពោះបទល្មើសដែលនឹងត្រូវចោទប្រកាន់ ជាបទមជ្ឈិម ឬបទលហុ។[23] ក្នុងករណីចុងក្រោយនេះ ស្ថាប័នអយ្យការអាចធ្វើការបើកការស៊ើបសួរ អាស្រ័យទៅលើស្ថានភាពនៃសំណុំរឿងនីតិវិធីជាអាទិ៍ នៅពេលដែលបុគ្គល ដែលជាប់ពាក់ព័ន្ធមិនបានកំណត់អត្តសញ្ញាណ និងមិនអាចកំណត់បានក្នុងពេលបច្ចុប្បន្ន។ មួយវិញទៀតព្រះរាជអាជ្ញា ក៏សម្រេចបើកការស៊ើបសួរផងដែរ កាលបើយល់ឃើញថា ភស្តុតាងដែលប្រមូលបានដោយការស៊ើបអង្កេតបឋម បន្តែអាចប្រមូលមកបាននោះ លុះត្រាតែប្រើអំណាចដោយបង្ខំ ឬបទល្មើសមជ្ឈិមដែលត្រូវពិគ្រោះនោះមានលក្ខណៈស្មុកស្មាញស៊ាំញ៉ាំ ដែលតម្រូវឲ្យមានការស្រាវជ្រាវយូរ និងប្រកបដោយភាពពិបាក។

ហើយចំពោះជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ក៏អាចដាក់ពាក្យបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[24] ទៅចំពោះមុខនៃចៅក្រមស៊ើបសួរបានផងដែរ នៅពេលដែលខ្លួនយល់ថាភាពអយុត្តិធម៌ ចំពោះអំពើណាមួយជាចាំបាច់ ក្នុងការដោះស្រាយនៃជីវិតរស់នៅរបស់ខ្លួន (ដោយនៅចំនុននេះនិង មានពន្យល់លម្អិតនៅត្រង់ផ្នែកទី២ នៃចំនុចទី២ ការដាក់ពាក្យបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ខាងមុខបន្ទាប់នៃមេរៀននេះ)។

### ៣.២.អានុភាពនៃការបើកការស៊ើបសួរ

គួរកត់សម្គាល់ថា: **ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ** អាចធ្វើឡើងប្រឆាំងនឹងបុគ្គលដែលស្គាល់ឈ្មោះ និងបុគ្គលមិនស្គាល់ឈ្មោះ (អញ្ញាតជន)។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ គឺជាលិខិតដែលបើកផ្លូវឲ្យមានបណ្តឹងអាជ្ញា ដែលព្រះរាជអាជ្ញាប្តឹងទៅចៅក្រមស៊ើបសួរ ដោយសុំឲ្យ

[23] មាត្រា១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[24] មាត្រា៥និងមាត្រា១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ស៊ើបសួររឿងរ៉ាវមួយជាកំណត់ ដែលត្រូវផ្តន្ទាទោសព្រហ្មទណ្ឌ។ ហេតុនេះហើយ ទើបដីកានេះទាមទារឲ្យគោរពយ៉ាងដាច់ខាត នូវលក្ខខណ្ឌមួយចំនួនជាអាទិ៍ ៖ ត្រូវមានបញ្ជាក់នូវសេក្តីសង្ខេបនៃអង្គហេតុ , ឈ្មោះបទល្មើស ,ចង្អុលបង្ហាញនូវបទប្បញ្ញត្តិ ដែលត្រូវពិគ្រោះ និងផ្តន្ទាទោស និងជាយថាហេតុ ឈ្មោះរបស់បុគ្គលដែលរងការស៊ើបសួរ ព្រមជាមួយគ្នាដីកានេះក៏ត្រូវចុះហត្ថលេខា និងកាលបរិច្ឆេទផងដែរ។ រីឯការចុះហត្ថលេខារបស់ចៅក្រម ដែលបានចេញសេចក្តីសម្រេចបើកការស៊ើបសួរនេះ ក៏ត្រូវបានធ្វើឡើងដើម្បីបញ្ជាក់ពីឆន្ទៈពិតរបស់អយ្យការក្នុងការចោទប្រកាន់។ បើពុំគោរពតាមលក្ខខណ្ឌខាងលើនេះទេ ជាហេតុនាំឲ្យមោឃៈកម្មនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះ។ ហើយនីតិវិធីដែលត្រូវគោរពជាដាច់ខាតនោះ ចាំបាច់ត្រូវតែមានដីកាសន្និដ្ឋានបញ្ជូនរឿងពីព្រះរាជអាជ្ញា ទៅកាន់ស្ថាប័ននៃចៅក្រមស៊ើបសួរ ពីព្រោះគ្មានការបើកការស៊ើបសួរណាមួយធ្វើឡើងដោយ គ្មានកិច្ចចោទប្រកាន់ពីព្រះរាជអាជ្ញាបានឡើយ។[25]

ម្យ៉ាងវិញទៀត នីតិវិធីនៃការបើកការស៊ើបសួរនេះក៏មានអានុភាព កាត់ផ្តាច់នូវអាជ្ញាយុកាលនៃបទល្មើស[26] ផងដែរ បានសេចក្តីថាគ្រប់កិច្ចចោទប្រកាន់របស់ព្រះរាជអាជ្ញា តាមរយៈ ការបើកការស៊ើបសួរ ឬ ការបង្ហាញខ្លួនភ្លាម ឬការបញ្ជូនខ្លួនទៅជំនុំជម្រះផ្ទាល់ក្តី ។ ដោយហេតុថា បទល្មើសព្រហ្មទណ្ឌដែលជនល្មើសបានប្រព្រឹត្ត អាជ្ញាយុកាលនៃបទល្មើសគឺចាប់ផ្តើមពីពេលដែលប្រព្រឹត្តបទល្មើស ហើយនៅពេលដែលមានកិច្ចចោទប្រកាន់ពីព្រះរាជ្ញាទៅកាន់ស្ថាប័ស៊ើបសួរ ឬចៅក្រមជំនុំជម្រះ នោះត្រូវបានកាត់ផ្តាច់នូវអាជ្ញាយុកាលនៃបទល្មើស។ ហើយរាល់ការបញ្ចប់កិច្ចចោទប្រកាន់ ឬកិច្ចស៊ើបសួរនីមួយៗ នាំអោយចាប់គិតថិរវេលាថ្មីអាជ្ញាយុកាលនៃបទល្មើស។[27] ទន្ទឹមនឹងនេះ សំណុំរឿងដែលត្រូវបានចោទប្រកាន់ក៏ត្រូវបានផ្ទេរសមត្ថកិច្ច ទៅកាន់ចៅក្រមស៊ើបសួរ ដើម្បីធ្វើការស៊ើបសួរផងដែរ។[28]

[25] មាត្រា១២៤ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[26] មាត្រា១១ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[27] មាត្រា១១ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[28] មាត្រា៤៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

# ជំពូកទី២

# ការស៊ើបសួរ

ការស៊ើបសួរ គឺធ្វើឡើងបន្ទាប់ពីព្រះរាជអាជ្ញាបានបញ្ជូនសំណុំរឿងព្រហ្មទណ្ឌ មកកាន់ស្ថានប័ននៃចៅក្រមស៊ើបសួរ ដើម្បីធ្វើការស្រាវជ្រាវ និងពិនិត្យលើរឿងក្តីដែលបញ្ជូនមក ឲ្យទទួលបាននូវភាពយុត្តិធម៌សម្រាប់ភាគីដែលពាក់ព័ន្ធ។ ប៉ុន្តែមុននិងធ្វើការស៊ើបសួរ ប្រធានតុលាការនៃសាលាដំបូងត្រូវតែធ្វើការកំណត់អោយបានច្បាស់អំពី (ផ្នែកទី១) ការចាត់តាំង កាបែងចែក និងការដកហូតសំណុំរឿង បន្ទាប់មកទៀតចៅក្រមត្រូវតែធ្វើ (ផ្នែកទី២) ការត្រួតពិនិត្យលើលក្ខខណ្ឌនៃការស៊ើបសួរ ក្រោយពីបានត្រួតពិនិត្យរួចរាល់ហើយចៅក្រមស៊ើបសួរត្រូវតែ (ផ្នែកទី៣) ធ្វើការស្រាវជ្រាវ ព្រមទាំងចេញនូវ (ផ្នែកទី៤) វិធានការនិរន្តរាយ និង នីតិវិធីចុងក្រោយត្រូវតែជានីតិវិធីនៃ (ផ្នែកទី៥) ការបិទការស៊ើបសួរ។

## ផ្នែកទី១៖ ការចាត់តាំង ការបែងចែក និង ការដកហូតសំណុំរឿង

ចៅក្រមស៊ើបសួរ គឺជាចៅក្រមវិជ្ជាជីវៈហើយគាត់និងក្លាយទៅជាចៅក្រមស៊ើសួរ តាមការតែងតាំងបំពេញមុខងារ តាមសេចក្តីសម្រេចមួយរបស់ប្រធានតុលាការខេត្ត ឬរាធានីដើម្បីធ្វើការស៊ើបសួរលើរឿងក្តីព្រហ្មទណ្ឌណាមួយ។

### ១.ការចាត់តាំង និង ការបែងចែកសំណុំរឿង

កាលណាបើមានបញ្ហា ដែលបណ្តាលមកពីការឈប់សម្រាក ដោយមានជម្ងឺ ឬដោយមានមូលហេតុដ៏ទៃទៀតដែលជាមូលហេតុ បណ្តាលឲ្យចៅក្រមស៊ើបសួរណាមួយពុំអាចបំពេញមុខងាររបស់ខ្លួន ប្រធានតុលាការខេត្ត ឬរាជធានីអាចចាត់តាំងជាបណ្តោះអាសន្នទៅឲ្យ ចៅក្រមស៊ើបសួរផ្សេងទៀតនៃតុលាការបាន ដើម្បីបំពេញមុខងារនោះ។[29] នៅក្នុងករណីដែលចៅក្រមស៊ើបសួរមានច្រើនរូប នៅក្នុងតុលាការមួយ សំណុំរឿងទាំងឡាយត្រូវបានបែងចែកដោយប្រធានតុលាការជាអ្នកសម្រេចដើម្បីដោះស្រាយអំពីរឿងនេះ។ ហេតុដូច្នេះ ប្រធានតុលាការរាជធានី ឬខេត្ត ត្រូវកំណត់ទុកមុនជារៀងរាល់ឆ្នាំ ដោយដីកាសម្រេចបែងចែកសំណុំរឿងមួយ ដោយមានកំណត់អំពីលំដាប់ជំនួសនៅក្នុងករណីចៅក្រមណាម្នាក់មានធុរៈ។[30]

ការបែងចែកសំណុំរឿង តាមលំដាប់លេខរៀងនេះ ចៅក្រមម្នាក់ៗ ត្រូវទទួលបន្ទុកជាស្វ័យប្រវត្តិដែលមិនអាចត្រូវប្តូរនៅឆ្នាំនោះបានឡើយ។ លើកលែងតែ ចៅក្រមណាម្នាក់មានការងារ

[29] មាត្រា៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[30] មាត្រា៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ច្រើនពេក ឬករណីចៅក្រមត្រូវឈប់ ឬត្រូវប្តូរទៅតុលាការផ្សេង។ នៅក្នុងករណីនេះ ប្រធានតុលាការរាជធានី ខេត្ត ត្រូវចេញដីកាចាត់តាំងមួយដែលពុំបើកផ្លូវតវ៉ា។[31] សភាស៊ើបសួរជាអ្នកដោះស្រាយទំនាស់នៃចៅក្រមស៊ើបសួររឿងវិវាទសមត្ថកិច្ចនៃការស៊ើបសួរ របស់តុលាការផ្សេងគ្នា។[32]

**២.ការដកហូតសំណុំរឿង**

ដើម្បីជាប្រយោជន៍ កិច្ចការរដ្ឋបាលដ៏ល្អនៃយុត្តិធម៌ និងដើម្បីជៀសវាងពីភាពលំអៀងអំពីចៅក្រមណាម្នាក់ ការដកហូតសំណុំរឿងពីចៅក្រមណាម្នាក់ប្រគល់ជូនទៅ ចៅក្រមម្នាក់ទៀតអាចស្នើដល់ប្រធានតុលាការដើម្បីធ្វើចំណាត់ការនេះបាន។

ចំពោះការសុំនេះ អាចធ្វើឡើងតាមពាក្យសុំរបស់ព្រះរាជអាជ្ញាដោយធ្វើឡើងពីការផ្តើមគំនិតផ្ទាល់ខ្លួន ឬតាមពាក្យបណ្តឹងរបស់ភាគី។[33] ជាទូទៅ មូលហេតុដែលអាចបណ្តាលឲ្យមានការស្នើដកសំណុំរឿងពីចៅក្រមស៊ើបសួរណាម្នាក់ ក្នុងករណីដូចខាងក្រោម៖

- កាលណាចៅក្រម ឬសហព័ន្ធរបស់ចៅក្រម ឬអតីតសហព័ន្ធរបស់ចៅក្រមជាភាគីណាមួយក្នុងរឿងក្តី
- កាលណាចៅក្រមជាញាតិលោហិតរហូតដល់ថ្នាក់ទី៦ ញាតិពន្ធរហូតដល់ថ្នាក់ទី៣ ឬអតីតញាតិពន្ធរហូតដល់ថ្នាក់ទី៣ របស់ភាគីណាមួយ
- កាលណាចៅក្រមជាអ្នកអាណាព្យាបាលរបស់ភាគីណាមួយ
- កាលណាចៅក្រមដែលទទួលបន្ទុករឿងក្តីធ្លាប់ ឬកំពុងមានវិវាទនៅតុលាការ ជាមួយភាគីណាមួយ
- កាលណាចៅក្រមបានធ្វើជាសាក្សី ឬអ្នកជំនាញក្នុងរឿងក្តី
- កាលណាចៅក្រម ធ្លាប់ជាអ្នកតំណាង ឬជាអ្នកជំនួយឲ្យភាគីចំពោះរឿងក្តី
- កាលណាចៅក្រមបានចូលរួមសម្រេចសេចក្តីក្នុងនាម មជ្ឈត្តករចំពោះរឿងក្តី ឬបានចូលរួមក្នុងការសម្រេចសេចក្តីនៅ សាលាដំបូងដែលបានប្តឹងឧបាស្រ័យ ឬការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ដែលបានឧបាស្រ័យ ឬបង្ហាញយោបល់ណែនាំ ផ្នែកច្បាប់ចំពោះរឿងក្តី។[34]

---

[31] មាត្រា២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[32] មាត្រា១២៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[33] មាត្រា៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[34] មាត្រា ៥៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

## ផ្នែកទី២៖ លក្ខខណ្ឌនៃការស៊ើបសួរ

នៅក្នុងក្របខ័ណ្ឌ នៃនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ថ្មីនេះយើងឃើញថា ច្បាប់នីតិវិធីនេះបាន ធ្វើការបញ្ញត្តិយ៉ាងច្បាស់លាស់អំពីការស៊ើបសួរក្នុងរឿងក្តីព្រហ្មណ្ឌ ដើម្បីធ្វើយ៉ាងណាឲ្យរឿងក្តីមួយ មានភាពច្បាស់លាស់ក្នុងការសម្រេចសេចក្តី។ ហើយការស៊ើបសួរត្រូវធ្វើដោយខានពុំបានចំពោះ បទឧក្រិដ្ឋ។ ចំពោះបទមជ្ឈិមវិញការស៊ើបសួរអាចធ្វើក៏បាន ឬមិនធ្វើក៏បាន។[35] ហើយការបើកការ ស៊ើបសួរត្រូវធ្វើឡើងតាមរយៈ ការបើកការស៊ើបសួរដោយដីការបស់ព្រះរាជអាជ្ញា និងការស៊ើបសួរ ដោយការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

### ១.ការស៊ើបសួរដោយដីការបស់ព្រះរាជអាជ្ញា

បន្ទាប់ពីព្រះរាជអាជ្ញាទទួលបាននូវពាក្យបណ្តឹងទាមទារ ឬពាក្យបណ្តឹងបរិហា ហើយធ្វើការ ស៊ើបអង្កេត និងស្រាវជ្រាវរួច ប៉ុន្តែព្រះរាជអាជ្ញាយល់ថាសំណុំរឿងមិនទាន់អាចបញ្ជូនទៅជំនុំជម្រះ បានទេ នោះព្រះរាជអាជ្ញា និងបញ្ជូនរឿងនោះទៅស្ថាប័ននៃចៅក្រមស៊ើបសួរតាមរយៈ ធ្វើជាដីកា សន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ គឺជាការសន្និដ្ឋានមួយ ដែល ធ្វើឡើងដោយព្រះរាជអាជ្ញា ក្នុងនាមគាត់ជាម្ចាស់នៃបណ្តឹងអាជ្ញា ហើយបានកំណត់ដោយច្បាប់ ក្រោយពីគាត់យល់ឃើញថា អំពើដែលប្រព្រឹត្តឡើង ដោយជនសង្ស័យនោះបានប៉ះពាល់ដល់ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយក្នុងសង្គម ដូចជាករណីបទឧក្រិដ្ឋធ្ងន់ធ្ងរ គាត់ត្រូវតែ ប្តឹងទៅចៅក្រមស៊ើបសួរ ដាច់ខាតតាមរយៈ **ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។**[36]

ក្រោយពីចៅក្រមស៊ើបសួរ ទទួលបានបណ្តឹងរបស់ព្រះរាជអាជ្ញាតាមរយៈដីកាសន្និដ្ឋាបញ្ជូន រឿងឲ្យស៊ើបសួរ ត្រូវធ្វើការស៊ើបសួរតាមការចង្អុលបង្ហាញរបស់ព្រះរាជអាជ្ញានៅក្នុងដីកា ឬចៅក្រម ស៊ើបសួរក៏អាចស៊ើបសួរ ប្រឆាំងនិងអញ្ញាតជន (ជនដែលមិនស្គាល់ឈ្មោះ ឬ ភិនភាគ)។ ចៅក្រម ស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយ ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ពី ព្រះរាជអាជ្ញាបានឡើយ។[37] ចៅក្រមស៊ើបសួរ ក៏អាចបើកការស៊ើបសួរតាមរយៈបណ្តឹង ដោយមាន ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានដែរ។[38]

### ២.ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

[35] មាត្រា១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[36] មាត្រា ៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[37] មាត្រា ១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[38] មាត្រា ១៣៩ កថាខ័ណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ អាចផ្តល់សិទ្ធិឲ្យជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម[39] (បទលហុមិនអាចធ្វើតាមនីតិវិធីនេះបានទេ) អាចប្តឹងផ្ទាល់មកចៅក្រមស៊ើបសួរ ក្នុងករណីដែលព្រះរាជអាជ្ញាអមសាលាដំបូង សម្រេចតម្កល់រឿងទុកឥតចាត់ការ ឬ បន្ទាប់ពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ បានសម្រេចតម្កល់សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាសាលាដំបូង ទុកជាបានការ។ ទោះបីជាពាក្យបណ្តឹងត្រូវបានទទួល តាមរយៈការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយក៏ចៅក្រមស៊ើបសួរត្រូវតែទទួលជាចាំបាច់នូវ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ពីអយ្យការជាមុនសិនទើបអាចធ្វើការស៊ើបសួរបាន។ ក្រោយពីបានទទួលនូវពាក្យបណ្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរត្រូវធ្វើការកត់សម្គាល់នូវពាក្យបណ្តឹង ហើយបញ្ជូនបណ្តឹងនោះមកកាន់ព្រះរាជអាជ្ញា។[40]

ក្រោយពីបានទទួលបណ្តឹងនោះ ព្រះរាជអាជ្ញាត្រូវប្តឹងទៅចៅក្រមស៊ើបសួរ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ពាក្យបណ្តឹងដោយ មានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនចងកាតព្វកិច្ចឲ្យព្រះរាជអាជ្ញា ត្រូវតែបើកការស៊ើបសួរចំពោះបុគ្គល ដែលចង្អុលបង្ហាញក្នុងពាក្យបណ្តឹងនោះទេ បានសេចក្តីថាព្រះរាជអាជ្ញា អាចបើកការស៊ើបសួរតាមរយៈការចេញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ឬក៏ព្រះរាជអាជ្ញាអាចស្នើសុំមកចៅក្រម ដើម្បីកុំអោយធ្វើការស៊ើបសួរ ។ ជាគោលការណ៍បណ្តឹងនេះ គឺជាសេរីភាពនៃឆន្ទៈបុគ្គលឯកជន។ ការដាក់ពាក្យបណ្តឹងបែបនេះទាមទារឲ្យជនរងគ្រោះពិចារណាឲ្យបានល្អិតល្អន់បំផុត ដោយហេតុថាបណ្តឹងនេះ អាចនិងទទួលរងនូវប្រតិកម្មតបវិញ ដោយអ្នកប្តឹងអាចនឹងប្រឈមការពិន័យរដ្ឋប្បវេណី ព្រមទាំងបណ្តឹងឲ្យមានការជួសជុលការខូចខាតពីភាគីម្ខាងទៀត ក្នុងករណីដែលរកឃើញថា បណ្តឹងនោះធ្វើឡើងដោយរំលោភបំពាន ឬបណ្តឹងអូសបន្លាយពេលវេលា។ ហេតុនេះហើយ ទើបមានការសន្មត់ថា បណ្តឹងនេះអាចជាជម្រើសចុងក្រោយរបស់ជនរងគ្រោះ ឬអាចនិយាយឲ្យកាន់តែច្បាស់ថែមទៀតនោះគឺបណ្តឹងបែបនេះភាគច្រើនជនរងគ្រោះធ្វើឡើង បន្ទាប់ពីការតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញាអមសាលាដំបូង ក្នុងក្របខ័ណ្ឌនៃការធ្វើបណ្តឹងអាជ្ញា ឲ្យមានចលនាចំពោះហេតុណាមួយដែល ជនរងគ្រោះយល់ឃើញថាខ្លួនបានទទួលរងគ្រោះ ពីការបំពាននៃអំពើនោះ ហើយអំពើនោះទៀតសោតមានចរិកលក្ខណៈ ជាបទល្មើសព្រហ្មទណ្ឌ។[41]

[39] មាត្រា ១៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[40] មាត្រា ១៣៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[41] ដក់ស្រង់ចេញពីសៀវភៅនីតិវិធីព្រហ្មទណ្ឌទំព័រទី ៥៦ របស់លោកសាស្រ្តាចារ្យ ឌី លីឡា និង ខាន់ សុខា

គួរកត់សម្គាល់ថា បណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ជាបណ្ដឹងមួយថ្មី ដែលទើបតែបញ្ចូលក្នុងក្រមនីតិវិធីព្រហ្មទណ្ឌថ្មីនេះឯង ហើយដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបង់នូវប្រាក់តម្កល់ទុក តាមការកំណត់របស់ចៅក្រមស៊ើបសួរ តាមដីកាសម្រេច ដោយផ្អែកលើធនធាននៃដើមបណ្ដឹងរដ្ឋប្បវេណី និងទៅលើភាពលំបាកនៃរឿងក្ដីដែលអាចមើលឃើញមុន តែចៅក្រមស៊ើបសួរ ក៏អាចលើកលែងមិនឲ្យបង់ប្រាក់តម្កល់នេះបានដែរ។ ប្រសិនបើចៅក្រមស៊ើបសួរ តម្រូវឲ្យបង់ប្រាក់តម្កល់ទុក តែដើមបណ្ដឹងរដ្ឋប្បវេណីពុំព្រមបង់ក្នុងរយៈពេល ដែលតម្រូវដោយចៅក្រមទេ ចៅក្រមស៊ើបសួរអាចប្រកាស់ថាមិនអាចទទួលពាក្យបណ្ដឹងនេះបាន។[42] ការតម្រូវឲ្យមានការបង់នូវប្រាក់តម្កល់នេះ គឺដើម្បីធានាការបង់ប្រាក់ពិន័យរដ្ឋប្បវេណី ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា នីតិវិធីនេះធ្វើឡើងដោយរំលោភ ឬអូសបន្លាយពេលវេលា ដោយចៅក្រមស៊ើបសួរចេញដីកាសម្រេចឲ្យបង់ប្រាក់ពិន័យរដ្ឋប្បវេណី តាមមាត្រា១៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តែប្រាក់ពិន័យនេះមិនអាចលើសពីចំនួនប្រាក់តម្កល់ទុកបានឡើយ។ ផ្ទុយទៅវិញ ប្រសិនបើពុំតម្រូវអោយបង់ប្រាក់ពិន័យរដ្ឋប្បវេណីទេ ត្រូវបង្វិលប្រាក់តម្កល់ទុក នោះទៅអោយសាមីខ្លួនវិញនៅពេលបញ្ចប់នីតិវិធី។[43] នៅក្នុងក្របខ័ណ្ឌនេះផងដែ ព្រះរាជអាជ្ញាអាចប្ដឹងសុំកុំឲ្យ ចៅក្រមស៊ើបសួរ ស៊ើបសួរតែក្នុងករណីដែល:

- បណ្ដឹងអាជ្ញាត្រូវបានផុតរលត់
- អំពើដែលប្ដឹងមកនោះ មិនមែនជាបទល្មើសព្រហ្មទណ្ឌ។[44]

ក្នុងករណីដែលចៅក្រមស៊ើបសួរ សម្រេចមិនស៊ើបសួរតាមការប្ដឹងសុំរបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសម្អាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ ដល់ដើមបណ្ដឹងរដ្ឋប្បវេណី។ កាលបើអ្នកប្ដឹងសុំ មិនសុខចិត្ត នឹងសេចក្ដីសម្រេចនេះ ដើមបណ្ដឹងរដ្ឋប្បវេណីប្ដឹងឧទ្ធរណ៍បានក្នុងរយៈពេល ៥ថ្ងៃ គិតពីថ្ងៃជូនដំណឹងអំពីដីកា។[45] បុគ្គលដែលមានឈ្មោះនៅក្នុងបណ្ដឹង អាចប្ដឹងសុំការជួសជុលសំណង ពីអ្នកដែលបានប្ដឹងមកលើខ្លួនបាន ប្រសិនបើមាន

[42] មាត្រា ១៤០ កថាខណ្ឌទី៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧
[43] មាត្រា ១៤០ កថាខ័ណ្ឌទី៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧
[44] ដក់ស្រង់ចេញពីសៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០១៧-២០១៨ទំព័រទី ៣៨របស់លោកសាស្ត្រាចារ្យ រុន្ទ ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត
[45] ដក់ស្រង់ចេញពីសៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌទំព័រទី ៥៧ របស់លោកសាស្ត្រាចារ្យ ឌី លីឡា និង ខាន់ សុខា

ការបើកការស៊ើបសួរ បន្ទាប់ពីមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីហើយក្រោយមក ចៅក្រមលើកលែងបទចោទប្រកាន់ កាលបើនីតិវិធីធ្វើឡើងដោយអូសបន្លាយពេលវេលា។[46]

**ផ្នែកទី៣៖ ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ**

ដើម្បីស្វែងរកការពិត និងរកយុត្តិធម៌ជូនជនរងគ្រោះ ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចស៊ើបសួរទាក់ទងនិងបុគ្គល ព្រមទាំងស្វែងរកនូវភស្តុតាងទាំងអស់ នៃរឿងក្តីដើម្បីឲ្យគូរភាគីទទួលបាននូវភាពយុត្តិធម៌ មួយច្បាស់លាស់ផងដែរ។

**១. កិច្ចស៊ើបសួរទាក់ទង និង បុគ្គល**

**១.១. ជនត្រូវចោទ**

ជនត្រូវចោទគឺជាបុគ្គល ដែលត្រូវបានចោទប្រកាន់តាម ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដោយឲ្យមានចំណាត់ការនីតិវិធីនៃការស៊ើបសួរ របស់ចៅក្រមស៊ើបសួរ។ ការចូលបង្ហាញខ្លួនរបស់ជនត្រូវចោទ ចៅក្រមស៊ើបសួរត្រូវសួរ និងកត់ត្រាអំពីអត្តសញ្ញាណរបស់ជនត្រូវចោទនោះ ដូចជាឈ្មោះ អាយុ ភេទ សញ្ជាតិ មុខរបរ កាលបរិច្ឆេទនិងហត្ថលេខារបស់ព្រះរាជអាជ្ញា ឬលំនៅឋានរបស់ជនត្រូវចោទជាដើម។ បន្ទាប់ពីចៅក្រមស៊ើបសួរ បញ្ជាក់អំពីអត្តសញ្ញាណ និង ក្រោយពីបានទទួលដំណឹងអំពីអំពើដែលខ្លួន ត្រូវចោទប្រកាន់រួចហើយ ប្រសិនបើជនត្រូវចោទជម្រាបចៅក្រមស៊ើបសួរថាខ្លួនសុំជ្រើសរើសយកមេធាវីមួយ ឬថាខ្លួនសុំឲ្យរដ្ឋចាត់តាំងមេធាវីមួយ (ការចាត់តាំងនូវមេធាវីត្រូវធ្វើដោយប្រធានតុលាការ ក្នុងករណី ជនរងគ្រោះជាអនីតិជន ជនគ្មានទីពឹង ជនត្រូវចោទជាមនុស្សគ ថ្លង់ ឬអ្នកមានវិបត្តិស្មារតី ជនត្រូវចោទដែលគ្មានលទ្ធភាពអាចពឹងពាក់មេធាវី ការពារខ្លួនបាន)។ កាលណាជនត្រូវចោទមានមេធាវីអម ចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីយ៉ាងតិចបំផុត ៥ ថ្ងៃមុនការសួរចម្លើយ។[47]

ការសួរចម្លើយជនត្រូវចោទ អាចធ្វើទៅបានតែនូវចំពោះមុខមេធាវីតែប៉ុណ្ណោះ។ ប៉ុន្តែក្នុងករណីបើការកោះហៅត្រូវបានធ្វើឡើងដោយត្រឹមត្រូវ ហើយមេធាវីមិនបានចូលបង្ហាញខ្លួន ទៅតាមពេលវេលាដែលបានកំណត់ទេ ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទដោយគ្មានវត្តមានមេធាវីបាន។[48] មេធាវីរបស់ជនត្រូវចោទ មានសិទ្ធិរបស់ខ្លួនផងដែរ គឺការប្រាស្រ័យទាក់ទងជាមួយកូនក្តីខ្លួននៅក្នុងពន្ធនាគារ ឬនៅក្នុងមណ្ឌលឃុំខ្លួនបាន។ ជាងនេះទៅទៀត មេធាវីក៏មានសិទ្ធិអាច

[46] មាត្រា ១៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[47] មាត្រា ១៤៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[48] មាត្រា ១៤៥ កថាខណ្ឌទី ២នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ធ្វើការសន្ទនាជាមួយកូនក្តីរបស់ខ្លួន និងអាចអានសំណុំរឿង ឲ្យស្តាប់ដោយគ្មានវត្តមានសមត្ថកិច្ចណាទាំងអស់។ មួយវិញទៀត ការថត ការសន្ទនារវាងមេធាវី និងកូនក្តីពីសំណាក់មន្ត្រីពន្ធនាគារ ឬសមត្ថកិច្ចដែលពាក់ព័ន្ធ គឺត្រូវបានហាមឃាត់ដោយច្បាប់ ចំណែកឯលិខិតថតចម្លងនៃសំណុំរឿងកូនក្តីរបស់ខ្លួន មេធាវីមិនអាចប្រគល់ ឲ្យទៅកូនក្តីរបស់ខ្លួនបានឡើយ។[49]

### ១.២. ដើមបណ្តឹងរដ្ឋប្បវេណី

ដើមបណ្តឹងរដ្ឋប្បវេណី គឺជាភាគីម្ខាងនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ដែលបានទទួលរងគ្រោះដោយសារតែបទល្មើសព្រហ្មទណ្ឌ ហើយបានប្តឹងទាមទារសំណង នៃការខូចខាតពីជនល្មើស តាមរយៈពាក្យបណ្តឹងសាមញ្ញ ឬ តាមបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ការយកចម្លើយពីជននេះពិតជាមានសារៈសំខាន់ណាស់ ដើម្បីឈានទៅរកជន ដែលបានប្រព្រឹត្តបទល្មើសយ៉ាងពិតប្រាកដ។ ដោយសារតែជនរងគ្រោះ ជាជនដែលទទួលរងនូវអំពើព្យាសនៈកម្មដោយផ្ទាល់ដូច្នេះហើយ គាត់ប្រាកដជាមានការរៀបរាប់អំពីហេតុការណ៍ ដែលបានកើតឡើងដោយលម្អិត និងព្រមសហការក្នុងការស្វែងរកនូវភាពយុត្តិធម៌ជាមិនខានឡើយ។ ដើម្បីសម្រួលដល់ភាពងាយស្រួលក្នុងការរកចាប់ខ្លួនជនត្រូវចោទ និង សម្រួលដល់ចៅក្រមស៊ើបសួរផងនោះ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ពិតជាមានសារៈសំខាន់ខ្លាំងណាស់។ ការសួរចម្លើយដោយចៅក្រមស៊ើបសួរ ធ្វើឲ្យចៅក្រមស៊ើបសួរ បានដឹងអំពីអង្គហេតុដែលបានកើតឡើង ចំពោះជនរងគ្រោះ ការវិនាសអន្តរាយ ការទាមទាររបស់ជនរងគ្រោះ និងភស្តុតាង ព្រមទាំងចំណុចសំខាន់ៗ ដែលចៅក្រមស៊ើបសួរចង់ដឹង។

ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី គឺជាការឲ្យជនរងគ្រោះ រៀបរាប់អំពីដំណើររឿងដែលបានកើតហេតុ ដើមចម ដែលធ្វើឲ្យរឿងនោះកើតឡើង។ នីតិវិធីនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី វាអាស្រ័យទៅលើចៅក្រមស៊ើបសួរយល់ថា វាជាបញ្ហាសំខាន់ដែលទាក់ទងទៅនិងបទល្មើសដែលបានកើតឡើង។ មួយវិញទៀត ចៅក្រមស៊ើបសួរក៏អាច ចេញដីកាកោះហៅជនរងគ្រោះ ដើម្បីស្តាប់ចម្លើយ និងអាចចុះទៅដល់ទីកន្លែងដែលបទល្មើសបានកើតឡើង ព្រមទាំងមានក្រឡាបញ្ជីទៅជាមួយផងដែរ។[50]

ទន្ទឹមនឹងនេះ ដើមបណ្តឹងរដ្ឋប្បវេណីក៏មានសិទ្ធិ មានមេធាវី ឬគ្មានមេធាវី ហើយការស្តាប់ចម្លើយរបស់គាត់ត្រូវបានបែងចែកជាពីរលក្ខខណ្ឌ។ លក្ខខណ្ឌទី១ ប្រសិនជាគាត់មានមេធាវី

[49] មាត្រា ១៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[50] មាត្រា ១៥០ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ការពារក្តី ការស្តាប់ចម្លើយត្រូវធ្វើឡើងចំពោះមុខមេធាវី តាមកាលបរិច្ឆេទដែលបានកំណត់ ៥ ថ្ងៃ យ៉ាងតិច មុនថ្ងៃស្តាប់ចម្លើយ តាមការកោះហៅរបស់ចៅក្រមស៊ើបសួរ។ បើផុតរយៈពេលនេះ ហើយគ្មានវត្តមានមេធាវីទេ ការស្តាប់ចម្លើយនេះអាចធ្វើដោយមិនមានការចូលរួម ដោយមេធាវីនៃដើមបណ្តឹងរដ្ឋប្បវេណីបាន។ ចំពោះលក្ខខណ្ឌទី២ វិញការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីនេះ អាចធ្វើដោយមិនមានការកោះហៅមេធាវីបាន ប្រសិនបើ ដើមបណ្តឹងរដ្ឋប្បវេណីបានបោះបង់ចោល ដោយជាក់លាក់នូវវត្តមានមេធាវីរបស់ខ្លួន ដោយការបោះបង់នេះត្រូវបាន ចុះនិទ្ទេសនៅក្នុង កំណត់ហេតុដោយឡែក ពីកំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងត្រូវចុះហត្ថលេខា ដោយដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។[51]

បន្ទាប់ពីចៅក្រមស៊ើបសួរ បានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីហើយ ចៅក្រមស៊ើបសួរយកចម្លើយទាំងនោះធ្វើការពិចារណាជាមួយ និង ចម្លើយរបស់សាក្សី ឬ ជនត្រូវបានចោទប្រកាន់ ដោយយកចម្លើយទាំងអស់នោះ មកប្រៀបធៀបថាតើមានលក្ខណៈសមស្រប ឬ មិនសមស្រប។ កំណត់ហេតុស្តីពីការបង្ហាញខ្លួន នេះត្រូវបានចុះហត្ថលេខាដោយ ចៅក្រម ក្រឡាបញ្ជី និង ដើមបណ្តឹងរដ្ឋប្បវេណី។ ហើយប្រសិនបើ ដើមបណ្តឹងរដ្ឋប្បវេណី មិនបានចុះហត្ថលេខានោះទេ ចាំបាច់តុលាការត្រូវតែចុះនិទ្ទេសឲ្យបានច្បាស់លាស់។

### ១.៣ សាក្សី

សាក្សីគឺ ជាជនដែលបានដឹង បានឮ ឬ បានឃើញហេតុការណ៍ផ្សេងៗ ដែលពាក់ព័ន្ធ នឹងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ។[52] ដោយហេតុថា សាក្សីគឺជាជនដែលមានវត្តមាននៅកន្លែងកើតហេតុ ឬហេតុការណ៍ដែលបានកើតឡើង ឬក៏ជាការចុះហត្ថលេខាលើលិខិតអ្វីមួយ ឬជាអ្នកឲ្យការណ៍ដល់តុលាការ។ ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយ របស់បុគ្គលគ្រប់រូប ដែលចម្លើយទាំងនោះផ្តល់ផលប្រយោជន៍ ក្នុងការសម្តែងឲ្យឃើញពីការពិត។[53]

ជាទូទៅសាក្សីត្រូវបានបែងចែកជាបីគឺ សាក្សីដោះបន្ទុក សាក្សីដាក់បន្ទុក និងសាក្សីដែលកោះហៅតាមឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរ។ សាក្សីត្រូវតែចូលមកបង្ហាញខ្លួននូវចំពោះមុខតុលាការតាមការកោះហៅ។ តុលាការអាចប្រើកម្លាំងសាធារណៈ ដើម្បីបង្ខំសាក្សីឲ្យចូលខ្លួន។[54]

---

[51] មាត្រា ១៥០ កថាខ័ណ្ឌទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[52] ទំព័រទី ១៧២ នៃសៀវភៅនីតិកស្តុតាង បោះពុម្ភនៅឆ្នាំ ២០១៦ ដោយលោកសាស្ត្រាចារ្យ អ៊ិន បូផា

[53] មាត្រា ១៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[54] មាត្រា ៣១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ហើយរាល់បុគ្គលណាដែលត្រូវបានកោះហៅដោយចៅក្រមស៊ើបសួរ ក្នុងឋានៈជាសាក្សីដើម្បីឲ្យបំភ្លឺរឿងរ៉ាវដែលខ្លួនបានដឹងហើយនោះ បដិសេធមិនចូលខ្លួនតាមដីកាកោះហៅទេ បុគ្គលនោះអាចត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែទៅ៦ខែ និងពិន័យជាប្រាក់ពី ១សែនរៀលទៅ ១លានរៀលតាមមាត្រា ៥៣៨ នៃក្រមព្រហ្មទណ្ឌ។ ការស្តាប់ចម្លើយរបស់សាក្សី គឺជាការយកចម្លើយទៅលើហេតុការណ៍ ដែលសាក្សីបានដឹង បានឮ និងបានឃើញដើម្បីបង្ហាញ ឲ្យឃើញពីអង្គហេតុពិតប្រាកដ ដែលបានកើតឡើង។ នីតិវិធីបែបនេះវាមានសារៈសំខាន់ណាស់ក្នុងការកាត់សេចក្តី និងជំរុញឲ្យមានភាពយុត្តិធម៌ជូនដល់ជនរងគ្រោះ និងជនត្រូវចោទ អោយទទួលបានភាពត្រឹមត្រូវមួយនៅក្នុងសង្គម។

បន្ទាប់ពីចៅក្រមស៊ើបសួរ ទទួលបាននូវរឿងក្តីតាមរយៈ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ដែលនាំឲ្យចៅក្រមស៊ើបសួរមានអំណាច កោះហៅគ្រប់ជនដែលពាក់ព័ន្ធនៅក្នុងសំណុំរឿង មកបង្ហាញខ្លួនដើម្បីធ្វើការស៊ើបសួរ និងផ្តល់ចម្លើយ។ ការកោះហៅសាក្សី ឬអ្នកដែលពាក់ព័ន្ធក្នុងរឿងក្តីព្រហ្មទណ្ឌ ត្រូវមានបញ្ជាក់អត្តសញ្ញាណរបស់សាក្សី ព្រមទាំងត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និង បោះត្រាផង។[55] មុននិងធ្វើការឆ្លើយបំភ្លឺ របស់សាក្សីចាំបាច់ត្រូវតែធ្វើការស្បថ ទៅតាមជំនឿសាសនារបស់ខ្លួនដោយនិយាយតែការពិត។ ការស្បថត្រូវធ្វើឡើងដូចមានចែងក្នុងទម្រង់ ដែលមានកំណត់នៅក្នុងឧបសម្ព័ន្ធ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧។[56]

ប៉ុន្តែនៅក្នុងករណីមួយចំនួន សាក្សីត្រូវបានឲ្យរួចផុតពីការស្បថ ក្នុងនោះរួមមាន៖

- ឪពុក ម្តាយ និង បុព្វជនគ្រប់រូបរបស់ជនត្រូវចោទ
- កូនប្រុសកូនស្រី និង បច្ឆាជនគ្រប់រូបរបស់ជនត្រូវចោទ
- បង ប្អូនប្រុសស្រី របស់ជនត្រូវចោទ
- បងប្អូនថ្លៃ ប្រុសស្រីរបស់ជនត្រូវចោទ
- ប្តីឬ ប្រពន្ធ របស់ជនត្រូវចោទ ទោះបីជាបានលែងលះគ្នាហើយក៏ដោយ
- កុមារមានអាយុតិចជាង ១៤ឆ្នាំ។[57]

[55] មាត្រា ១៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[56] មាត្រា ១៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[57] មាត្រា ៣១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ចំពោះលក្ខខណ្ឌនៃការស្បថ និងនីតិវិធីនៃការធ្វើសម្បថត្រូវបាន ដឹកនាំដោយក្រឡាបញ្ជីមួយរូប ហើយត្រូវធ្វើឡើងនៅចំពោះមុខនៃទីកន្លែង វត្ថុស័ក្តសិទ្ធិ នៃតុលាការនីមួយៗតាំងនៅមានសមត្ថកិច្ច។ ក្រោយពីបានធ្វើសម្បថរួចហើយ ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុដែលបានឲ្យស្បថនោះបញ្ជាក់ថាបានធ្វើដោយភាពត្រឹមត្រូវហើយ វាចាស្បថយ៉ាងណាត្រូវធ្វើ កំណត់ហេតុយ៉ាងនោះ។ ការឆ្លើយរបស់សាក្សីត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំ ឬគំរាមកំហែងលើគ្រប់រូបភាពទាំងអស់មានទាំងផ្លូវកាយ និង ផ្លូវចិត្តផងដែរ។ កាលណាមានករណីនេះកើតឡើង ចម្លើយរបស់សាក្សីពុំត្រូវបានយកជាបានការនោះទេ ចំណែកឯបុគ្គលដែលមានការបង្ខំ ឬមានការគំរាមកំហែងទៅលើសាក្សីគ្រប់រូបភាព អាចនិងត្រូវជាប់ពិរុទ្ធ ដូចដែលមានចែងនៅក្នុងមាត្រា ៥៤៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ បានបញ្ញត្តិថា អ្នកដែលសម្លុតសាក្សីត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពី២ ឆ្នាំទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀល ទៅ១០លានរៀល ។ ហើយសាក្សីសំដៅទៅលើ មនុស្សមានជីវិត។ ការបង្ហាញ ឬការបំភ្លឺរបស់សាក្សី គឺជាការបំភ្លឺដែលធ្វើឡើងដោយមនុស្សដែលមានជីវិត (ភស្តុតាងមានជីវិត) ហើយការបំភ្លឺនេះមានគោលបំណង ធ្វើឲ្យបានដឹង និងបានយល់ច្បាស់នូវអង្គហេតុនានាដូចជា៖ សកម្មភាពនានានៃអំពើ ទាំងនោះជាធាតុផ្សំដ៏សំខាន់នៃ បទល្មើសព្រហ្មទណ្ឌ។ ភស្តុតាងផ្សេងទៀត ដែលមិនមានជីវិតនោះទេ (ភស្តុតាងស្លាប់) ពីព្រោះវាមិនចេះនិយាយ ដូចវត្ថុធាតុដើមដែលភស្តុកតាងប្រភេទបែបនេះ យើងអាចយល់បានតាមការលេចឡើង ចំពោះខណៈនៃអង្គហេតុតែប៉ុណ្ណោះ។

## ២. កិច្ចស៊ើបសួរទាក់ទង និង ភស្តុតាង

ភស្តុតាង គឺជាព្រឹត្តហេតុ ឬអង្គហេតុទាំងឡាយ ដែលអង្គហេតុទាំងនោះត្រូវបានកំណត់ដោយច្បាប់ទៅលើទម្រង់នីតិវិធីនានារបស់វា ដើម្បីធ្វើការបង្ហាញ ឬបដិសេធទៅលើព្រឹត្តិការណ៍នៃបទល្មើសណាមួយបាន ដោយអង្គហេតុទាំងនោះបង្ហាញនូវការដាក់បន្ទុក ឬដោះបន្ទុក ឬដោះសាចំពោះការទទួលខុសត្រូវរបស់បុគ្គល ព្រមទាំងកំណត់បាននូវកម្រិតខ្ពស់ ទាប និង ធ្ងន់ ឬស្រាលទៅលើការទទួលខុសត្រូវរបស់បុគ្គលទាំងនោះផង។[58] ភស្តុតាងត្រូវបានគេសង្កេតឃើញថា មានពីប្រភេទគឺ ភស្តុតាងផ្ទាល់ និង ភស្តុតាងប្រយោល។ ភស្តុតាងផ្ទាល់ គឺជាភស្តុតាងដែលឆ្លុះបញ្ចាំងផ្ទាល់ទៅលើអង្គហេតុ ឬអ្នកប្រព្រឹត្តអំពើអ្វីមួយជាសត្យានុម័ត ។ ចំណែកឯភស្តុតាងដោយប្រយោលវិញ គឺជាភស្តុតាងដែលទាក់ទងមិនចំពោះ។ ដំណាក់កាល នៃការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

[58] ដកស្រង់ចេញពីសៀវភៅនីតិភស្តុតាងរបស់លោកសាស្ត្រាចារ្យ អ៊ិន បូផា បោះពុម្ពលើទី២ ឆ្នាំ ២០១៦

ក្នុងកិច្ចស៊ើបសួរទាក់ទង និង ភស្តុតាង ចាំបាច់ត្រូវតែធ្វើការប្រមូលភស្តុតាង បន្ទាប់មកត្រូវ វាយតម្លៃលើភស្តុតាងនោះផងដែរ ទើបអាចធ្វើការកាត់សេចក្តីបានដោយភាពយុត្តិធម៌។

### ២.១ ការប្រមូលភស្តុតាង

ចៅក្រមស៊ើបសួរ មានសិទ្ធិក្នុងការប្រមូលភស្តុតាង ទាំងអស់ដែលខ្លួនយល់ឃើញថា ភស្តុតាងទាំងនោះមានប្រយោជន៍ ក្នុងការបង្ហាញពីការពិត។ ការប្រមូលភស្តុតាង គឺជាការប្រូកសរុបនូវគ្រប់សកម្មភាពនៃការរុករក ការកត់ត្រា ដកហូត ប្រមែប្រមូល និងរក្សាឲ្យស្របទៅតាមច្បាប់ដែលបានចូលជាធរមាន។ ចៅក្រមស៊ើបសួរ ត្រូវតែប្រមូលភស្តុតាង ប្រកបទៅដោយការត្រិះរិះពិចារណា ស្វែងរកភស្តុតាងដែលមានលក្ខណៈសំខាន់ ហើយត្រូវយកចិត្តទុកដាក់ ចំពោះពេលវេលា ដើម្បីឲ្យដំណើរការក្នុងរឿងក្តីបានល្អ ចៅក្រមស៊ើបសួរ មិនត្រូវបណ្តែតបណ្តោយធ្វើឲ្យមានការធ្វេសប្រហែសនោះឡើយ ព្រោះវាអាចធ្វើអោយរឿងក្តីបាត់នូវភស្តុតាង។ ម្យ៉ាងទៀតចៅក្រមស៊ើបសួរអាចចាត់វិធានការផ្សេងៗ ឲ្យតែអាចមានប្រយោជន៍ ដូចជាអាចចុះឆែកឆេរទៅដល់ទីកន្លែង លំនៅឋាន ឬទីសំណាក់ ឬទ្រព្យសម្បត្តិ ទីកន្លែងកើតហេតុ ដើម្បីអាចចាប់យកវត្ថុតាងក្នុងរឿងក្តីធ្វើការដោះស្រាយតាមផ្លូវច្បាប់។ ។

អំណាចនៃការឆែកឆេរនេះ គឺបានធ្វើឲ្យមានផលប៉ះពាល់ដល់ សិទ្ធិសេរីភាព កិត្តិយស និងសេចក្តីថ្លៃថ្នូរ របស់បុគ្គលដែលពាក់ព័ន្ធ ដូចនេះអាជ្ញាធរមានសមត្ថកិច្ចត្រូវតែ ធ្វើឡើងឲ្យបានត្រឹមត្រូវ និង តឹងរឹងបំផុតដោយមានការសំអាងច្បាស់លាស់ពិតប្រាកដ និងស្របទៅតាមច្បាប់ជាពិសេសក្រមនីតិវិធីព្រហ្មទណ្ឌជាដើម។ ការឆែកឆេរដែលត្រូវបានធ្វើដោយចៅក្រមស៊ើបសួរ ត្រូវតែធ្វើនៅចំពោះមុខសាក្សី ដែលបានកាន់កាប់ទីកន្លែង ហើយនៅក្នុងករណីដែលមិនមានទេ ចៅក្រមស៊ើបសួរអាចធ្វើការឆែកឆេរ នៅចំពោះមុខសាក្សីពីរនាក់ ដែលខ្លួនបានចាត់តាំង។ ហើយសាក្សីទាំងនោះ គឺមិនមែនជាបុគ្គលដែល ជាអ្នកមានសមត្ថកិច្ចក្នុងការឆែកឆេរនោះទេ។ ចំពោះពេលវេលានៃការឆែកឆេរ ចៅក្រមស៊ើបសួរអាចឆែកឆេរ នៅវេលាម៉ោង ៦ ព្រឹករហូតដល់ម៉ោង ១៨ ល្ងាចជាកំណត់លើកលែងតែ៖

- ក្នុងករណីដែលការឆែកឆេរនៅទីកន្លែង ដែលបើកចំហដល់សាធារណៈជន
- ក្នុងករណីដែលឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ឬប្រើប្រាស់គ្រឿងញៀន។[59]

[59] មាត្រា ១៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

លក្ខណៈពិសេសមួយទៀតនោះ ប្រសិនបើមានការឆែកឆេរនៅការិយាល័យមេធាវី នីតិវិធីនៃការឆែកឆេរនេះត្រូវធ្វើនៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូនៃគណៈមេធាវីនោះ។ នៅក្នុងការអនុវត្តនីតិវិធីនៃការឆែកឆេរ បានឃើញនូវកម្មវត្ថុនៃការប្រព្រឹត្តបទល្មើស ចៅក្រមស៊ើបសួរអាចចាប់យកវត្ថុតាងទាំងនោះបាន ហើយត្រូវតែធ្វើការបិទស្លាក បោះត្រាលើវត្ថុតាងទាំងនោះ។ ក្រោយពីបានបង្ហាញវត្ថុដែលចាប់បាននោះ ដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សីទាំងពីរនាក់រួចមកចៅក្រមស៊ើបសួរ ត្រូវធ្វើកំណត់ហេតុស្ដីពីការចាប់ ដែលរួមមានបញ្ជីសារពើភ័ណ្ឌ នៃវត្ថុដែលចាប់យកនោះ។ ចៅក្រមស៊ើបសួរក៏ ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌអោយបានច្បាស់លាស់ លម្អិតអំពីវត្ថុ និងលិខិតទាំងឡាយដែលខ្លួនបានរឹបអូស ដោយទុកវត្ថុ និងលិខិតទាំងនោះនៅក្នុងបញ្ជីបិទជិត ហើយបោះត្រាលើកញ្ចប់នោះព្រមទាំងចុះហត្ថលេខា របស់ចៅក្រម និងក្រឡាបញ្ជី ផងដែរ។ អ្នកមានសមត្ថកិច្ចនៅក្នុងនីតិវិធីនេះមិនត្រូវប្រញាប់ប្រញាល់ យកវត្ថុតាងភ្លាមនោះទេ ព្រោះវាអាចធ្វើឲ្យបាត់បង់ទៅវិញក៏ថាបានដែរ។ គាត់ត្រូវកត់ត្រាអំពីការរកឃើញ និង អត្តសញ្ញាណនៃវត្ថុដែលបានរកឃើញ ហើយត្រូវធ្វើការថតរូបនិងវាស់វែង ក្នុងការបង្ហាញទីតាំងដើម និងធម្មជាតិនៃវត្ថុតាង។ ហើយភស្តុតាងដែលបានរកឃើញមួយចំនួនតម្រូវឲ្យមាន ការធ្វើកោសលវិច័យ និងវាយតម្លៃ ដើម្បីរកឃើញនូវភស្តុតាងផ្សេងៗទៀតដែលពាក់ព័ន្ធ។

### ២.២ ការវាយតម្លៃវត្ថុតាង

ការវាយតម្លៃនៃវត្ថុតាង គឺជាការសរុបនូវលទ្ធផលដែលកើតចេញពីការ ធ្វើកោសលវិច័យទៅលើអត្ថិភាពនៃវត្ថុតាងទាំងឡាយ ដែលមាននៅក្នុងសំណុំរឿងក្ដីដើម្បីបង្ហាញពីភាពជឿជាក់ ឬមិនជឿជាក់ទៅលើវត្ថុតាង។ ចៅក្រមស៊ើបសួរត្រូវតែធ្វើការវិភាគទៅលើវត្ថុតាង ឲ្យបានល្អិតល្អន់ ព្រមទាំងធ្វើការសំយោគ នៃវត្ថុតាងដែលមានទាំងនោះ ដោយកើតចេញពីការប្រមូលវត្ថុតាងនានា។

ប្រសិនបើចៅក្រមស៊ើបសួរ យល់ឃើញថាជាវិធានចាំបាច់ដើម្បីបញ្ជាក់ពីការពិត ចៅក្រមស៊ើបសួរអាចឲ្យធ្វើកោសលវិច័យទៅលើឈាម ឬវត្ថុ ឬស្លាកស្នាម ឬអាវុធ ឬឧបករណ៍ផ្សេងទៀត ឬទៅលើសាកសពជាដើម ដែលអាចធ្វើតាមការវិភាគមានលក្ខណៈវិទ្យាសាស្ត្រ បច្ចេកទេសដែលជាភាពចាំបាច់ក្នុងការធ្វើកោសលវិច័យ។ នៅក្នុងករណីនេះ ចៅក្រម ស៊ើបសួរអាចបង្គាប់ឲ្យធ្វើកោសលវិច័យដោយឯកឯងបាន ឬតាមពាក្យសុំរបស់ព្រះរាជអាជ្ញា ឬរបស់ជនត្រូវចោទ ឬតាមពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ ផ្ទុយទៅវិញ បើមានការបដិសេធ មិនឲ្យមានការធ្វើកោសលវិច័យ ចៅក្រម

ស៊ើបសួរ ត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុនៅក្នុងរយៈពេល ៥ ថ្ងៃចំពោះព្រះរាជអាជ្ញា និងចំនួន ៣០ ថ្ងៃចំពោះជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។[60]

ការវាយតម្លៃលើវត្ថុតាង ចាំបាច់ត្រូវមានការចូលរួមពី អ្នកជំនាញដែលមានឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិ ដែលត្រូវបានរៀបចំឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ហើយអ្នកជំនាញទាំងនោះចាំបាច់ត្រូវតែគោរពនូវបែបបទជាពិសេសគឺ ការស្បថនៅមុខសាលាឧទ្ធរណ៍ ក្នុងករណីដែលអ្នកជំនាញត្រូវបានចាត់តាំងតាមបញ្ជីនៃអ្នកជំនាញថ្នាក់ជាតិនោះ គឺអ្នកជំនាញនោះមិនចាំបាច់ធ្វើការស្បថជាលើកទីពីរទេ។[61] មួយវិញទៀត ចៅក្រមស៊ើបសួរ ក៏អាចចាត់តាំងអ្នកជំនាញដែលមិនមានឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិ នោះបានផងដែរដោយឲ្យអ្នកជំនាញទាំងនោះចាំបាច់ស្បថមុន និងធ្វើប្រតិបត្តិការរបស់ខ្លួន។[62] បេសកកម្មរបស់អ្នកជំនាញ ត្រូវបានអនុវត្តនូវតួនាទីរបស់ខ្លួនដោយមានការត្រួតពិនិត្យដោយចៅក្រមស៊ើបសួរ។ ប្រសិនបើអ្នកជំនាញ មិនគោរពរយៈពេលដែលកំណត់ដោយ ចៅក្រមស៊ើបសួរទេ ចៅក្រមស៊ើបសួរអាចចាត់អ្នកជំនាញផ្សេងៗទៀត ជំនួសនៃអ្នកជំនាញនោះ ។ ប៉ុន្តែប្រសិនបើកាលៈទេសៈតម្រូវនោះ ចៅក្រមស៊ើបសួរអាចអនុញ្ញាតតាម ដីកាសម្រេចឲ្យធ្វើការពន្យាពេលបាន។[63]

ចំពោះការត្រួតពិនិត្យទៅលើភស្តុតាង ក៏ជានីតិវិធីមួយដែល ចៅក្រមប្រើប្រាស់វាដើម្បីប្រមែប្រមូលស្រាវជ្រាវ និងវាយតម្លៃនៃវត្ថុតាង ឬក៏អាចនិយាយបានថា គឺជាដំណាក់កាលនៃការស្រាយបំភ្លឺនូវ ស្ថានលម្អិតទាំងឡាយនៃអង្គហេតុវិវាទនោះឲ្យមានភាពច្បាស់លាស់។ នៅក្នុងសំណុំរឿងវត្ថុដែលបានផ្តល់មកឲ្យចៅក្រមមាន ឯកសារ ឬលិខិតស្នាមដែលផ្ទុកព័ត៌មាន ឬព្រឹត្តហេតុដែលកើតឡើងទាក់ទងនិងរឿងក្តីព្រហ្មទណ្ឌ ហើយវាមានអត្ថន័យណាស់ក្នុងការដោះស្រាយរឿងក្តីរបស់ចៅក្រម។ ហើយវត្ថុតាងដែលមានសារៈសំខាន់ និង មានការពាក់ព័ន្ធចំពោះរឿងក្តីនោះទាមទារឲ្យចៅក្រមស៊ើបសួរធ្វើការត្រួតពិនិត្យទៅលើ ៖

- ពិនិត្យគ្រប់មុខសញ្ញាដែលពាក់ព័ន្ធ
- ពិនិត្យទៅលើចម្លើយសារភាពរួមផ្សំ និងវត្ថុដែលប្រមូលបានតើវាពាក់ព័ន្ធគ្នាដែរឬទេ
- ជាវត្ថុតាងដែលបានមកដោយការមិនបំពាន ឬបន្លំដែរឬទេ

[60] មាត្រា ១៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧
[61] មាត្រា ១៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧
[62] មាត្រា ១៦៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧
[63] មាត្រា ១៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

- កោសលវិច័យត្រូវបានធ្វើឡើងដោយអ្នកជំនាញពិតប្រាកដ
- ស្រាវជ្រាវនិង វិភាគផ្នែកនីមួយនៃវត្ថុតាង ធ្វើការផ្ទួរផ្ទងរវាងបណ្តាវត្ថុដែលប្រមូលបាន
- ស្វែងរកវត្ថុតាងថ្មី ដើម្បីបញ្ជាក់បន្ថែមនៅវត្ថុដែលមានស្រាប់ ។

ការវាយតម្លៃនៃភស្តុតាង គឺជាការសរុបលទ្ធផលមួយដែលកើតចេញពីការផ្ទៀងផ្ទាត់ ទៅលើអត្ថិភាពនៃភស្តុតាងទាំងឡាយ ដែលមាននៅក្នុងសំណុំរឿងក្តី ដោយលទ្ធផលទាំងនេះដាក់ចេញបានអំពីការទទួលស្គាល់ទៅលើអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុទាំងនោះ។ យើងអាចនិយាយម្យ៉ាងទៀតថា ការវាយតម្លៃ ឬការប៉ាន់ប្រមាណទៅលើភស្តុតាង គឺជាការធ្វើសេចក្តីសន្និដ្ឋានសរុបអំពីភាពជឿជាក់ ឬមិនជឿជាក់ទៅលើភស្តុតាង ដើម្បីយកមកធ្វើការសម្រេចសេចក្តី។

**៣.ការស្តាប់ទូរស័ព្ទ**

ការស្តាប់ទូរស័ព្ទ គឺជាការស្តាប់នូវការសន្ទនាតាមទូរស័ព្ទ ការចាប់ និងការថតគ្រប់ការឆ្លើយឆ្លងទៅតាមគ្រប់មធ្យោបាយ ទូរគមនាគមន៍ ឧបករណ៍ទំនើបបច្ចេកទេសដែលអាចទំនាក់ទំនងបាន ឬអ៊ីនធឺណែត ឬសារតាមទូរស័ព្ទជាដើម។ ហើយការស្តាប់ទូរស័ព្ទ គឺជានីតិវិធីមួយដែលប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិបុគ្គលឯកជន ដែលធានាដោយរដ្ឋធម្មនុញ្ញ ទាក់ទិននិងការរក្សាការសម្ងាត់នៃការឆ្លើយឆ្លងគ្នា។ ហេតុនេះហើយ ទើបក្រមនីតិវិធីព្រហ្មទណ្ឌអនុញ្ញាតឲ្យតែ ចៅក្រមស៊ើបសួរប៉ុណ្ណោះ ដែលមានសិទ្ធិអំណាចបង្គាប់ឲ្យស្តាប់ទូរស័ព្ទបាន។ ចៅក្រមស៊ើបសួរ អាចបង្គាប់ឲ្យមានការស្តាប់ទូរស័ព្ទ និងថតការសន្ទនាតាមរយៈមធ្យោបាយទំនាក់ទំនង ដែលត្រូវបានប្រើសប្រាស់ប្រសិនបើមានការយល់ថា ជាការសំខាន់និង ចាំបាច់។ ចៅក្រមស៊ើបសួរ បង្គាប់បញ្ជាតាមនីតិវិធីព្រហ្មទណ្ឌ ដោយដីកាសម្រេចមានការស្តាប់ និងបញ្ជាក់នៅក្នុងដីកា អំពីប្រភេទនៃទំនាក់ទំនងហើយរយៈពេលនៃបេសកកម្ម ដែលត្រូវធ្វើ។ ចៅក្រមស៊ើបសួរ អាចធ្វើកិច្ចការនេះតាមដីកាចាត់ឲ្យស៊ើបសួរជំនួសបានដែរ។[64] អង្គភាពសាធារណៈ មន្ត្រីរាជការដែលចាត់តាំង ត្រូវបំពេញពាក្យសុំរបស់ចៅក្រមស៊ើបសួរ។

ប្រសិនបើមានការលំបាក អំពីបេសកកម្មដែលខ្លួនបានទៅបំពេញ អង្គភាពសាធារណៈ ឬមន្ត្រីរាជការដែលចាត់តាំង ត្រូវជូនដំណឹងនេះទៅចៅក្រមស៊ើបសួរ នូវព្រឹត្តិការណ៍ ដែលបានកើតឡើងជាយថាហេតុ។ បន្ទាប់ពីបាន ចុះទៅបំពេញបេសកកម្មរួចរាល់ហើយ អង្គភាពសាធារណៈ ឬមន្ត្រីដែលត្រូវបានចាត់តាំង ត្រូវចម្លងជាលាយលក្ខណ៍អក្សរ នូវសម្លេងដែលបានថតនោះ និងត្រូវប្រគល់ជូនដល់ចៅក្រមស៊ើបសួរ ព្រមទាំងបិទស្លាកផងដែរ។ គ្រប់ពេលវេលានៃការស៊ើបសួរ

[64] មាត្រា ១៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ចៅក្រមស៊ើបសួរអាចចុះទៅដល់កន្លែងដែលធ្វើការចាប់ និងថតនោះ។ មានតែចៅក្រមស៊ើបសួរទេ ដែលអាចស្តាប់នូវសម្លេងតាមទូរស័ព្ទ ឬតាមបណ្តាព័ត៌មានបច្ចេកវិទ្យាផ្សេងៗ ដើម្បីបម្រើដល់ការ ស៊ើបសួរនៃសំណុំរឿងរបស់ខ្លួន។ ហើយចំពោះការស្តាប់ ឬថតសម្លឹងកជនជាការសម្ងាត់ ដោយ គ្មានការយល់ព្រមពីបុគ្គលនោះ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែទៅ ១ឆ្នាំ និងពិន័យជា ប្រាក់ពី ១សែនរៀលទៅដល់ ១លានរៀលផងដែរតាមមាត្រា ៣០១នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩។

កាលណាចៅក្រមស៊ើបសួរ ធ្វើកោសលវិច័យត្រូវបានបញ្ចប់ ចៅក្រមស៊ើបសួរត្រូវធ្វើរបាយ ការណ៍អំពីការកោសលវិច័យ ហើយត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរ អាចធ្វើ ការកោះហៅជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី ប្រាប់សេចក្តីសន្និដ្ឋានអំពី គោលការណ៍កោសល វិច័យនេះ។ ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិស្នើសុំឲ្យចៅក្រមស៊ើបសួរ ធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលច័យបន្ថែមក្នុងរយៈពេលមិនអាចតិចជាង ១០ថ្ងៃនោះទេ។ ក្នុងករណីប្រសិនបើមានការបដិសេធមិនធ្វើប្រតិកោសលវិច័យ ឬការធ្វើកោសលវិច័យបន្ថែមទេ ក្រោយពីទទួលបានពាក្យសុំពីព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរត្រូវសម្រេច ៥ថ្ងៃ និង ១ខែប្រសិនបើ បានទទួលពាក្យសុំពី ភាគីដើមបណ្តឹងរដ្ឋប្បវេណី និង ជនត្រូវចោទបើពុំដូច្នេះទេ អ្នកដាក់ពាក្យសុំ អាចធ្វើការប្តឹងឧទ្ធរណ៍ ដោយផ្ទាល់ដល់សភាស៊ើបសួរដើម្បី សម្រេចជំនួសចៅក្រមស៊ើបសួរ ។[65] បន្ទាប់ពីចៅក្រមស៊ើបសួរ បានអនុវត្តនីតិវិធីព្រហ្មទណ្ឌនៃការស្រាវជ្រាវរួចមក ចៅក្រមស៊ើបសួរនិង អនុវត្តនីតិវិធីនៃ វិធានការនិរន្តរាយបន្តទៀត មុននឹង បិទការស៊ើបសួរនៃសំណុំរឿងព្រហ្មទណ្ឌ។ **កំណត់ចំណាំ៖** នៅក្នុងការបំពេញភារកិច្ចរបស់ខ្លួន ចៅក្រមស៊ើបសួរ អាចចាត់អោយមានអ្នកស៊ើប សួរជំនួស ដោយដីការចាត់អោយស៊ើបសួរជំនួស តាមមាត្រា១៧៣ និងមាត្រា បន្តបន្ទាប់ដែល អនុញ្ញាតអោយចៅក្រមស៊ើបសួរ ប្រគល់សិទ្ធិដោយផ្នែកណាមួយនៃរឿងក្តីអោយស៊ើបសួរជំនួស។

## ផ្នែកទី៤៖ វិធានការនិរន្តរាយ

វិធានការនិរន្តរាយ[66] គឺជាវិធានការមួយដែលបង្កើតឡើងក្នុងក្របខ័ណ្ឌនៃការស៊ើបសួរ ដោយវិធានការនេះធានាបាននូវប្រសិទ្ធភាពក្នុងការស៊ើបសួរ និង ធានាការស៊ើបសួរដែលបាន ប្រព្រឹត្តទៅឲ្យល្អ។ ដូចនេះដើម្បីទទួលបានការអនុវត្ត ក្នុងក្របខ័ណ្ឌនៃការស៊ើបសួរឲ្យមានភាព ច្បាស់លាស់ នៅក្នុងរឿងក្តីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរគាត់អាចចេញដីកា ( ដីកាបង្គាប់ឲ្យចូលខ្លួន

[65] មាត្រា ១៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[66] និរន្តរាយមានន័យថាការមិនមានអន្តរាយដំណើរដែលមានគ្រោះថ្នាក់ (វចនានុក្រមខ្មែរសម្តេចសង្ឃរាជជួនណាត) ។

ដីកាបង្គាប់ឲ្យនាំខ្លួន ដីកាបង្គាប់ឲ្យចាប់ខ្លួន ដីកាបង្គាប់ឲ្យឃុំខ្លួន ) ដើម្បីឲ្យបុគ្គលនោះចូលមកដោះស្រាយ នូវចំពោះមុខតុលាការ។

**១.ដីកា**

ដីកា គឺជាបញ្ជាលាយលក្ខណ៍អក្សរចេញពីអាជ្ញាធរមានសមត្ថកិច្ច ដែលបង្គាប់ឲ្យចាត់ការនូវអំពើណាម្យ៉ាងជាពិសេស បញ្ជាដែលបង្គាប់ឲ្យចាប់ខ្លួនជនណាម្នាក់ ឬច្រើននាក់ដែលចេញដោយតុលាការ អង្គការ ឬមន្ត្រីរាជការណាម្នាក់។ ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឲ្យចូលខ្លួន ដីកាបង្គាប់ឲ្យនាំខ្លួន ដីកាបង្គាប់ឲ្យចាប់ខ្លួន និង ដីកាបង្គាប់ឲ្យឃុំខ្លួន ។

**១.១ ដីកាបង្គាប់ឲ្យចូលខ្លួន**

ដីកាបង្គាប់ឲ្យចូលខ្លួន គឺជាបញ្ជាដល់បុគ្គលណាម្នាក់ ឲ្យចូលទៅបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ។ ដីកានេះអាចចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានពិរុទ្ធភាពប៉ុណ្ណោះ។[67] ជាទូទៅដីកាបង្គាប់ឲ្យចូលខ្លួន គឺធ្វើឡើងនៅពេលដែលចៅក្រមស៊ើបសួរទទួលបាននូវសំណុំរឿងព្រហ្មទណ្ឌ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីសំណាក់ព្រះរាជអាជ្ញា។ ចំពោះនិទ្ទេសដែលត្រូវបានចុះលើដីកា បង្គាប់ឲ្យចូលខ្លួនមានដូចជា៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលត្រូវបានចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់និងបង្ក្រាបបទល្មើសនេះ
- ថ្ងៃ ខែ ឆ្នាំ ម៉ោងនិងទីកន្លែងដែលត្រូវចូលទៅបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ
- ឈ្មោះនិង ឋានៈរបស់ចៅក្រមដែលចេញដីកា។

ដីកាបង្គាប់ឲ្យចូលខ្លួនត្រូវមានចុះកាលបរិច្ឆេទ និង ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។[68] ដីកាបង្គាប់ឲ្យចូលខ្លួននេះ មិនមានវិធានការបង្ខំដល់ជនទាំងឡាយដែលត្រូវបានអញ្ជើញមកបំភ្លឺនោះទេ គឺជននោះមានសេរីភាពក្នុងការបង្ហាញខ្លួន។ ហើយដីកាបង្គាប់ឲ្យចូលខ្លួន ត្រូវបានអោយដំណឹងដល់បុគ្គលដែលពាក់ព័ន្ធដោយ មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬដោយអាជ្ញាសាលា។

នៅពេលដែលដីកានេះ បានចេញពីរដងទៅលើជនដែលមានឈ្មោះ ប៉ុន្តែជននោះមិនព្រមចូលមកបង្ហាញខ្លួនដើម្បីផ្តល់នូវចម្លើយជននោះ និងត្រូវទទួលបានការប្រើនូវវិធានបង្ខំ ដើម្បីឲ្យចូលខ្លួនឆ្លើយបំភ្លឺនៅតុលាការ។ ប្រសិនបើការចេញដីកាបង្គាប់ឲ្យចូលខ្លួន មិនអាចធ្វើឲ្យជនដែលទទួល

[67] មាត្រា ១៨៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[68] មាត្រា ១៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

បានដីកានោះ ចូលមកកាន់តុលាការ តាមការកំណត់ឲ្យចូលមកបង្ហាញខ្លួននោះទេ វាជាហេតុបណ្តាលឲ្យមានការចេញនូវ ដីកាបង្គាប់ឲ្យនាំខ្លួន។

### ១.២ ដីកាបង្គាប់ឲ្យនាំខ្លួន

ដីកាបង្គាប់ឲ្យនាំខ្លួន គឺជាបញ្ជាដល់កម្លាំងសាធារណៈ ឲ្យចាប់និងនាំខ្លួនបុគ្គលណាម្នាក់ ទៅចំពោះមុខចៅក្រមស៊ើបសួរ។ ដីកានេះត្រូវតែចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាពប៉ុណ្ណោះ។[69] ការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន ត្រូវបានប្រគល់ឲ្យមន្ត្រីនគរបាលយុត្តិធម៌ ដែលមានកាតព្វកិច្ចនាំខ្លួនបុគ្គលដែលពាក់ព័ន្ធ ទៅចំពោះមុខចៅក្រមស៊ើបសួរក្រោយពេលចាប់ខ្លួនបាន។ ប៉ុន្តែករណីដែលចៅក្រម មិនអាចសួរចម្លើយជន នោះភ្លាមៗ ឬដោយមូលហេតុនៃកាលៈទេសៈ បុគ្គលដែលពាក់ព័ន្ធមិនអាចត្រូវនាំទៅ បង្ហាញចំពោះមុខចៅក្រមស៊ើបសួរបានភ្លាមៗទេ ដីកានេះបានអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ នាំខ្លួនបុគ្គលដែលពាក់ព័ន្ធទៅរក្សាទុកនៅ អង្គភាពក្នុងមណ្ឌលឃុំខ្លួន ឬពន្ធនាគារដែលមានថិរៈវេលាមិនអាចលើសពី ១ថ្ងៃបានឡើយ ពោលគឺត្រូវនាំខ្លួនបុគ្គលដែលពាក់ព័ន្ធនេះ ទៅចំពោះមុខចៅក្រមស៊ើបសួរ ឬអ្នកជំនួសនៅថ្ងៃបន្ទាប់។ ផ្ទុយពីនេះ បើសិនជាការបង្ហាញខ្លួន មិនបានបង្ហាញខ្លួននៅថ្ងៃបន្ទាប់ទេ បុគ្គលដែលពាក់ព័ន្ធត្រូវបានដោះលែងឲ្យមានសេរីភាពវិញ។[70] ប្រការមួយទៀតដែលត្រូវ ជៀសវៀងដាច់ខាត់ ដើម្បីកុំឲ្យមានការរំលោភនូវសិទ្ធិបុគ្គល មន្ត្រីនគរបាលយុត្តិធម៌ ដែលអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន មិនអាចចូលទៅក្នុងលំនៅឋាន របស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង៦ ព្រឹកនិងក្រោយម៉ោង១៨ ល្ងាចបានទេ។ ដីកាបង្គាប់ឲ្យនាំខ្លួនមាននិទ្ទេសសំខាន់ៗជាអាទ៍ភាពដូចតទៅ៖

- អត្តសញ្ញាណនៃបុគ្គល ដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទដែលកំណត់ដោយច្បាប់
- ឈ្មោះនិងឋានៈរបស់ចៅក្រមដែលចេញដីកា។

ដីកាបង្គាប់ឲ្យនាំខ្លួន ត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។[71]

### ១.៣ ដីកាបង្គាប់ឲ្យចាប់ខ្លួន

ដីកាបង្គាប់ឲ្យចាប់ខ្លួន គឺជាបញ្ជាដល់កម្លាំងសាធារណៈឲ្យស្រាវជ្រាវរកចាប់ និងនាំបុគ្គល

[69] មាត្រា ១៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧
[70] មាត្រា ១៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
[71] មាត្រា ១៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ណាម្នាក់ទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន និងជាបញ្ជាដល់ពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ឲ្យទទួល និងឃុំខ្លួនបុគ្គលនោះ។ ចៅក្រមស៊ើបសួរដែលអាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួន ត្រូវគោរពលក្ខខណ្ឌមួយចំនួនដូចតទៅ៖

- ចេញបានទៅលើជនត្រូវចោទ និងបុគ្គលដែលមានតម្រុយពិរុទ្ធភាព
- បទល្មើសដែលត្រូវបានចោទប្រកាន់ ជាបទឧក្រិដ្ឋ ឬជាបទមជ្ឈិមដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ
- បុគ្គលដែលពាក់ព័ន្ធត្រូវបានគេចខ្លួន មិនដឹងជាស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា
- ចៅក្រមស៊ើបសួរត្រូវសុំយោបល់ពីព្រះរាជអាជ្ញាជាមុនសិន (ប៉ុន្តែយោបល់របស់ព្រះរាជអាជ្ញាមិនចងកាតព្វកិច្ចត្រូវតែឲ្យ ចៅក្រមស៊ើបសួរអនុវត្តនោះឡើយ)។

បន្ទាប់ពីទទួលបានយោបល់ពីព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរត្រូវចេញដីកាបង្គាប់ឲ្យចាប់ខ្លួន ដោយមានចែងមូលហេតុ ជាអាទិ៍៖ បានគេចខ្លួន ឬមិនដឹងជាស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជណាចក្រកម្ពុជា។ ដីកាបង្គាប់ឲ្យចាប់ខ្លួន ត្រូវបានប្រគល់ឲ្យមន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកអនុវត្តដីកានោះ ក្នុងរយៈពេលដ៏ខ្លីបំផុត។ ក្នុងករណីបន្ទាន់ ដីកាបង្គាប់ឲ្យចាប់ខ្លួន ត្រូវបានផ្សព្វផ្សាយទៅតាមអង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ។ ហើយនៅក្នុងករណីចាំបាច់ ដីកានេះ ត្រូវបានអនុវត្តការផ្សព្វផ្សាយជាអន្តរជាតិ តាមរយៈក្រសួងយុត្តិធម៌ ដោយប្រើយន្តការនានាដែលមានប្រសិទ្ធភាព។ បុគ្គលដែលពាក់ព័ន្ធ ត្រូវបានគេនាំខ្លួនទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួសចៅក្រមស៊ើបសួរនៅថ្ងៃបន្ទាប់ពីបានចាប់ខ្លួន។ ប្រសិនបើមិនបានអនុវត្តដូចករណីខាងលើទេ បុគ្គលដែលពាក់ព័ន្ធអាចធ្វើដូច្នេះ គឺត្រូវបានសួរចម្លើយដោយព្រះរាជអាជ្ញានៅ នឹងកន្លែងឃុំខ្លួន ហើយត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ នូវកំណត់ហេតុនៃការសួរចម្លើយនោះ។ នៅក្នុងការអនុវត្តនូវដីកាឲ្យចាប់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ ដែលអនុវត្តដីកានោះមិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែល ពាក់ព័ន្ធនៅមុនម៉ោង៦ ព្រឹក និងក្រោយម៉ោង១៨ល្ងាចបានទេ។

ជាទូទៅដីកាបង្គាប់ឲ្យចាប់ខ្លួន របស់ចៅក្រមស៊ើបសួរ អាចចេញបានតែទៅលើជនត្រូវចោទ ឬបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាពប៉ុណ្ណោះ។ ជនទាំងនោះ គឺជាជនទាំងឡាយណាដែលត្រូវបានព្រះរាជអាជ្ញាផ្តើមការចោទប្រកាន់ ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ មកចំពោះមុខចៅក្រមស៊ើបសួរតែប៉ុណ្ណោះ។ នេះមានន័យថា ដីកានេះមិនអនុវត្តទៅលើបុគ្គលណាផ្សេង

(សាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី ឬជនរងគ្រោះ) ក្រៅពីជនត្រូវចោទឡើយ។ ហើយដីកាបង្គាប់ឲ្យចាប់ខ្លួននេះ អាចមានកម្មវត្ថុក្នុងការផ្សព្វផ្សាយជាសាធារណៈ ជាតិ និង អន្តរៈជាតិ។

### ១.៤ ដីកាបង្គាប់ឲ្យឃុំខ្លួន

ដីកាបង្គាប់ឲ្យឃុំខ្លួន គឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ឲ្យទទួល និង ឲ្យឃុំខ្លួនជនត្រូវចោទ[72] រហូតទាល់តែបានទទួលដំណឹង អំពីការដោះលែងឲ្យមានសេរីភាពឡើងវិញ។ ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឲ្យឃុំខ្លួនបុគ្គលណាម្នាក់បាន លុះត្រាតែមានសេចក្ដីសម្រេចអំពីការឃុំខ្លួនបណ្ដោះអាសន្នជាមុនសិន ហើយបង្គាប់ឲ្យឃុំខ្លួនបាន លុះត្រាតែជនត្រូវចោទនោះ ជាកម្មវត្ថុនៃការសម្រេចឲ្យ ឃុំខ្លួនបណ្ដោះអាសន្នជាមុនសិន។ នៅក្នុងចំណុចនេះបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ តាមន័យនេះ ចៅក្រមស៊ើបសួរមិនអាចឃុំខ្លួនបុគ្គលណាម្នាក់ដោយមិនមាន ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ននោះឡើយ។ និទ្ទេសដែលត្រូវចុះក្នុងដីកាបង្គាប់ឲ្យឃុំខ្លួនមានដូចជា៖

- អត្តសញ្ញាណរបស់ជនត្រូវចោទ
- ប្រភេទបទល្មើសដែលត្រូវបានចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ឈ្មោះនិង ឋានៈរបស់ចៅក្រមដែលចេញដីកា។

ដីកាបង្គាប់ឲ្យឃុំខ្លួន ត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រា ។[73]

បន្ទាប់ពីតុលាការបានអនុវត្តនូវនីតិវិធី ដូចបានរៀបរាប់ខាងលើរួចមក យើងឃើញថាចៅក្រមស៊ើបសួរមានសមត្ថកិច្ចក្នុងការអនុវត្តនូវនីតិវិធីមួយចំនួនទៀតដូចជា (២) ការឃុំខ្លួនបណ្ដោះអាសន្ន និង (៣) ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ជាដើមក្នុងការស្វែងរកសច្ចៈភាពនៃយុត្តិធម៌។

### ២. ការឃុំខ្លួនបណ្ដោះអាសន្ន

ការឃុំខ្លួនបណ្ដោះអាសន្ន គឺជានីតិវិធីមួយដែលមានលក្ខណៈទប់ស្កាត់ របស់តុលាការក្នុងការអនុវត្តចំពោះជនត្រូវចោទដែលត្រូវបានចោទពីបទ ល្មើសព្រហ្មទណ្ឌ ណាមួយនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ការអនុវត្តនីតិវិធីនៃការឃុំខ្លួនបណ្ដោះ អាសន្ន

[72] មាត្រា ២២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[73] មាត្រា ២២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

បានធ្វើឲ្យកាត់ផ្តាច់នូវទំនាក់ទំនងជនដែលត្រូវបានឃុំខ្លួន និងសង្គមមួយរយៈ ហើយថែមទាំងបានរារាំងនូវសិទ្ធិខ្លះៗ របស់ប្រជាពលរដ្ឋដែលច្បាប់បានកំណត់។ ក្រោយពីជនត្រូវចោទ ត្រូវបានចៅក្រមស៊ើបសួរ ដាក់អោយស្ថិតនៅក្រោមការត្រួតពិនិត្យពីបទល្មើសណាមួយហើយនោះ ចៅក្រមស៊ើបសួរត្រូវសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន ឬយ៉ាងណា។[74] តាមមាត្រា២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានលើកឡើងអំពីគោលការណ៍នៃសេរីភាពរបស់ជនត្រូវចោទ មានន័យថាការឃុំខ្លួនបណ្តោះអាសន្ន ត្រូវតែជាករណីពិសេស ឬត្រូវមានមូលហេតុច្បាស់លាស់។

### ២.១ មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនបណ្តោះអាសន្នត្រូវតែមាន សំអាងហេតុ យោងតាមបញ្ញត្តិនៃមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ស្តីពីមូលហេតុនៃការឃុំខ្លួននេះ ដែលជាករណីពិសេស និងជាភាពចាំបាច់ដើម្បី៖

1) ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតមានជាថ្មី។
2) ដើម្បីរារាំងកុំឲ្យមានការគៀបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងរវាងជនត្រូវចោទ និងអ្នកសមគំនិត។
3) ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ។
4) ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី។
5) ដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ។
6) ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឲ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស។

### ២.២ លក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន

ជានិច្ចជាកាល ការឃុំខ្លួនបណ្តោះអាសន្ន អាចធ្វើទៅបាន លុះត្រាតែជនត្រូវចោទដែលជាកម្មវត្ថុនៃការឃុំខ្លួនបណ្តោះអាសន្ននោះ ត្រូវបានទទួលរងនូវការចោទប្រកាន់ពីបទឧក្រិដ្ឋ។ ចំពោះបទមជ្ឈិមវិញ ការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើទៅបាន លុះត្រាតែជនត្រូវចោទដែលជា កម្មវត្ថុនៃការឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានទទួលរងនូវការចោទប្រកាន់ពីបទមជ្ឈិមដែលច្បាប់កំណត់ ថិរៈវេលានៃការផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពីមួយឆ្នាំ។[75] ការឃុំខ្លួនបណ្តោះអាសន្នត្រូវបាន

[74] ទំព័រទី៤៦ នៃមេរៀននីតិវិធីព្រហ្មទណ្ឌ របស់លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ថាំង ស៊ីណាត ឆ្នាំ២០១៧-២០១៨

[75] មាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

សម្រេចដោយចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរអាចសម្រេចអំពីវិធាននេះ បន្ទាប់ពីទទួលបានសេចក្តីសន្និដ្ឋានប្តឹងសុំរបស់ព្រះរាជអាជ្ញា តាមរយៈដីការបស់គាត់ ឬដោយគំនិតរបស់ខ្លួនផ្ទាល់។

បន្ទាប់ពីចៅក្រមស៊ើបសួរ បានទទួលបណ្តឹងតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ដែលសុំឲ្យឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ននោះ ឬ មិនព្រមធ្វើការសុំឲ្យឃុំខ្លួននោះទេ ចៅក្រមស៊ើបសួរត្រូវចេញនូវដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន ក្នុងរយៈពេល ៥ថ្ងៃដោយមិនចាំបាច់មានសំអាងហេតុទេ។ ដីកានេះត្រូវជូនដំណឹងជាបន្ទាន់ដល់អ្នកប្តឹងសុំ។ ដោយឡែកកាលណាចៅក្រមមិនបានសម្រេច ក្នុងរយៈពេលដែលបានកំណត់ខាងលើនេះទេ តំណាងអយ្យការ អាចធ្វើការប្តឹងទៅសភាស៊ើបសួរ ដើម្បីធ្វើការសម្រេចជំនួសចៅក្រមស៊ើបសួរ។

### ២.៣ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានបែងចែកតាមចំណាត់ថ្នាក់នៃបទល្មើស ជាបីសណ្ឋានគឺ **ការឃុំខ្លួនបណ្តោះអាសន្នក្នុងបទឧក្រិដ្ឋ** ថិរវេលានៃការឃុំខ្លួន ត្រូវបានបែងចែកជាបីផ្នែក៖

**១.**នីតិជន ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៦ខែបានទេប៉ុន្តែនៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យាពេលបានពីរដងដោយក្នុងមួយដងៗ មានថិរវេលា៦ខែ។[76]

**២.**អនីតិជន អាយុ១៦ឆ្នាំដល់ក្រោម១៨ឆ្នាំ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៦ ខែបានទេ កាលណាផុតថិរវេលានេះ ចៅក្រមស៊ើបសួរមិនអាចពន្យាពេលនៃការឃុំខ្លួនបានឡើយ។

**៣.**អនីតិជន ដែលមានអាយុពី ១៤ឆ្នាំដល់ក្រោម ១៦ឆ្នាំថិរវេលានៃការឃុំខ្លួនមិនអាច លើសពី ៤ខែបានទេកាលបើផុតថិរវេលានេះ ចៅក្រមស៊ើបសួរមិនអាច ពន្យាពេលនៃការឃុំខ្លួនបណ្តោះអាសន្នបានឡើយ។[77]

**ការឃុំខ្លួនបណ្តោះអាសន្នក្នុងបទមជ្ឈិម** ថិរវេលានៃការឃុំខ្លួនក្នុងករណីនេះ ត្រូវបានគេធ្វើការបែងចែកជាបីផ្នែកដូចខាងក្រោម៖

**១.**នីតិជន ដែលត្រូវបានចោទប្រកាន់ពីបទ មជ្ឈិមមានថិរវេលានៃការឃុំខ្លួនមិនអាចលើសពី ៤ខែបានទេ ប៉ុន្តែកាលបើផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យាពេលនៃការឃុំខ្លួនមិនឲ្យលើសពី ២ ខែឡើយ ហើយបានតែម្តងគត់។ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន មិនត្រូវលើសពីពាក់កណ្តាលនៃអប្បរិមានៃទោសដែលច្បាប់បានកំណត់បានឡើយ។

[76] មាត្រា ២០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[77] មាត្រា ២១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

**២.**អនីតិជន ដែលមានអាយុ ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ ខែបានទេកាលបើផុតថិរវេលានេះចៅក្រមស៊ើបសួរ មិនអាចធ្វើការពន្យាពេលបានទេ។

**៣.**អនីតិជន ដែលមានអាយុ ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ ការឃុំខ្លួនបណ្ដោះអាសន្ន មិនអាចលើសពី ២ខែបានទេ កាលបើផុតថិរវេលានេះ ចៅក្រមស៊ើបសួរមិនអាចពន្យាពេលនៃការឃុំខ្លួនបណ្ដោះអាសន្នបានឡើយ។

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នតាមចំណុចទី២ និង ទី៣ ខាងលើនេះមិនត្រូវលើសពីពាក់កណ្ដាលអប្បបរមានៃទោសដាក់ពន្ធនាគារបានឡើយ ។

**ការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន មិនអាចលើសពី ១ឆ្នាំ បានទេ ចំពោះបទល្មើសនីមួយៗប៉ុន្តែអាចពន្យាពេលបានពីរដង ដោយមួយដងៗ មានថិរវេលា ១ឆ្នាំ។

- នៅក្នុងករណី ដែលជនត្រូវចោទជាប់ឃុំខ្លួនជាបណ្ដោះអាសន្ន ក្រមនីតិវិធីព្រហ្មទណ្ឌបានសម្រេចដោះលែងអោយនៅក្រៅឃុំវិញតាមវិធីបីយ៉ាងគឺ៖
  - តាមការផ្ដួចផ្ដើមរបស់ចៅក្រមស៊ើបសួរ (មាត្រា២១៥)
  - តាមការផ្ដួចផ្ដើមរបស់ព្រះរាជអាជ្ញា (មាត្រា២១៦)
  - តាមបណ្ដឹងរបស់ជនត្រូវចោទ (មាត្រា២១៧) ។

### ២.៤ អានុភាពនៃការឃុំខ្លួនបណ្ដោះអាសន្ន

អានុភាពនៃការឃុំខ្លួនបណ្ដោះអាសន្ន ប្រែប្រួលទៅតាមស្ថានភាពដែលកើតមានបន្ត ដូចជាក្នុងករណីដែលមានការផ្ដន្ទាទោសដាក់ពន្ធនាគារ ការឃុំខ្លួនបណ្ដោះអាសន្ន គឺរាប់បញ្ចូលដោយស្វ័យប្រវត្តិនៅពេលសាលក្រមស្ថាពរ។

## ៣. ការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទ ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ប្រសិនបើជនត្រូវចោទនេះត្រូវបានចោទប្រកាន់អំពីបទល្មើសព្រហ្មទណ្ឌ ផ្ដន្ទាទោសដាក់ពន្ធនាគារតាមច្បាប់កំណត់ជាធរមាន។

### ៣.១. ការជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ

បុគ្គលណាម្នាក់ត្រូវបាន ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ តាមផ្លូវតុលាការ មានពាក់ព័ន្ធ

និងការបង្ហាញខ្លួនជាលើកដំបូងរបស់ជនត្រូវចោទ។ ក្នុងករណីនេះ ជនត្រូវចោទមានសេរីភាពក្នុងការជ្រើសរើសមេធាវី ជាពិសេសសម្រាប់អនីតិជនជាដាច់ខាតត្រូវតែមានមេធាវី។[78]

ចំពោះបុគ្គលដែលត្រូវបានដាក់ឲ្យ ធ្វើការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជាជនទាំងឡាយណាដែលមានកំណត់នៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[79] របស់ព្រះរាជអាជ្ញា ឬតាមដីកាឲ្យស៊ើបសួរបន្ថែម[80] ហើយវាក៏អាចសម្រេចបានតាមរយៈ ដីកាបង្គាប់ដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរបស់ចៅក្រមស៊ើបសួរ។[81] ផ្ទុយទៅវិញការអនុវត្តនីតិវិធីនៃ ការត្រួតពិនិត្យតាមផ្លូវតុលាការ មិនអាចធ្វើបានឡើយចំពោះអនីតិជនក្រោមអាយុ ១៤ ឆ្នាំនោះ។[82]

### ៣.២. នីតិវិធីនៃការត្រួតពិនិត្យតាមផ្លូវតុលាការ

ជាក់ស្ដែងនៅក្នុងនីតិវិធីនេះ ចៅក្រមស៊ើបសួរ គាត់អាចពិនិត្យអំពីអត្តសញ្ញាណរបស់ជនត្រូវចោទ នីតិវិធីបែបនេះហើយដែលធ្វើឲ្យ ចៅក្រមស៊ើបសួរអាចប្រាប់រឿងរ៉ាវដែលចោទប្រកាន់ដល់ជននោះ ព្រមទាំងប្រាប់អំពីឈ្មោះនៃបទល្មើសដែលកំណត់ដោយច្បាប់ និងប្រាប់អំពីសិទ្ធិរបស់ខ្លួន ដោយខ្លួនមានសិទ្ធិក្នុងការឆ្លើយឬ មិនឆ្លើយ។ ក្នុងករណីដែលជនត្រូវចោទចង់ឆ្លើយនោះ ចៅក្រមស៊ើបសួរត្រូវទទួលចម្លើយនោះភ្លាម។ និទ្ទេសស្ដីពីការប្រាប់នេះ ត្រូវចុះនៅក្នុងកំណត់ស្ដីពីការបង្ហាញខ្លួនលើកដំបូង។

ក្រោយពីចូលបង្ហាញខ្លួនលើកទី១ ជនត្រូវចោទដែលនៅក្រៅឃុំ ត្រូវប្រកាសប្រាប់ដល់ចៅក្រមស៊ើបសួរ អំពីអាសយដ្ឋានរបស់ខ្លួន។ ជនត្រូវចោទនេះត្រូវបានទទួលដំណឹងថា៖

- ខ្លួនត្រូវតែជូនព័ត៌មានដល់ចៅក្រមស៊ើបសួរ នៅពេលដែលខ្លួនផ្លាស់ប្ដូរអាសយដ្ឋាន
- គ្រប់ការឲ្យដំណឹងដែលបានធ្វើតាមអាសយដ្ឋានចុងក្រោយ ដែលប្រកាសឡើងដោយជនត្រូវចោទនោះត្រូវចាត់ទុកថាធ្វើឡើងដោយសាមីខ្លួនផ្ទាល់។
- ម្យ៉ាងទៀត ការត្រួតពិនិត្យតាមផ្លូវតុលាការ អាចដាក់ជនត្រូវចោទ ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ប្រសិនបើជនត្រូវចោទនោះ ត្រូវបានចោទប្រកាន់អំពីបទល្មើសដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ។

[78] មាត្រា ១៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[79] មាត្រា ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[80] មាត្រា ១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[81] មាត្រា ២២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[82] មាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ការដាក់ឲ្យជនណាម្នាក់ស្ថិតក្នុង ការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវបានធ្វើឡើងដោយផ្ទាល់ខ្លួនរបស់ចៅក្រមស៊ើបសួរ ឬ តាមរយៈដីកាសន្និដ្ឋានសរុបរបស់ព្រះរាជអាជ្ញា។ ហើយការសម្រេចដាក់ជនណាម្នាក់ ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវបានធ្វើឡើងតាមរយៈ **ដីកាបង្គាប់ឲ្យដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ** ដូចដែលមានចែងនៅក្នុងមាត្រា ២២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧។ ម្យ៉ាងទៀតជនត្រូវចោទ ទទួលបាននូវឯកសារបញ្ជាក់អំពីអត្តសញ្ញាណ អំពីប្រាក់ធានា ឬអាវុធ។ ហើយចំពោះបង្កាន់ដៃប្រគល់ឯកសារ បញ្ជាក់អំពីអត្តសញ្ញាណត្រូវបានចុះហត្ថលេខាដោយក្រឡាបញ្ជី។ បង្កាន់ដៃនៃប្រាក់ធានា ឬ អាវុធត្រូវបានចុះហត្ថលេខារួមដោយប្រធានតុលាការ ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ចំពោះប្រាក់ធានាត្រូវបានតម្កល់ទុកនៅធានាគា ឬត្រូវបានរក្សាទុកនៅកន្លែងដែលមានសុវត្ថិភាព ចំណែកឯ អាវុធត្រូវបានរក្សាទុកនៅកន្លែងដែលមានសន្តិសុខល្អ។[83] ចៅក្រមស៊ើបសួរអាចកែ ប្រែខ្លឹមសារនៃកាតព្វកិច្ច ឬអាចលុបចោល ឬបញ្ចូលឯកទេសថ្មីបានគ្រប់ពេលវេលា។[84]

ទន្ទឹមនឹងនេះផងដែរ ការត្រួតពិនិត្យតាមផ្លូវតុលាការ មានអានុភាពបង្គាប់ឲ្យជនត្រូវចោទនៅក្រៅឃុំឲ្យគោរព នូវកាតព្វកិច្ចមួយ ឬច្រើនដូចតទៅ៖

1. មិនត្រូវចេញទៅក្រៅព្រំប្រទល់ដែលកំណត់ដោយចៅក្រមស៊ើបសួរ។
2. មិនត្រូវផ្លាស់ប្តូលំនៅឋានដោយគ្មានការអនុញ្ញាតដោយចៅក្រមស៊ើបសួរ។
3. មិនត្រូវទៅកាន់ទីកន្លែងដែលកំណត់ដោយចៅក្រមស៊ើបសួរ។
4. ត្រូវចូលបង្ហាញខ្លួនតាមការកំណត់របស់អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។
5. ត្រូវឆ្លើយតប នឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។
6. ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីនូវឯកសារបញ្ជាក់អត្តសញ្ញាណ។
7. មិនត្រូវបើកបររថយន្ត។
8. មិនត្រូវទទួលឬ ជួបបុគ្គលមួយចំនួនដែលបានចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ។
9. ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានា និងថេរវេលាបង់ប្រាក់នេះ ត្រូវកំណត់ដោយចៅក្រមស៊ើបសួរដោយផ្អែកលើធនធានរបស់ជនត្រូវចោទ។

[83] មាត្រា ១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[84] មាត្រា ២២៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

10. មិនត្រូវកាន់កាប់ ឬយកតាមនូវអាវុធជាប់ខ្លួន។ ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជី នូវអាវុធដែលជនត្រូវចោទកាន់កាប់។
11. ត្រូវប្រគល់ឲ្យ ពេទ្យពិនិត្យព្យាបាល និងជាយថាហេតុ ដាក់ឲ្យស្ថិតនៅក្រោមរបបព្យាបាលរោគនៅមន្ទីរពេទ្យ។
12. មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈ។

ដើម្បីអនុវត្តចំណុចទាំង១២ ខាងលើចៅក្រមស៊ើបសួរ មិនអាចហាមឃាត់ការអនុវត្តនូវអាណត្តិបោះឆ្នោត ឬសកម្មភាពខាងសហជីពបានទេ។[85]

### ៣.៣ អានុភាពនៃការត្រួតពិនិត្យតាមផ្លូវតុលាការ

ការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលត្រូវបានដាក់ដោយកាតព្វកិច្ចរបស់ចៅក្រមស៊ើបសួរ។ ហេតុនេះ ការគេចវេះពីកាតព្វកិច្ចដោយចេតនា អាចនិងត្រូវដាក់ទណ្ឌកម្ម។ ក្នុងករណីនេះមាត្រា ២៣០ បានអនុញ្ញាតឲ្យចៅក្រមស៊ើបសួរ នោះឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្នបាន ទោះបីជាទោសដែលត្រូវរងនោះ មានថិរៈវេលាប៉ុន្មានក៏ដោយ ហើយទោះបីជាជនដែលត្រូវបានជាប់ឃុំបណ្ដោះអាសន្នអស់រយៈពេល អតិបរមាដូចដែលមានចែង នៅក្នុងនីតិវិធីនេះក៏ដោយ ។ ប៉ុន្តែរយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងករណីនេះ ៤ ខែសម្រាប់នីតិជន ហើយ ២ខែ យ៉ាងយូរសម្រាប់អនីតិជន ដោយពុំមានការបែងចែកបទល្មើសដែលត្រូវចោទប្រកាន់ទេ។[86]

## ផ្នែកទី៥៖ ការបិទការស៊ើបសួរ

កាលណាចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរត្រូវបានបញ្ចប់ នោះចៅក្រមស៊ើបសួរត្រូវតែជូនអំពីព័ត៌មាននេះទៅដល់ ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវី ដើម្បីឲ្យបានដឹង អំពីនីតិវិធីនេះ។

### ១.ដំណាក់កាលបឋម

#### ១.១ ការជូនព័ត៌មាន

យោងទៅលើមាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បានបញ្ញត្តិទាំងរូបមន្តនៃលិខិតជូនពត៌មាន អំពីការបិទបញ្ចប់នៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ តាមនីតិវិធីនៃការធ្វើសេចក្តីជូនដំណឹងនេះ ហើយគាត់ត្រូវធ្វើលិខិតជូនដំណឹងនេះទៅតំណាងអយ្យការ ដោយមានការបញ្ជាក់អំពីការបិទបញ្ចប់នៃការស៊ើបសួរ។ ជាងនេះទៅទៀត ការជូនដំណឹងអំពីការសម្រេចបិទ

[85] មាត្រា ២២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[86] មាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

បញ្ចប់នៃការស៊ើបសួរ ដល់ភាគីដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីរបស់ខ្លួន ព្រមទាំងភាគីរដ្ឋប្បវេណីរបស់ជនត្រូវចោទ និងមេធាវី ដោយនីតិវិធីនេះត្រូវតែមានការបញ្ជាក់ ឲ្យបានច្បាស់លាស់អំពីអ្នកដែលប្រគល់ និងអ្នកដែលទទួលនៃលិខិតជូនដំណឹងនេះ ហើយក៏ត្រូវមានការចុះហត្ថលេខា ឬស្នាមម្រាមដៃផងដែរ។

### ១.២ ការបញ្ជូនសំណុំរឿងឲ្យព្រះរាជអាជ្ញា

ការបញ្ជូនសំណុំរឿងទៅឲ្យព្រះរាជអាជ្ញា ត្រូវតែធ្វើឡើង ២ថ្ងៃ ក្រោយពីមានការបិទបញ្ចប់នៃការស៊ើបសួរ។ តាមរយៈនីតិវិធីនេះ ប្រសិនបើព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី មេធាវី មានសិទ្ធិស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែប ចៅក្រមស៊ើបសួរត្រូវតែសម្រេចអំពីបញ្ហានេះ។[87] ក្រោយពីមានការស៊ើបសួរបន្ថែម ត្រូវបានបញ្ចប់សព្វគ្រប់ហើយ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពី ការបញ្ចប់ការស៊ើបសួរម្ដងទៀត។

### ១.៣ ដីកាស្ថាពររបស់ព្រះរាជអាជ្ញា

ហើយបន្ទាប់មក ព្រះរាជអាជ្ញាត្រូវតែបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ ដោយមាន **ដីកាសន្និដ្ឋានស្ថាពរ** ភ្ជាប់មកជាមួយផងក្នុងរយៈពេល ១៥ ថ្ងៃបើជនត្រូវចោទត្រូវបានឃុំខ្លួននិងរយៈពេល ១ ខែបើជនត្រូវចោទនៅក្រៅឃុំ គិតពីថ្ងៃដែលព្រះរាជអាជ្ញាទទួល បានសំណុំរឿង។ ហើយចំពោះដីកាសន្និដ្ឋានស្ថាពរ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ នៅក្នុងដីកាសន្និដ្ឋានស្ថាពរ ព្រះរាជអាជ្ញាអាចប្ដឹងសុំអោយ ចៅក្រមស៊ើបសួរបញ្ជូនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះ ឬក៏លើកលែងបទចោទប្រកាន់។

## ២. នីតិវិធីចុងក្រោយនៃការស៊ើបសួរ

ក្រោយពីបានទទួលដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា ដោយមានការប្ដឹងឲ្យចៅក្រមស៊ើបសួរ គាត់បញ្ជូនរឿងទៅជំនុំជម្រះ ឬក៏លើកលែងការចោទប្រកាន់ក៏ដោយ ចៅក្រមស៊ើបសួរគាត់មានសិទ្ធិអំណាចឯករាជ្យ ដែលមានន័យថា ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញានេះ មិនមានការចងកាតព្វកិច្ចគាត់ ត្រូវតែអនុវត្តតាមបណ្ដឹងរបស់ស្ថាប័នអយ្យការនោះទេ។

### ២.១. ការលើកលែងបទចោទប្រកាន់

ចៅក្រមស៊ើបសួរ ចេញដីកាលើកលែងការចោទប្រកាន់ នៅក្នុងករណីដូចតទៅ៖

- អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុ។

[87] មាត្រា ១៣២ ដល់មាត្រា ១៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

- ជនដែលប្រព្រឹត្តអំពើនោះនៅតែមិនស្គាល់។
- គ្មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកទៅលើជនត្រូវចោទ
- ដីកាដំណោះស្រាយជានិច្ចកាលត្រូវតែមានសំអាងហេតុ។[88]

កាលណាចៅក្រមស៊ើបសួរ ចេញដីកាលើកលែងការចោទប្រកាន់នោះ ចៅក្រមស៊ើបសួរដកសមត្ថកិច្ចរបស់ខ្លួនឯងពីសំណុំរឿង និងបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ និងការឃុំខ្លួនបណ្តោះអាសន្ន។ កាលណាចៅក្រមស៊ើបសួរ សម្រេចឲ្យដោះលែងជនត្រូវចោទ ដែលជាប់ឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទនោះត្រូវបានរក្សាទុកនៅក្នុងពន្ធនាគារ រហូតដល់ផុតរយៈពេលសម្រាប់បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា លើកលែងតែព្រះរាជអាជ្ញាយល់ព្រមឲ្យដោះលែង ជនត្រូវចោទនោះភ្លាម។[89] ក្នុងករណីដែល ព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍ អំពីដីកាលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរ ជនត្រូវចោទដែលជាប់ឃុំត្រូវរក្សាទុកនៅក្នុងពន្ធនាគារ រហូតដល់រយៈពេលដែលសភាស៊ើបសួរ សម្រេចអំពីបណ្តឹងឧទ្ធរណ៍នោះ។[90]

នៅក្នុងករណីដែល សភាស៊ើបសួរសម្រេចបន្តការស៊ើបសួរដោយខ្លួនឯង ទៀតនោះសភាស៊ើបសួរប្រគល់ភារកិច្ចទៅសមាជិករបស់ខ្លួនម្នាក់ ដែលប្រើប្រាស់អំណាចជាចៅក្រមស៊ើបសួរ។ កាលណាការស៊ើបសួរត្រូវបានបញ្ចប់ សំណុំរឿងនៃនីតិវិធីត្រូវបាន តម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។ ប្រធាននៃសភាស៊ើបសួរត្រូវកំណត់ អំពីកាលបរិច្ឆេទនៃសវនាការ។ សភាស៊ើបសួរបិទបញ្ចប់នៃការស៊ើបសួរ តាមសាលដីកាដំណោះស្រាយ។ ក្នុងករណីដែល សភាស៊ើបសួរសម្រេច ដោះលែងជនត្រូវចោទដែលជាប់ឃុំ សេចក្តីសម្រេចនោះត្រូវមានអានុភាពអនុវត្តភ្លាម។[91] ដើមបណ្តឹងរដ្ឋប្បវេណី អាចធ្វើបណ្តឹងឧទ្ធរណ៍ពីដីកា លើកលែងការចោទប្រកាន់ និងដីកានានាមួយចំនួនទៀតរបស់ចៅក្រមស៊ើបសួរ។ ក្រោយពេលដែល ដីកាលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរ ឬសាលដីកាលើកលែងការចោទប្រកាន់របស់សភាស៊ើបសួរ បានចូលជាស្ថាពរហើយ ប្រសិនបើមានលេចចេញនូវបន្ទុកភស្តុតាងថ្មីឡើង ការស៊ើបសួរអាចបើកផ្តើមវិញដោយតំណាងអយ្យការ។[92]

---

[88] មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧
[89] មាត្រា ២៧៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧
[90] មាត្រា ២៧៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧
[91] មាត្រា ២៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧
[92] មាត្រា ២៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

### ២.២. ដីកាបញ្ជូនរឿងទៅជំនុំជម្រះ

បន្ទាប់ពីចៅក្រមស៊ើបសួរ បានបញ្ចប់នូវនីតិវិធីក្នុងការស៊ើបសួររបស់ខ្លួនហើយ ព្រមទាំងយល់ថា សំណុំរឿងមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ចំពោះអំពើល្មើសជា បទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុ នោះចៅក្រមស៊ើបសួរចេញដីកាបញ្ជូនទៅជំនុំជម្រះនៅសវនាការ។ ដីកាត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និង ឈ្មោះបទល្មើសតាមច្បាប់។

ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ត្រូវបានដកសមត្ថកិច្ចរបស់ចៅក្រមដែលធ្វើការស៊ើបសួរនៃសំណុំរឿងនោះ ដោយមិនអាចទៅធ្វើជាចៅក្រមជំនុំជម្រះទៀតបានទេ។ ដីកានេះបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ និងការឃុំខ្លួនបណ្តោះអាសន្ន។ ប៉ុន្តែយោងតាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ និងក្រោមលក្ខខណ្ឌមួយចំនួន ចៅក្រមស៊ើបសួរអាចរក្សាជនត្រូវចោទឲ្យនៅជាប់ឃុំរហូតដល់ពេល ចូលបង្ហាញខ្លួននៅមុខតុលាការនៃ ចៅក្រមជំនុំជម្រះ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវមានសំអាងហេតុ ទៅលើសេចក្តីសម្រេចរក្សាជនត្រូវចោទឲ្យនៅក្នុងឃុំ ដោយមូលហេតុណាមួយក្នុងចំណោមមូលហេតុទាំងអស់ ដូចជា៖ ដើម្បីបញ្ចប់បទល្មើស ឬដើម្បីបង្ការ និងទប់ស្កាត់បទល្មើសកុំឲ្យកើតឡើងជាថ្មី រារាំងកុំឲ្យមានការគាបសង្កត់លើសក្សី ឬជនរងគ្រោះ ឬរារាំងកុំឲ្យមានការត្រូវរូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត ដើម្បីធានារក្សាទុកជនត្រូវចោទជូនតុលាការចាត់ការតាមនីតិវិធីច្បាប់ ដើម្បីការពារជនត្រូវចោទ ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈកុំឲ្យមាន ភាពច្របូកច្របល់ដែលបណ្តាលមក ពីបទល្មើស។[93] ចំណែកឯ សេចក្តីសម្រេចរក្សាជនត្រូវចោទក្នុងការ ឃុំខ្លួនបណ្តោះអាសន្នលែងមានអានុភាព ក្នុងរយៈពេល៤ខែ ប្រសិនបើជនត្រូវចោទមិនត្រូវបាននាំចូលទៅចំពោះមុខចៅក្រមជំនុំជម្រះ ក្នុងរយៈពេល៤ខែនោះទេ ជនត្រូវចោទត្រូវបានដោះលែងឲ្យនៅក្រៅឃុំដោយឯកឯង។[94] ក្នុងករណីដែលចៅក្រមស៊ើបសួរ ចេញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងនោះ ទៅប្រធានតុលាការជាបន្ទាន់ ដើម្បីកំណត់ពេលក្នុងការបើកសវនាការជំនុំជម្រះ។[95]

[93] មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[94] មាត្រា ១៨៩-៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[95] មាត្រា ២៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី **ការបញ្ជូនរឿងទៅស៊ើបសួរ** យើងឃើញថានីតិវិធីនេះទាមទារឲ្យ ការអនុវត្តនីតិវិធីប្រព្រឹត្តទៅប្រកបដោយភាពហ្មត់ចត់ និង ការទទួលខុសត្រូវខ្ពស់បំផុត នៅក្នុងនោះរួមមានមុន និងធ្វើការបញ្ជូនរឿងទៅស៊ើបសួរ ចាំបាច់ត្រូវតែមានការចោទប្រកាន់ពីព្រះរាជអាជ្ញាជាមុនសិន។ ដោយនៅក្នុងដំណាក់កាលនៃការចោទប្រកាន់នេះ ព្រះរាជអាជ្ញាត្រូវតែពិនិត្យទៅលើលក្ខខណ្ឌនៃបទល្មើសព្រហ្មទណ្ឌជាមុន ដូចថាតើបទល្មើសជាប្រភេទនៃបទល្មើសអ្វីដូចជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ទៅតាមការកំណត់របស់នីតិវិធីច្បាប់នីមួយៗ ទើបព្រះរាជអាជ្ញាមានសិទ្ធិក្នុងការសម្រេចចិត្តចោទប្រកាន់ ឬមិនចោទប្រកាន់នៃបទល្មើសព្រហ្មទណ្ឌបាន។ ក្នុងករណីដែលព្រះរាជអាជ្ញាមិនធ្វើការចោទប្រកាន់ទេ គឺគាត់អនុវត្តនីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ ប៉ុន្តែប្រសិនបើព្រះរាជអាជ្ញាគាត់សម្រេចចោទប្រកាន់វិញនោះ គាត់ត្រូវជ្រើសរើស អនុវត្តនូវលំហូនីតិវិធីចំនួនបីគឺ នីតិវិធីនៃការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ឬក៏ការបង្ហាញខ្លួនភ្លាម និងនីតិវិធីនៃការបើកការស៊ើបសួរ ហើយចំពោះការបើកការស៊ើបសួរ គឺព្រះរាជអាជ្ញាធ្វើឡើងតាមរយៈ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ទៅកាន់ស្ថាប័ននៃចៅក្រមស៊ើបសួរ។

ហើយបន្ទាប់ពីចៅក្រមស៊ើបសួរ ទទួលបាននូវសំណុំរឿងពីការចាត់តាំង និង ការបែងចែក ហើយនោះ ចៅក្រមស៊ើបសួរត្រូវតែពិនិត្យទៅលើបទល្មើសជាមុនសិន បន្ទាប់មកទៀតគឺគាត់ត្រូវតែបើកការស៊ើបសួរ។ ការបើកការសស៊ើបសួរ ជំហ៊ានបន្ទាប់នេះគឺធ្វើការស្រាវជ្រាវទៅលើបទល្មើសដែលការស្រាវជ្រាវនោះគឺស្រាវជ្រាវទាក់ទងនិងបុគ្គល ដែលមានដូចជា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សីជាដើម។ ហើយការស៊ើបសួរទាក់ទងនិងភស្តុតាងវិញគឺ មានការស្វែងរកភស្តុតាង វាយតម្លៃនៃភស្តុតាង ការធ្វើកោសវិច័យ និងការស្តាប់ទូរស័ព្ទជាដើម រហូតដល់ដំណាក់កាលនៃការចេញនូវវិធានការនិរន្តរាយ របស់ចៅក្រមស៊ើបសួរ។ ហើយនូវក្នុងកិច្ចនៃនីតិវិធីនេះ តុលាការអាចឃុំខ្លួនជនត្រូវចោទតាមការកំណត់បទល្មើសរបស់ច្បាប់ ឬដាក់ជននោះឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ទើបអាចឈានដល់ដំណាក់កាលនៃការបិទការស៊ើបសួរ។ នៅពេលបិទការស៊ើបសួរនេះ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងជាបឋមដល់ ព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី និងជនត្រូវចោទអំពីការបិទការស៊ើបសួររបស់ខ្លួន។ ចៅក្រមស៊ើបសួរ នៅពេលដែលបញ្ចប់នីតិវិធីរបស់ខ្លួននោះ គាត់សម្រេចសេចក្តីក្នុងការលើកលែងបទចោទប្រកាន់នៃបទល្មើស ឬបញ្ជូនរឿងទៅជំនុំជម្រះ នៅចៅក្រមជំនុំជម្រះនៃតុលាការមានសមត្ថកិច្ច។

យើងសង្កេតឃើញថានីតិវិធីនេះ វាហាក់បីដូចជាមានភាពស្មុកស្មាញបន្តិចមែន ប៉ុន្តែវាបានបង្ហាញឲ្យយើងឃើញកាន់តែមានភាពច្បាស់លាស់ពី ការអនុវត្តនីតិវិធីរបស់តុលាការមុន និងធ្វើការជំនុំជម្រះថាជនណាម្នាក់មានទោស ឬគ្មានទោសនៃបទល្មើសព្រហ្មទណ្ឌ។ ពីព្រោះថាគ្រប់ដំណាក់កាលដែលនីតិករខ្មែរយើងបានបញ្ញត្តិឡើង គឺដើម្បីធ្វើកិច្ចនីតិវិធីនីមួយៗ ឲ្យមានតម្លាភាព សច្ចៈធម៌ យុត្តិធម៌ ក្នុងការដោះស្រាយ និងទទួលយកបានទាំងគ្រប់ភាគីនៃវិវាទដែលកើតឡើង ហើយមិនត្រឹមតែប៉ុណ្ណោះទេ សំណុំរឿងព្រហ្មទណ្ឌបានអនុញ្ញាតឲ្យតុលាការស្វែងរកជនណាដែលបង្កបញ្ហាដល់សង្គមយ៉ាងពិតប្រាកដ និងចាប់ជននោះមកផ្តន្ទាទោសតាមច្បាប់ជាធរមាន។ ជាក់ស្តែងណាស់ចំពោះនីតិវិធីនៃ **ការបញ្ជូនរឿងទៅស៊ើបសួរ** នេះមានស្ថាប័នចៅក្រមស៊ើបសួរ ជាចម្បងមកចូលរួមក្នុងការដោះស្រាយ និងស៊ើបសួរតាមរយៈការស្រាវជ្រាវ ព្រមទាំងបានធ្វើឲ្យសំណុំរឿងនៃរឿងក្តីព្រហ្មទណ្ឌត្រូវបានតុលាការធ្វើការជំនុំជម្រះបាន ដោយមិនខុសនឹងនីតិវិធីជាធរមាន។ ជាការពិតណាស់ ការអនុវត្តនូវនីតិវិធីដើម្បីទទួលបាន យុត្តិធម៌ព្រហ្មទណ្ឌ គឺតម្រូវឲ្យមានការដោះស្រាយដោយត្រឹមត្រូវទៅតាមច្បាប់នីតិវិធីព្រហ្មទណ្ឌជាធរមាន ហើយមិនអាចឲ្យជនណាម្នាក់ទទួលរងនូវការឈឺចាប់ ឬភាពអយុត្តិធម៌នោះទេ ពោលគឺការអនុវត្តច្បាប់ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវបានធ្វើឡើងដោយមិនមានការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។

សរុបសេចក្តីមក **ការបញ្ជូនរឿងទៅស៊ើបសួរ** នេះពិតជាមានសារៈសំខាន់ខ្លាំងណាស់ ដែលអាចឲ្យរឿងក្តីមួយមានភាពពេញលេញនៃដំណោះស្រាយ ហើយឲ្យបង្ហាញពីការពិតចំពោះអំពើល្មើស ដើម្បីស្វែងរកចាប់ជននោះមកដាក់ទោសតាមច្បាប់ និងមានភាពយុត្តិធម៌ក្នុងសង្គមក៏ដូចជាជនរងគ្រោះផងដែរ។ ការដែលរឿងមួយត្រូវបានបញ្ជូនទៅកាន់ស្ថាប័ននៃចៅក្រមស៊ើបសួរបាន វាចាំបាច់ណាស់ត្រូវតែមានការឯកភាពពីព្រះរាជអាជ្ញាតាមរយៈ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរជាមុនសិន ហើយចំពោះការអនុវត្តការងាររបស់ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរគឺធ្វើឡើងយ៉ាងយកចិត្តទុកដាក់ និងអត់ធ្មត់បំផុតពីបុគ្គលទាំងនោះជាពិសេសគឺចៅក្រមស៊ើបសួរ។ ម្យ៉ាងវិញទៀតក៏ត្រូវមានការប្រុងប្រយ័ត្នខ្ពស់ផងដែរ ចំពោះការស៊ើបសួរខ្លះអាចធ្វើឲ្យមានភាពលំបាកដល់អ្នកស៊ើបសួរ ប៉ុន្តែដើម្បីឲ្យមានជំនឿលើប្រព័ន្ធតុលាការ និងបង្ហាញពីភាពច្បាស់លាស់របស់ខ្លួនបានចាំបាច់ណាស់ត្រូវធ្វើតាមនីតិវិធីដែលមានចែងជាធរមាន។ ទោះបីជាយ៉ាងណាក៏ដោយ យើងខ្ញុំសូមធ្វើការគាំទ្រឲ្យមានកិច្ចនីតិវិធីនៃការបញ្ជូនរឿងទៅស៊ើបសួរនេះ ដែលត្រូវបានអនុវត្តឡើងដោយព្រះរាជអាជ្ញានិងចៅក្រមស៊ើបសួរមុនធ្វើការបញ្ជូនរឿងក្តីនោះទៅសវនាការ។

# អនុសាសន៍

៦.២

ឆ្លងតាមការសិក្សាស្រាវជ្រាវអំពីនីតិវិធីនៃ " **ការបញ្ជូនរឿងទៅស៊ើបសួរ** " ដែលធ្វើឡើងដោយព្រះរាជអាជ្ញា ទៅកាន់ចៅក្រមស៊ើបសួរ ខ្ញុំសង្កេតឃើញថានីតិវិធីនេះពិតជាមានលក្ខណៈល្អសមស្របមួយដែលភាគីអាចទទួលយកបាន ពីព្រោះថាបទល្មើសព្រហ្មទណ្ឌខ្លះ មានការផ្តន្ទាទោសដាក់ពន្ធនាគារធ្ងន់ធ្ងរ (បទឧក្រិដ្ឋ) នេះជាហេតុធ្វើឲ្យមានការប៉ះពាល់ដល់សិទ្ធិសេរីភាពជាមូលដ្ឋានរបស់បុគ្គលដែលបានប្រព្រឹត្តបទល្មើសជាដើម។ មិនត្រឹមតែប៉ុណ្ណោះទេ នីតិវិធីនេះបានផ្តល់លទ្ធភាពសមស្របដល់គូភាគីនៃរឿងក្តី ឲ្យចូលរួមស្វែងរកការពិតជាមួយស្ថាប័នតុលាការ ដោយឆ្លុះបញ្ចាំងពីឯករាជ្យភាព នៃការអនុវត្តនីតិវិធីរបស់ខ្លួនដោយតាងនាម ប្រជារាស្ត្រខ្មែរទាំងមូល ហើយផ្តល់នូវយុត្តិធម៌សម្រាប់ប្រជាជននៃប្រទេសកម្ពុជា ដែលជារដ្ឋឯករាជ្យពិតប្រាកដ។ ចំពោះការបញ្ជូនរឿងទៅស៊ើបសួរនេះ បានផ្តល់សមត្ថកិច្ចយ៉ាងពេញលេញដល់ចៅក្រមស៊ើបសួរ ក្នុងការស្វែងរកឲ្យឃើញការពិតជូនជនរងគ្រោះ ជូនសង្គមជាតិ និង ជូនដល់ជនដែលប្រព្រឹត្តខុសច្បាប់ព្រហ្មទណ្ឌជាដើម។ ពីព្រោះថាឆ្លងកាត់នីតិវិធីស៊ើបសួរស្រាវជ្រាវបទល្មើសរួចហើយនោះ វាបានបង្ហាញឲ្យកាន់តែច្បាស់ថែមមួយកម្រិតទៀតថា តុលាការបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើតួនាទីរបស់ខ្លួន ក្នុងការជំនុំជម្រះថាជនណាម្នាក់មានទោស ឬគ្មានទោសនៃច្បាប់ក្នុងសង្គមជាធរមាន។

ម្យ៉ាងវិញទៀត ការស្រាវជ្រាវនៃបទល្មើសទាំងឡាយ ចៅក្រមស៊ើបសួរមិនអាចស៊ើបសួររឿងក្តីព្រហ្មទណ្ឌ ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីព្រះរាជអាជ្ញាបានឡើយ ហើយរាល់ការស៊ើបសួរត្រូវតែស៊ើបសួរនូវកម្មវត្ថុដែលមានចែងនៅក្នុងដីកាដែលបញ្ជូនមកនេះតែប៉ុណ្ណោះ ពោលគឺមិនអាចធ្វើការស៊ើបសួរទៅលើអង្គហេតុផ្សេងបានឡើយ។ នេះមានន័យប្រសិនបើចៅក្រមស៊ើបសួរបានអនុវត្តផ្ទុយពីនីតិវិធីនេះ ការស៊ើបសួរនោះពុំមានអានុភាព ហើយក៏មិនមានភាពយុត្តិធម៌សម្រាប់ភាគីពាក់ព័ន្ធឡើយ។ ហេតុនេះ ដើម្បីឲ្យមានភាពច្បាស់លាស់និងអាចទទួលយកបាន ព្រះរាជអាជ្ញា និងចៅក្រម មិនអាចធ្វើតាមតែចិត្តនឹកឃើញរបស់ខ្លួនបានទេ គឺត្រូវអនុវត្តតាមច្បាប់ដែលបានចែងពិតប្រាកដ និង ច្បាស់លាស់ ដោយឆន្ទៈឥតលំអៀងឡើយ។ ហើយចំណែកឯប្រជាពលរដ្ឋ គួរតែចូលរួមសហការជាមួយអ្នកអនុវត្តច្បាប់ពាក់ព័ន្ធ តាមរយៈការកោះហៅធ្វើជាសាក្សី ឬការផ្តល់នូវព័ត៌មានអំពីបទល្មើសណាមួយ ដែលខ្លួនបានដឹងដល់អាជ្ញាធរមានសមត្ថកិច្ចដើម្បីឲ្យពួកគាត់ចូលអន្តរាគមន៍បានទាន់ពេលវេលា។ ប្រជាពលរដ្ឋកម្ពុជាយើងបច្ចុប្បន្ននេះ នីតិវិធី

ព្រហ្មទណ្ឌ ឬច្បាប់នានាផ្សេងទៀត ពួកគាត់នៅយល់ដឹងមានកម្រិតនៅឡើយ ហេតុដូច្នេះហើយ ក្រសួងយុត្តិធម៌ និង ស្ថាប័នតុលាការត្រូវតែធ្វើការផ្សព្វផ្សាយ តាមបណ្ដាញសង្គមបច្ចេកវិទ្យាឲ្យមានភាពទូលំទូលាយ ព្រមទាំងលុបបំបាត់ចោលនូវរាល់អំពើពុករលួយគ្រប់រូបភាព និងគ្រប់ទម្រង់ដើម្បីឲ្យមានភាពជឿជាក់លើប្រព័ន្ធតុលាការក្នុងការស្វែងរកដំណោះស្រាយដោយសន្តិវិធី។ ពីព្រោះថា ប្រសិនបើមិនមានភាពជឿជាក់ លើប្រព័ន្ធតុលាការក្នុងការដោះស្រាយរឿងក្តីនោះទេ គឺអាចនិងធ្វើឲ្យសង្គមមានភាពវឹកវរ ចលាចល ប្រជាពលរដ្ឋពោពេញទៅដោយភាពច្របូកច្របល់ ដោយមិនគិតស្វែងរកដំណោះស្រាយតាមច្បាប់ជាដើម។

ដូច្នេះហើយក្នុងនាមយើងជាអ្នកបញ្ញាវន្តផ្នែកច្បាប់ ត្រូវតែចូលរួមចំណែកក្នុងការផ្សព្វផ្សាយឲ្យប្រជាពលរដ្ឋមានការយល់ដឹងអំពីច្បាប់ ដោយដំបូងឡើយត្រូវធ្វើខ្លួនឯងជាគម្រូក្នុងការអនុវត្តច្បាប់ជាមុនសិន មុននិងទៅពន្យល់ណែនាំតាមរយៈប្រជាពលរដ្ឋ ឲ្យពួកគាត់មានការយល់ដឹងកាន់តែច្បាស់ថែមមួយកម្រិតទៀតដែលទាក់ទងទៅ និងជីវភាពរស់នៅ របស់ពួកគាត់ប្រចាំថ្ងៃ។ ទោះបីជានីតិវិធីនៃការបញ្ជូនរឿងទៅស៊ើបសួរ នេះជាកិច្ចនីតិវិធីរបស់ ស្ថាប័នតុលាការតាមរយៈ ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរក៏ដោយ ក៏ប្រជាពលរដ្ឋគម្បីមានការយល់ដឹងដែរ ព្រោះនីតិវិធីនេះពាក់ព័ន្ធប្រជាពលរដ្ឋនៅត្រង់ចំណុចនៃការចូលរួមដើម្បីធ្វើការដាក់ពាក្យបណ្ដឹង រហូតដល់ចំនុចដែលចៅក្រមស៊ើបសួរធ្វើការកោះហៅប្រជាពលរដ្ឋ ឬភាគីពាក់ព័ន្ធឲ្យចូលខ្លួនមកបំភ្លឺក្នុងឋានៈជាសាក្សី ជនរងគ្រោះ ជនជាប់ចោទ តាមភាពចាំបាច់នៃនីតិវិធីព្រហ្មទណ្ឌ។

# ឯកសារយោង

## ១.ក្រមងឯកសាច្បាប់

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចូលជាធរមានកាលពីថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣។
- ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ។
- ច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រមនិង ព្រះរាជអាជ្ញា។
- ច្បាប់ក្រមនីតិវិធីព្រហ្មទណ្ឌចូលជាធរមានកាលពីថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧។
- ច្បាប់ស្ដីពីវិសោធនកម្មនៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០១៣។
- ច្បាប់ក្រមព្រហ្មទណ្ឌចូលជាធរមាន ឆ្នាំ ២០១០ ។

## ២.ក្រមងឯកសារមេរៀន

- វចនានុក្រមសម្ដេចព្រះសង្ឃ រាជ ជួនណាត ឆ្នាំ១៩៦៧ ។
- មេរៀននីតិវិធីព្រហ្មទណ្ឌលោកសាស្ត្រាចារ្យ សុខ រឿន បោះពុម្ពនៅឆ្នាំ២០១០-២០១១។
- សៀវភៅមគ្គុទេសក៍ស្ដីពីនីតិវិធីព្រហ្មទណ្ឌនៅតុលាការកម្ពុជា របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ចុះផ្សាយឡើងកាលពីខែ សីហា ឆ្នាំ២០១៣។
- មេរៀននីតិព្រហ្មទណ្ឌពិសេសរៀបរៀងដោយសាស្ត្រាចារ្យ កៅ សីហា បោះពុម្ពនៅឆ្នាំ២០១៤ ។
- មេរៀននីតិភស្តុតាងរបស់លោកសាស្ត្រាចារ្យ អ៊ិន បូផា បោះពុម្ពលើកទី២នៅឆ្នាំ ២០១៦។
- មេរៀននីតិវិធីព្រហ្មទណ្ឌ របស់លោកសាស្ត្រាចារ្យ Vinh-Koeurm បោះពុម្ពឆ្នាំ២០១៦។
- កម្រងទោសបញ្ញត្តិនិពន្ធដោយលោកសាស្ត្រាចារ្យ ម៉ម ចាន់ណៃត បោះពុម្ពលើកទី១ នៅឆ្នាំ ២០១៦។
- មេរៀននីតិវិធីព្រហ្មទណ្ឌរបស់លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត បោះពុម្ពនៅឆ្នាំ ២០១៧-២០១៨។
- មេរៀនបណ្ដឹងតុលាការរៀបចំដោយលោក Franz Kafka ។
- មេរៀននីតិវិធីព្រហ្មរបស់លោកស្រីសាស្ត្រាចារ្យ **ឌី លីឡា** និង លោកសាស្ត្រាចារ្យ **ខាន់ សុខា** ។